global witness

# ការកាន់កាប់អំណាចដោយហឹង្សា

## ការកាន់កាប់អំណាចដោយហឹង្សា ៖ អធិរាជក្រុមហ៊ុន របស់ គ្រួសារមានអំណាច នៅក្នុងប្រទេសកម្ពុជា



កក្កដាឆ្នាំ 2016

# មាតិការ

03 ខ្លឹមសារសង្ខេប និង អនុសាសន៍គន្លឹះ

06 សេចក្តីផ្តើម៖ កម្ពុជាបើកទ្វារចំហសម្រាប់ការធ្វើពាណិជ្ជកម្ម

07 សហប្រតិត្តការនិងឥទ្ធិពលនៃទិន្នន័យ

08 មែកធាងគ្រួសារហ៊ុន

10 អធិរាជអាជីវកម្មរបស់គ្រួសារត្រកូល ហ៊ុន

12 សក្តានុពលរបស់គ្រួសារត្រកូល ហ៊ុន នៅក្នុងវិស័យថាមពល

13 ក្រលែកមើលអាជីវកម្មវិនិយោគដោយលោកជំទាវ ហ៊ុន ម៉ាណា

16 ទិន្នន័យច្បាស់ការដែលបង្ហាញពីបញ្ជីក្រុមហ៊ុនទាំងអស់

18 ទំនាក់ទំនងរបស់គ្រួសារ ហ៊ុន ជាមួយក្រុមហ៊ុនលំដាប់អន្តរជាតិ

19 ហានិភ័យសម្រាប់វិនិយោគិនបរទេស

20 ចម្លើយតបទោលសម្រាប់ករណីចោទប្រកាន់របស់អង្គការ Global Witness

21 ការមិនខ្វល់ពីច្បាប់របស់គ្រួសារត្រូកូល ហ៊ុន

21 ការឆ្លៀតយកចំណេញពីលើធនធានរដ្ឋ

22 ការចំណាយលើប្រជាជន និងបរិស្ថាន

25 ការយកចំណេញពីវប្បធម៌រួចទោសបុគ្គល

26 The Hun Hegemony - ការពង្រឹងបន្ថែមលើការត្រួតត្រា

26 កម្លាំងរបស់ស្ថាប័នសាធារណ: និងកម្លាំងសន្តិសុខរបស់រដ្ឋ

27 រៀបការដើម្បីបង្កើតសម្ព័ន្ធ

28 អំពើសប្បុរសធម៌ចប់នៅផ្ទះ

28 ប្រព័ន្ធផ្សព្វផ្សាយ - ផ្សាយ និងមិនផ្សាយ

30 សេចក្តីសន្និដ្ឋាន

31 អនុសាសន៍

33 ឧប្បសម្ព័ន្ធ

33 ឧប្បសម្ព័ន្ធ 1 - របកគំហើញទាំងអស់របស់យើងខ្ញុំ

38 ឧប្បសម្ព័ន្ធ 2 - វិធីសាស្ត្រស្រាវជ្រាវ

38 ឧប្បសម្ព័ន្ធ 3 - ក្របខ័ណ្ឌច្បាប់

41 ឧប្បសម្ព័ន្ធ 4 - លម្អិតនៃរបកគំហើញសំខាន់ៗ

# ខ្លឹមសារសង្ខេប[1]

*“ខ្ញុំគិតថា ក្នុងរយៈពេលពីរឆ្នាំ ទ្រព្យសម្បត្តិរបស់ខ្ញុំនឹងថយចុះ ដោយសារតែនឹងមិនមានផលចំណេញ។ ហើយក្រៅពីប្រាក់ខែរបស់ខ្ញុំ ខ្ញុំមិនមានប្រាក់ចំណូលផ្សេងទៀតទេ។ ប៉ុន្តែ កូនៗរបស់ខ្ញុំនឹងទំនុកបម្រុងខ្ញុំ។ ពួកគេនឹងមិនឲ្យខ្ញុំអត់បាយហូបទេ។”*[2]

-ហ៊ុន សែន, ខែមេសាឆ្នាំ 2011



អ្នកកាសែតកម្ពុជាត្រូវបានបញ្ជាឲ្យប្រើប្រាស់ងារពេញរបស់ ហ៊ុន សែន នៅលើទំព័រមុខនៃកាសែតរបស់ពួកគេ "សម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែន"។

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានលើកក្រដាសប្រកាសទ្រព្យសម្បត្តិរបស់លោកឡើងដើម្បីបង្ហាញកាមេរ៉ា ដែលផ្តិត យករូបភាព ក្នុងពេលដែលលោកបានកំពុងថ្លែងនៅក្នុងបន្ទប់មួយពេញដោយអ្នកសារព័ត៌មានជាច្រើន។ ព្រឹត្តិការណ៍នេះបានកើតឡើងក្នុងខែមេសាឆ្នាំ 2011 ហើយជាលើកដំបូងបំផុតហើយ ដែលលោក ហ៊ុន សែនបានប្រកាសទ្រព្យសម្បត្តិរបស់លោកជាសាធារណៈដល់អង្គភាពប្រឆាំងអំពើពុករលួយ ដែលត្រូវបានបង្កើតឡើងថ្មីៗនៅក្នុងប្រទេសកម្ពុជា។[3]ច្បាប់ប្រឆាំងអំពើពុករលួយថ្មីថ្មោងរបស់ប្រទេសកម្ពុជា ក៏ចែងអំពីកាតព្វកិច្ចរបស់មន្ត្រីកម្ពុជាជាង 25,000 នាក់ ដែលត្រូវប្រកាសទ្រព្យសម្បត្តិរបស់ខ្លួនជារៀងរាល់ពីរឆ្នាំម្តង។ មន្ត្រីដែលមិនប្រកាស ប្រឈមនឹងការផាកពិន័យជាប្រាក់ច្រើនបំផុត US500$ និងជាប់ពន្ធនាគារហូតដល់មួយឆ្នាំ។ [4]

ក្បាលម៉ាស៊ីនដឹកនាំការប្រឆាំងអំពើពុករលួយនេះត្រូវបានបង្កើតឡើងយឺតពេល។ រយៈពេលជាច្រើនឆ្នាំ ប្រទេសកម្ពុជាបានរុំរ៉ៃនឹង ចំណាត់ថ្នាក់នៅបាតក្រោមនៃ*សន្ទស្សន៍ចំណាប់អារម្មណ៍លើអំពើពុករលួយ* ចេញដោយអង្គការតម្លាភាពអន្តរជាតិ។ ចុងក្រោយបំផុតនេះ ពោលគឺក្នុងឆ្នាំ 2015 ប្រទេសនេះស្ថិតនៅចំណាត់ថ្នាក់ទី 150 ក្នុងចំណោម 168 ប្រទេស ដែលនេះជាពិន្ទុទាបបំផុតនៅក្នុងតំបន់អាស៊ី អាគ្នេយ៍។[5]

ប៉ុន្តែតួលេខទាក់ទងនឹងសេចក្តីប្រកាសដំបូងរបស់លោក ហ៊ុន សែន បាននាំឲ្យមានចម្ងល់យ៉ាងច្រើន។ ប្រាក់ខែរបស់នាយករដ្ឋមន្ត្រីរូបនេះ ដែលគាត់បានអះអាងថា ជាប្រភពចំណូលតែមួយគត់របស់លោក ដែលផ្តល់ចំណូល US1150$ ក្នុងមួយខែ ឬ US13,800$ ក្នុងមួយឆ្នាំ។[6]ចម្ងល់កើតឡើងដោយសារតែត្រកូល ហ៊ុន ត្រូវបានគេដឹងយ៉ាងទូលំទូលាយថា ជាគ្រួសារមានបំផុតមួយ បើមិនមានបំផុត ក៏ជាគ្រួសារមានអំណាចបំផុតនៅក្នុងប្រទេសដែរ ដោយមានទ្រព្យសម្បត្តិបូកបញ្ចូលគ្នាទៅមានក្នុងចន្លោះ500 លាន ទៅ មួយរយកោដិដុល្លារអាមេរិក នេះបើយោងតាមការប៉ាន់ស្មានដោយអ្នកជំនាញការ។[7]

Hostile Takeover បានជួយដោះស្រាយរឿងអាថ៌កំបាំងនេះ។ នេះគឺជារបាយការណ៍ដំបូងបំផុត ដែលលាតត្រដាងថា តើនៅពីក្រោយឆាកនៃការគ្រប់គ្រងអំណាចបែបផ្តាច់ការរបស់លោក ហ៊ុន សែន គ្រួសាររបស់លោកប្រមូលផ្តុំដោយទ្រព្យសម្បត្តិផ្ទាល់ខ្លួនយ៉ាងសន្ធឹកសន្ធាប់ ដែលកើតចេញពីបណ្តាញដ៏ធំសម្រាប់ការបង្កើតកិច្ចព្រមព្រៀង អំពើពុករលួយ សំងាត់ៗ ដែលកំពុងតែធានា សន្តិសុខបន្ទាយនយោបាយរបស់នាយករដ្ឋមន្ត្រីរូបនេះ។

លោក ហ៊ុន សែនគឺជានាយករដ្ឋមន្ត្រីគ្រប់គ្រងដំណែងយូរជាងគេលំដាប់ទីប្រាំមួយនៅក្នុងពិភពលោក ពោលគឺក្តាប់អំណាចរយៈពេល 30 ឆ្នាំ ដែលជាឆ្នាំមានការបន្លំសន្លឹកឆ្នោត និងការដាក់គំនាបយ៉ាងខ្លាំងក្លាលើគណបក្សនយោបាយប្រឆាំង ដូចជា តាមរយៈការធ្វើឃាត ធ្វើទុក្ខបុកម្នេញ និងការចាប់ដាក់ពន្ធនាគារតាមអំពើចិត្ត។[8]របាយការណ៍នេះបង្ហាញមូលដ្ឋានភស្តុតាង ដើម្បីបញ្ជាក់ពីអ្វីដែលប្រជាជនកម្ពុជាសង្ស័យថា លោក ហ៊ុន សែន បានបំពានលើតួនាទីរបស់ខ្លួនជានាយករដ្ឋមន្ត្រី ដើម្បីអនុញ្ញាតឲ្យសាច់ញាតិរបស់លោកកាន់កាប់ទាំងស្រុង ឬក៏ចំណែកភាគច្រើននៅក្នុងឧស្សាហកម្ម សំខាន់ៗភាគច្រើននៅក្នុងប្រទេសកម្ពុជា។

ក្រុមអ្នកស៊ើបអង្កេតរបស់យើងខ្ញុំបានចំណាយពេលជាច្រើនខែ ដើម្បីស្វែងរកទិន្នន័យទាក់ទងនឹងកម្មសិទ្ធិក្នុងក្រុមហ៊ុននៅប្រទេស កម្ពុជា។ នេះជាព័ត៌មានដែលរដ្ឋាភិបាលរិតបន្តឹងមិនឲ្យបង្ហាញឲ្យដឹងថា តើអ្នកណាជាអ្នកកាន់កាប់ ឬគ្រប់គ្រង ក្រុមហ៊ុនឯកជននានាដែលចុះបញ្ជីនៅក្នុងប្រទេសនេះទេ។ ទោះយ៉ាងណា យើងខ្ញុំបានបង្កើតផែនការរកទិន្នន័យទាក់ទងនឹងខ្សែស្រឡាយគ្រួសារ ហ៊ុន ដើម្បីរកឲ្យឃើញថា គ្រួសារផ្ទាល់របស់លោកនាយករដ្ឋមន្ត្រីរូបនេះមានអាជីវកម្មចុះបញ្ជីដែលមានទំនាក់ទំនងជាមួយក្រុមហ៊ុនផ្សេងៗ ដែលមានចំណែកដើមទុនចុះបញ្ជីសរុបចំនួនជាង US$ 200 លានដុល្លា រួមទាំងសម្ព័ន្ធភាពជាមួយក្រុមហ៊ុនអន្តរជាតិជាច្រើន ដូចជា Apple, Nokia, Visa, Unilever, Proctor & Gamble និង Honda ជាដើម។[9] ក្រុមហ៊ុនអាជីវកម្មទាំងប្រាំបួនរបស់ពួកគេបានត្រួតត្រាយ៉ាងច្រើនលើវិស័យដែលអាចផ្តល់ប្រាក់ចំណេញច្រើនបំផុតនៅក្នុងប្រទេសកម្ពុជា បូករួមទាំងវិស័យដែលគេដឹងយ៉ាងទូលំទូលាយថា មានអំពើពុករលួយយ៉ាងច្រើន ដូចជា វិស័យរ៉ែ ល្បែងស៊ីសង និងអចលនទ្រព្យ។

តាមពិត នេះគ្រាន់តែចំណែកមួយនៃតម្លៃពិតនៃក្រុមហ៊ុននានាក្នុងគ្រួសារនេះ ពីព្រោះទិន្នន័យរដ្ឋាភិបាលដែលយើងខ្ញុំបានរកឃើញមានកម្រិតផ្នែកទំហំ ហើយគ្រួសារ ហ៊ុន ត្រូវបានគេនិយាយថា មានភាពស្មុគស្មាញក្នុងការស្វែងយល់ដោយសារតែមានការចុះឈ្មោះ មិត្តភក្រ្ត និងសហការីឲ្យធ្វើជាម្ចាស់ទៅវិញ ឬក៏លាក់អត្តសញ្ញាណនៅពីក្រោយសំបកក្រុមហ៊ុន។

*“[ក្នុងឆ្នាំ 2015 លោក ហ៊ុន សែន] បានប្រើប្រាស់ការគ្រប់គ្រងកម្លាំងសន្តិសុខរបស់លោក តុលាការ និងសេវាកម្មសាធារណៈ នៅក្នុងប្រទេសកម្ពុជា ដើម្បីបង្ខំឲ្យមេដឹកនាំគណបក្សប្រឆាំងធ្វើនិរទេសខ្លួន វាយដំអ្នកនយោបាយរបស់គណបក្សប្រឆាំង ចាប់អ្នករិះគន់ដាក់ពន្ធនាគារ អនុម័តច្បាប់សាហាវៗ និងបង្កើនវិសាលភាពនៃការត្រួតត្រារបស់គណបក្សកាន់អំណាចលើស្ថាប័ននានានៅក្នុងប្រទេសនេះ។”*[10]

**អង្គការឃ្លាំមើលសិទ្ធិមនុស្ស ខែមករា ឆ្នាំ** 2016។

1 ឯកសារយោងសម្រាប់ចំណុចដែលបានធ្វើឡើងនៅក្នុងផ្នែកនេះអាចរកឃើញបាននៅក្នុងតួសេចក្តីសំខាន់នៃរបាយការណ៍ លុះត្រាតែបានបង្ហាញក្នុងន័យផ្សេង។

ផលប៉ះពាល់នៃស្នាមមេដៃរបស់គ្រួសារ ហ៊ុន លើសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាមិនមានគ្រាន់តែទ្រព្យសម្បត្តិ និងសិទ្ធិពិសេសប៉ុណ្ណោះទេ។ វាបណ្តាលឲ្យមានការត្រួតត្រាលើសលប់លើអំណាចផ្សេងៗ ដែលបង្កើតឲ្យមានការគាបសង្កត់លើលទ្ធិប្រជាធិបតេយ្យ និងអំពើពុករលួយក្នុងប្រព័ន្ធច្បាប់នៅក្នុងប្រទេស ដែលនៅតែស្ថិតនៅក្រោមការត្រួតត្រារបស់លោក ហ៊ុន សែន ដដែល។ ជាលទ្ធផល ក្រុមហ៊ុននានាដែលមានចំណងពាក់ព័ន្ធជាមួយគ្រួសារត្រកូល ហ៊ុន ហាក់ដូចជាមិនប្រឈមមុខជាមួយ បញ្ហានឹងច្បាប់ប្រឆាំងអំពើពុករលួយ ដែលទប់ស្កាត់ការបែងចែកកិច្ចសន្យាសាធារណ: និងអាជ្ញាប័ណ្ណសម្បទាននានាដែលអាចផ្តល់ផលចំណេញច្រើន។ នេះមិនមែនជាបទឧក្រិដ្ឋដែលមិនមានជនរងគ្រោះទេ ដោយសារតែប្រតិបត្តិការមួយចំនួនរបស់ក្រុមហ៊ុនរបស់ពួកគេបានបណ្តាលឲ្យមានផលប៉ះពាល់យ៉ាងខ្លាំងបំផុតលើប្រជាជនកម្ពុជា និងបរិស្ថាន ដូចជា ការទន្ទ្រានយកដីដែលបង្កឲ្យប្រជាជនជាច្រើនគ្រួសារបាត់បង់ទីជម្រក និងទុគ៌តភាពក្នុងចំណោមប្រជាជនក្រីក្រតាមតំបន់ជនបទ។ ក្រៅពីសកម្មភាពក្នុងក្រុមហ៊ុន តាមការចោទប្រកាន់បុគ្គលនៅក្នុងគ្រួសារនេះបានប្រព្រឹត្តិបទល្មើសព្រហ្មទ័ណ្ឌកម្រិតធ្ងន់ជាច្រើន ដោយមិនប្រឈមនឹងការផ្តន្ទាទោស។ ជាច្រើនឆ្នាំកន្លងមកនេះ សមាជិក គ្រួសារនេះបានជាប់ពាក់ព័ន្ធក្នុងប្រតិបត្តិការរត់ពន្ធហេរ៉ូអ៊ីនដែលមានតម្លៃ 1 រយកោដិដុល្លារអាមេរិក អំពើបាញ់បោក និងបើករថយន្តបុកគេហើយរត់គេចខ្លួនទៀត ផង។

សាច់ញាតិរបស់លោកនាយករដ្ឋមន្ត្រីក៏មានសារ:សំខាន់ សម្រាប់ជួយរក្សាអំណាចត្រួតត្រារបស់លោក តាមរយ:មធ្យោបាយផ្សេងៗក្រៅពីជ្រើសតាំងដោយផ្ទែកឯកជន។ ពួកគេកាន់ដំណែងសំខាន់ៗនៅគ្រប់ផ្នែក ដូចជា នយោបាយ យោធា នគរបាល ប្រព័ន្ធផ្សព្វផ្សាយ និងមនុស្សធម៌ ដែលជាឧបករណ៍សម្រាប់គាំទ្រគណបក្សប្រជាជនកម្ពុជារបស់លោក ហ៊ុន សែន តាមរយ:ការឃោសនា ការឧបត្ថម្ភក្នុងសកម្មភាពនយោបាយ ឬកម្លាំងសមត្ថកិច្ច។ ឧទាហរណ៍ ហ៊ុន ម៉ាណែត កូនប្រុសច្បងរបស់លោកនាយករដ្ឋមន្ត្រី និងជាអ្នកបន្តវង្សត្រកូល កាន់បួនមុខដំណែងសំខាន់ៗ។ គាត់គឺជាមេបញ្ជាការរងអង្គភាពអង្គរក្សនាយករដ្ឋមន្ត្រី ប្រធានក្រុមការងារចម្រុះនៃកងយុទ្ធពលខេមរភូមិន្ទ មេបញ្ជាការរងកងទ័ព និងជាមេបញ្ជាការកម្លាំងពិសេសប្រឆាំងភេរវកម្មរបស់ប្រទេសកម្ពុជា។ ប្អូនប្រុសរបស់លោក ម៉ាណែត គឺលោកម៉ាណិត គឺជាវរសេនីយឯកក្នុងជួរយោធារ និងជាប្រធាននាយកដ្ឋានស៊ើបអង្កេតយោធានៃក្រសួងការពារជាតិ។
កូនពីរនាក់ចុងក្រោយបំផុតរបស់លោក ហ៊ុន សែន គឺម៉ានី និងម៉ាលី ម្នាក់ៗបានរៀបការជាមួយកូនរបស់ឧបនាយករដ្ឋមន្ត្រីក្នុងចំណោមឧបនាយករដ្ឋមន្ត្រីទាំងប្រាំបួននាក់។ នេះគ្រាន់តែជាឧទាហរណ៍ពីរនៃភាពពេញនិយមនៃការរៀបការភ្ជាប់បណ្តាញអំណាចរវាងគ្រួសារបង្កើតរបស់លោកនាយករដ្ឋមន្ត្រី និងអ្នកកាន់អំណាចធំៗ។ ហ៊ុន ម៉ាណា កូនស្រីច្បងរបស់លោក ហ៊ុន សែន និងជាអ្នកសម្បូរទ្រព្យសម្បត្តិ និងពាណិជ្ជករដ៏លេចធ្លោរបំផុតនៅក្នុងគ្រួសារ ជាកំពូលអ្នកមានម្នាក់ក្នុងចំណោមកំពូលអ្នកមានពីររូបផ្នែកប្រព័ន្ធនៅក្នុងប្រទេស ដែលកាន់កាប់អង្គភាពដែលផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងកាសែត។

លទ្ធផលនៃការត្រួតត្រាដែលគ្រួសារត្រកូល ហ៊ុន និងជនមានល្បីៗផ្សេងៗទៀតមាន នៅក្នុងស្ទើរតែគ្រប់ទិដ្ឋភាពនៃសង្គម គឺជារឿងដែលកើតឡើងនៅប្រទេសកម្ពុជានាពេលបច្ចុប្បន្ន។ ទោះបីជាមានកំណើនសេដ្ឋកិច្ចខ្ពស់ក៏ដោយ ប្រជាជនខ្មែរប្រាំមួយលាននាក់ ពោលគឺ 40 %នៃចំនួនប្រជាជនសរុប នៅតែរស់នៅក្រោម ឬក្បែរបន្ទាត់ភាពក្រីក្រ។[11]វិសមភាពកើនឡើងនៅក្នុងជីវភាពរស់នៅ រវាងអ្នកមាននៅតំបន់ក្រុង និងប្រជាន 80 ភាគរយដែលរស់នៅក្នុងតំបន់ជនបទក្នុងស្ថានភាពតោកយ៉ាក។[12]

*"អ្នកមានអំណាចមានចំណងពាក់ព័ន្ធជាមួយរដ្ឋមន្ត្រី ស្នងការ រហូតដល់អ្នករត់ការរកអំណាចតាមគណបក្ស។ លុយចរាចរនៅក្នុងបណ្តាញនយោបាយ និងសេដ្ឋកិច្ច មិនមែនត្រឹមតែក្នុងមិត្តភាពនោះទេ ថែមទាំងក្នុងចង្កោមគ្រួសារទៀតផង។"*[13] នេះជាប្រសាសន៍របស់លោក Sebastian Strangio ដែលត្រូវបានសរសេរនៅក្នុងសៀវភៅដែលមានចំណងជើងថា ប្រទេសកម្ពុជារបស់លោក ហ៊ុន សែន។

មូលដ្ឋានអំណាចក៏ពឹងអាស្រ័យលើរំហូរចូលនៃមូលធនខាងក្រៅផងដែរ។ លទ្ធផលស៊ើបអង្កេតរបស់យើងខ្ញុំបង្ហាញការភ្ជាប់ទំនាក់ទំនងរវាងក្រុមហ៊ុនគ្រប់គ្រង ឬកាន់កាប់ដោយគ្រួសារត្រកូល ហ៊ុន និងក្រុមហ៊ុនអន្តរជាតិ។ ទំនាក់ទំនងទាំងនេះមិនមែនត្រឹមតែបង្កើតឲ្យសំណួរទាក់ទងនឹងសីលធម៌ក្រុមហ៊ុនសម្រាប់ក្រុមហ៊ុនទាំងនោះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កឲ្យមានហានិភ័យផងដែរ។ ក្រុមហ៊ុននានា និងវិនិយោគិនដែលចុះកិច្ចព្រមព្រៀងប្រភេទណាក៏ដោយជាមួយអ្នកនយោបាយ ឬសមាជិកគ្រួសាររបស់ពួកគេ នៅក្នុងបរិយាកាសអាជីវកម្មដ៏ស្រអាប់ ដូចជា ហានិភ័យនៃការរំលោភច្បាប់ប្រឆាំងអំពើពុករលួយរបស់ប្រទេសកម្ពុជា ការប្រឈមនឹងទោសហិរញ្ញវត្ថុ និងចុងក្រោយការបាត់បង់កិត្តិយស។

ទោះបីជាចំណងទាំងនេះធ្វើឡើងតាមរយ:ភាពជាដៃគូផ្លូវការ ការជាវម៉ាក សង្វាក់ផ្គត់ផ្គង់ កិច្ចព្រមព្រៀងចែកចាយផល ឬសម្ព័ន្ធភាពអតិថិជនធូរលង់ក៏ដោយ ក្រុមហ៊ុនអន្តរជាតិមិនគួរធ្វើអជីវកម្មជាមួយបុគ្គល ឬក្រុមហ៊ុនដែលមានប្រវត្តិរងការចោទប្រកាន់ទាក់ទងនឹងអំពើពុករលួយ និងការរំលោភសិទ្ធិមនុស្ស។ អ្នកដែលធ្វើបែបនេះមិនបានអនុវត្តការត្រួត ពិនិត្យថ្លឹងថ្លែងសមស្របទេ ឬក៏ដឹងពីចំណងពាក់ព័ន្ធទាំងនោះដែរ ប៉ុន្តែជ្រើសរើសយកការមិនខ្វល់។

## ការរកឃើញសំខាន់ៗ ៖

- ញាតិសន្តានរបស់លោក ហ៊ុន សែន[14] មានទំនាក់ទំនងជាមួយបណ្តាក្រុមហ៊ុនឯកជនក្នុងស្រុកចំនួន 114 ក្រុមហ៊ុន ដែលមានដើមទុនចុះបញ្ជីសរុបចំនួនជាង 200 លានដុល្លារអាមេរិក។ តួលេខនេះមិនរាប់បញ្ចូលនូវក្រុមហ៊ុន 16 ក្នុងចំណោមក្រុមហ៊ុនទាំង 114 (14%) ដែលមិនមានទិន្នន័យបញ្ជាក់ពីដើមទុនឡើយ។[15] បញ្ជីឈ្មោះក្រុមហ៊ុនពេញលេញអាចរកឃើញនៅក្នុង ឧបសម្ព័ន្ធ 1 នៅទំព័រទី 33។
- ក្រុមហ៊ុន 103 ក្នុងចំណោមក្រុមហ៊ុនទាំងនេះ (90%) មានឈ្មោះសមាជិកក្រុមគ្រួសារនេះជាប្រធានក្រុមប្រឹក្សាភិបាល នាយក ឬមានចំណែកភាគហ៊ុនលើសពី (25%)។ ចំណុចនេះមានន័យថា ពួកគេមានការត្រួតត្រាទាំងស្រុង ឬខ្លាំងក្លា។[16] សម្រាប់ទិន្នន័យលម្អិតនៃតួរលេខនេះ សូមមើលឧបសម្ព័ន្ធទី 1 និង 4។
- ក្នុងចំណោមក្រុមហ៊ុន 44 ដែលអាចទទួលបានទិន្នន័យទាក់ទងនឹងភាគហ៊ុនិក ចំណែកភាគហ៊ុនដែលកាប់កាប់ដោយសមាជិកគ្រួសារនេះផ្តល់នូវកម្មសិទ្ធិដល់ពួកគេ ដែលមានភាកហ៊ុនយ៉ាងតិច %5។[17] សម្រាប់ទិន្នន័យលម្អិតនៃតួរលេខនេះ សូមមើលឧប្បសម្ព័ន្ធ 1។
- ក្រុមហ៊ុន 30 (គឺ26%) ដែលមានចំណងទាក់ទងជាមួយគ្រួសារនេះត្រូវបានចុះបញ្ជីជា "ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតដែលមានម្ចាស់តែមួយ" ដែលមានន័យថា ដើមទុនទាំងមូលត្រូវបានកាន់កាប់ ឬគ្រប់គ្រងដោយបុគ្គលតែម្នាក់។ សមាជិកគ្រួសារត្រកូល ហ៊ុន ត្រូវបានចុះបញ្ជីជានាយកក្រុមហ៊ុន ឬប្រធានក្រុមប្រឹក្សាភិបាលនៅក្នុងក្រុមហ៊ុនទាំង 30 ក្នុងចំណោមក្រុមហ៊ុនទាំងនេះ។ ដូច្នេះ ពិតជាទំនងខ្លាំងណាស់ថាសមាជិកគ្រួសារនេះគឺជាម្ចាស់ទោលនៃចំណែកភាគច្រើននៅក្នុងក្រុមហ៊ុនទាំងនេះ បើទោះជាមិនទាំងអស់ក្តី។[18] សម្រាប់ទិន្នន័យលម្អិតអំពីតួរលេខនេះ សូមមើលឧប្បសម្ព័ន្ធ 4។
- ក្រុមហ៊ុនដែលមានការពាក់ព័ន្ធជាមយយគ្រួសារត្រកូល ហ៊ុន ត្រួតត្រាលើចំណែកភាគច្រើននៅក្នុងវិស័យពាណិជ្ជកម្មដែលអាចផ្តល់ប្រាក់ចំណេញខ្លាំងបំផុត ដូចជា ពាណិជ្ជកម្មដោះដូរទំនិញ ហិរញ្ញវត្ថុ ថាមពល និងទេសចរណ៍។ ក្រុមហ៊ុនទាំងនោះក៏ធ្វើប្រតិបត្តិការអាជីវកម្មនៅក្នុងវិស័យជាច្រើន ដែលជោគជាំដោយអំពើពុករលួយ ដូចជា ល្បែងស៊ីសង សំណង់ កសិកម្ម និងរុករករ៉ែ។ សម្រាប់ព័ត៌មានលម្អិតទាក់ទងនឹងវិស័យនីមួយៗ សូមមើលទំព័រទី 11។
- ក្រុមហ៊ុនដែលមានចំណងពាក់ព័ន្ធជាមួយសមាជិកគ្រួសារត្រកូល ហ៊ុន មានសម្ព័ន្ធអាជីវកម្មជាមួយក្រុមហ៊ុនល៉ដាប់ពិភពលោក ដូចជា Visa, Unilever, Proctor & Gamble, Honda, Heineken និងក្រុមហ៊ុនគ្រឿងអេឡិចត្រូនិកធំៗជាច្រើន ដូចជា Apple, Cannon និង Nokia ជាដើម។ សម្រាប់ព័ត៌មានបន្ថែម សូមមើលទំព័រទី 18។

នេះទំនងជាចំណែកចុងក្រោយនៃបណ្តាញពាណិជ្ជកម្មដ៏ធំនេះហើយ។ ការស៊ើបអង្កេតរបស់យើងខ្ញុំពឹងផ្អែកស្ទើរតែទាំងស្រុងលើទិន្នន័យផ្លូវការរបស់រដ្ឋាភិបាល ដែលទទួលបានពីបញ្ជីក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្ម។ បញ្ជីនេះរាយឈ្មោះប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន ប៉ុន្តែមិនបង្ហាញជាលក្ខណ:ប្រព័ន្ធនូវបញ្ជីរាយនាមនាយក ឬភាគហ៊ុនិកពេញលេញទេ។ កាន់តែសំខាន់ជាងនេះទៀត របក គំហើញទាំងនេះគ្រាន់តែលាតប្រដាងនូវក្រុមហ៊ុនអាជីវកម្មទាំងនេះ ដែលត្រូវបានប្រកាសជាផ្លូវការប៉ុណ្ណោះ។ សមាជិកគ្រួសារទាំងនេះបូករួមទាំងលោក ហ៊ុន សែន ផងដែរ ត្រូវបានគេគិតថា បានលាក់ផលប្រយោជន៍នៅក្នុងក្រុមហ៊ុនឯកជន ដោយប្រើប្រាស់អ្នក តំណាង។ និយាយម្យ៉ាងទៀតថា ប្រើប្រាស់អ្នកមិនមែនជាសមាជិកគ្រួសារឲ្យចុះបញ្ជីក្រុមហ៊ុនអាជីវកម្ម ដោយប្រើឈ្មោះអ្នកទាំងនោះ ចំណែកឯគ្រួសារត្រកូលហ៊ុន នៅតែជាអ្នកទទួលផលដដែល។

ក្នុងខែមករា ឆ្នាំ 2016 អង្គការ Global Witness បានសរសេរលិខិតផ្ញើជូនសមាជិកគ្រួសារត្រកូលហ៊ុនចំនួន 25 រូប បូករួមទាំងលោក ហ៊ុន សែន ផ្ទាល់ផងដែរ ដើម្បីស្នើសុំប្រតិកម្មតបទៅនឹងការចោទប្រកាន់ពួកគាត់នៅក្នុងរបាយការណ៍នេះ។ នៅពេលបោះពុម្ពផ្សាយ មានតែម្នាក់ប៉ុណ្ណោះបានចម្លើយតបពីកូនប្រសាររបស់លោក ហ៊ុន សែន គឺលោក សុខ ពុទ្ធីវុធ ដែលត្រូវបានរៀបរាប់លម្អិតនៅទំព័រទី 20។ អង្គការ Global Witness ក៏បានសរសេរលិខិតផ្ញើជូនអ្នកកាន់ចំណែកកាន់កាប់ភាគីច្រើននៅក្នុងក្រុមហ៊ុន និងអង្គការកម្ពុជាផងដែរ ហើយក៏បានទទួលចម្លើយតបវិញចំនួនប្រាំមួយ ដែលត្រូវបានបង្ហាញនៅក្នុងរបាយការណ៍នេះ។



រូបថតរបស់លោក ហ៊ុន សែន និងប៊ុន រ៉ានី ជាមួយកូនៗរបស់ពួកគេចំនួនបួន និងស្វាមីភរិយារបស់ពួកគេ និងអតីតនាយករដ្ឋមន្ត្រីថៃ ថាក់ស៊ីន ស៊ីនាវ៉ាត់ត្រា ក្នុងឆ្នាំ 2009។ © រូបភាពរបស់ AP/សមាគមសារព័ត៌មាន

## អនុសាសន៍សំខាន់ៗ

សម្រាប់បញ្ជីអនុសាសន៍ពេញលេញ សូមអានទំព័រទី 31។

### ក្រុមហ៊ុន និងវិនិយោគិនគួរតែ៖

- សិក្សាស្រាវជ្រាវនិងវិភាគឲ្យបានស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយ ដើម្បីឲ្យដឹងច្បាស់ថា អ្នកណាខ្លះមានការពាក់ព័ន្ធនឹងគម្រោង វិនិយោគ។ នៅកន្លែងដែលមានការពាក់ព័ន្ធជាមួយអ្នកលេចធ្លោរផ្នែកអាជីវកម្ម ឬនយោបាយ (រួមទាំងអ្នកដែលពាក់ព័ន្ធនឹងកិច្ចការនយោបាយគ្រប់រូបផងដែរ) ដែលមានប្រវត្តិរងការចោទប្រកាន់ថាបានប្រព្រឹត្តិអំពើពុករលួយ ឬក៏សមាជិករបស់អ្នកទាំងនោះ សូមកុំបន្តអនុវត្តគម្រោងវិនិយោគនោះ។ នៅកន្លែងដែលគម្រោងនេះពាក់ព័ន្ធនឹងគម្រោងវិនិយោគដែលមានស្រាប់ សូមចាកចេញពីសម្ព័ន្ធភាពអាជីវកម្មនេះឲ្យបានឆាប់តាមលទ្ធភាពដែលអាចធ្វើទៅបាន។ ប្រសិនបើភស្តុតាងបញ្ជាក់ពីការជាប់ព័ន្ធនឹងការប្រព្រឹត្តិអំពើពុករលួយត្រូវបានបង្ហាញ នៅក្នុងដំណើរការនៃការសិក្សាស្រាវជ្រាវ និងវិភាគស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយ នោះក្រុមហ៊ុន ឬ វិនិយោគិននានាគួរតែរាយការណ៍ដោយខ្លួនឯង អំពីអ្វីដែលខ្លួនបានរកឃើញទៅអាជ្ញាធរពាក់ព័ន្ធទាំងអស់ដែលមានយុត្តាធិការស្របច្បាប់។

### រដ្ឋាភិបាលអន្តរជាតិដែលផ្តល់ជំនួយហិរញ្ញវត្ថុ និងជំនួយផ្សេងៗទៀតដល់ប្រទេសកម្ពុជា៖

- ធ្វើឲ្យប្រាកដថា ប្រាក់ជំនួយផ្តល់ដល់ប្រទេសកម្ពុជា ត្រូវបានគ្រប់គ្រងប្រកបដោយតម្លាភាព និងមិនហូរចូលហោប៉ៅរបស់អ្នកលេចធ្លោរទាំងនោះ ហើយត្រូវបានចំណាយតាមច្រកដែលផ្តល់ផលប្រយោជន៍ដល់ប្រជាជនខ្មែរ។
- ក្រើនរំឭកដល់វិនិយោគិនក្នុងប្រទេសរបស់ខ្លួន អំពីហានិភ័យខ្ពស់នៃការពាក់ព័ន្ធនឹងអំពើពុករលួយ នៅពេលបោះទុនវិនិយោគក្នុងប្រទេសកម្ពុជា។ ណែនាំពួកគេឲ្យសិក្សាស្រាវជ្រាវឲ្យបានច្បាស់លាស់ ដើម្បីធ្វើឲ្យប្រាកដថា ពួកគេនឹងមិនជាប់ព័ន្ធពាក់ព័ន្ធនឹងទំនាក់ទំនងពាណិជ្ជកម្មជាមួយអាជីវករ ឬអ្នកនយោបាយដែលមានប្រវត្តិរងការចោទប្រកាន់ថាមានការពាក់ព័ន្ធនឹងការប្រព្រឹត្តិអំពើពុករលួយ ឬសមាជិកគ្រួសាររបស់អ្នកទាំងនោះ។ សូមណែនាំ ពួកគេថា វិស័យមួយចំនួន ដូចជា និស្សារណកម្មធនធានធម្មជាតិ មានហានិភ័យខ្ពស់ខ្លាំង ដែលគួរតែចៀសវាង។
- ប្រឆាំងជាសាធារណ:ចំពោះការបិទសកម្មភាពលទ្ធិប្រជាធិបតេយ្យដែលកំពុងតែកើតឡើង ដូចជា ការបង្ក្រាបលើអ្នករិះគន់ រដ្ឋាភិបាល និងការដាក់ចេញនូវចំណាត់ការច្បាប់ដើម្បីបិទច្រកមិនឲ្យចេញរួច។

### រដ្ឋាភិបាលកម្ពុជាគួរ៖

- ចុះស៊ើបអង្កេតឲ្យបានគ្រប់ជ្រុងជ្រោយ ប្រកបដោយឯករាជ្យភាព និងតម្លាភាព អំពីករណីចោទប្រកាន់ដែលត្រូវបានលើកឡើងនៅក្នុងរបាយការណ៍នេះ ហើយចាត់ការតាមផ្លូវច្បាប់លើបុគ្គលឬក្រុមហ៊ុនណា ដែលត្រូវបានរកឃើញថាបានល្មើសនឹងច្បាប់កម្ពុជា។ ជាពិសេស គួរធ្វើការស៊ើបអង្កេតឲ្យបានគ្រប់ជ្រុងជ្រោយ និងមានតម្លាភាពលើលោក ហ៊ុន សែននិងសមាជិកគ្រួសាររបស់លោកអ្នកដែលមានឈ្មោះក្នុងរបាយការណ៍នេះ លើករណីបទល្មើសនៃអំពើខុសច្បាប់នានា និងការផ្តល់ និងទទួលបានការមានប្រៀបដោយអយុត្តិធម៌លើការវិភាជន៍ធនធានរបស់រដ្ឋ។
- កែទម្រង់ច្បាប់ប្រឆាំងអំពើពុករលួយ ដើម្បីឲ្យច្បាប់នេះស្របតាមគោលបំណង។ ជាពិសេស សូមបន្ថែមលក្ខខណ្ឌសម្រាប់ រដ្ឋាភិបាល និងសមាជិកគ្រួសាររបស់ពួកគេ ក្នុងការប្រកាសជាសាធារណ: អំពីទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ពួកគេ បូករួមទាំងក្រុមហ៊ុនអាជីវកម្មផងដែរ។
- ជំរុញឲ្យបញ្ចប់រលកនៃចំណាត់ការរាំងខ្ទប់កាលពីពេលថ្មីៗនេះ ដែលមានដូចជា៖
  - ការបញ្ឈប់សកម្មភាពធ្វើទុក្ខបុកម្នេញលើអ្នករិះគន់រដ្ឋាភិបាល
  - ការធ្វើឲ្យប្រាកដថា ច្បាប់រិតបន្តឹងនានាដែលកំពុងបញ្ចប់ការធ្វើសេចក្តីព្រាង មិនត្រូវបានអនុម័តក្នុងទម្រង់បច្ចុប្បន្ន ហើយច្បាប់រិតបន្តឹងប្រហាក់ប្រហែលផ្សេងៗទៀតដែលអនុម័តកាលពីពេលថ្មីៗនេះត្រូវបានលុបចោល។

### សេចក្តីផ្តើម៖កម្ពុជាបើកទ្វារសម្រាប់ការធ្វើពាណិជ្ជកម្ម៖

- ធ្វើការប្រកាសជាសាធារណ:អំពីទ្រព្យសម្បត្តិរបស់ខ្លួន រួមទាំងការជាប់ព័ន្ធទាំងអស់នាពេលបច្ចុប្បន្ន ជាមួយក្រុមហ៊ុនជាតិ និងអន្តរជាតិ ដើម្បីបញ្ជាក់ថាទំនាក់ទំនងទាំងនោះផ្លូវការ ឬក្រៅផ្លូវការ។

# កម្ពុជា បើកទ្វារសម្រាប់ការធ្វើពាណិជ្ជកម្ម

ផ្នែកនេះមានគោលបំណងពិពណ៌នាអំពីជោគវាសរបស់ប្រទេសកម្ពុជា ក្រោមការដឹកនាំរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលកំពុងធ្លាក់ចូលទៅក្នុងចលាចល។ ប៉ុន្តែទោះបីជាមានអំពើហិង្សានិងការរំលោភបំពានក៏ដោយ ប្រទេសនេះមិនមែនអនាធិបតេយ្យទេ។ នេះគឺជាបញ្ហាមានលក្ខណៈជាប្រព័ន្ធនៃរដ្ឋទាំងមូល ហើយធនធានរបស់រដ្ឋនេះមានអំពើពុករលួយចាក់ឫសរឹងមាំ ដែលជាហេតុបណ្តាលឲ្យសេរីភាពបញ្ចេញមតិត្រូវបានគាបសង្កត់ និងធ្វើបាបអ្នកដែលគាំទ្រសកម្មភាពទាំងនេះ។ ការកាន់កាប់អំណាចដោយហឹង្សា*(Hostile Takeover)*បង្ហាញពីផ្នែកសេដ្ឋកិច្ចនៅក្នុងសកម្មភាពរបស់លោក ហ៊ុន សែន និងបង្ហាញពីទំហំរបស់វានៅក្នុងវិស័យនីមួយៗនៃសេដ្ឋកិច្ចនយោបាយរបស់ប្រទេសកម្ពុជា។

ជាអតីតមេបញ្ជាការក្នុងរបបខ្មែរក្រហម លោក ហ៊ុន សែន បានឈានចូលដំណែងជានាយករដ្ឋមន្ត្រីក្នុងឆ្នាំ 1985។[19] ប្រជាជនកម្ពុជាបានបោះឆ្នោតទម្លាក់គាត់ក្នុងព្រឹត្តិការណ៍បោះឆ្នោតឆ្នាំ 1993 រៀបចំដោយអង្គការសហប្រជាជាតិ ប៉ុន្តែលោក ហ៊ុន សែន មិនព្រមចុះចេញពីដំណែងទេ។[20] តាំងពីពេលនោះមក ការបោះឆ្នោតម្តងៗនៅក្នុងប្រទេសកម្ពុជា តែងតែនាំឲ្យមានអំពើហិង្សា ឬការគំរាមប្រើអំពើហិង្សា។[21] ក្នុងឆ្នាំ 1997 មុនដល់ពេលបោះឆ្នោតសាកល ប្រជាជន 16 នាក់បានស្លាប់ និងជាង 150 នាក់បានរងរបួសក្នុងការវាយប្រហារដោយគ្រាប់បែក ដោយកងអង្គរក្សលោកនាយករដ្ឋមន្ត្រី ទៅលើការដើរដង្ហែរក្បួនដែលដឹកនាំដោយលោក សម រង្ស៊ី មេដឹកនាំគណបក្សប្រឆាំង។ នៅចុងឆ្នាំនោះរដ្ឋប្រហារបង្ហូរឈាមកើតឡើងក្នុងខែកក្កដាដែលលោកហ៊ុនសែនបានបណ្តេញសហនាយករដ្ឋមន្ត្រីរបស់លោកចេញពីតំណែង ហើយមនុស្សជាង 100 នាក់ ដែលភាគច្រើនជាសមាជិកគណបក្សរាជានិយម ត្រូវបានសម្លាប់។ រហូតមកទល់ពេលបច្ចុប្បន្នមិនមានបទល្មើសណាមួយក្នុងចំណោមបទល្មើសទាំងនេះត្រូវបានស៊ើបអង្កេតត្រឹមត្រូវឬផ្តន្ទាទោសទេ។[22]

ប្រទេសកម្ពុជាបានធ្វើឲ្យមានទ្វេគ្រោះដល់សហមន៍អន្តរជាតិ។ ឧទាហរណ៍ សហរដ្ឋអាមេរិកនាំចូលផលិតផលសម្លៀកបំពាក់ថោកៗចូល វិនិយោគក្នុងសេដ្ឋកិច្ចដែលមានបទបញ្ញត្តិធូរលង់លើទីផ្សារ និងជាម្ចាស់ជំនួយធំបំផុតលំដាប់ទីបីរបស់ប្រទេសនេះ។[23] ប៉ុន្តែ របាយការណ៍សិទ្ធិមនុស្សនៅក្នុងប្រទេសដឹកនាំដោយលោក ហ៊ុន សែន នេះបង្ហាញពីស្ថានភាពមិនល្អ សម្រាប់មានសិកាការទូតរបស់ រដ្ឋាភិបាលក្រុងវ៉ាស៊ីងតោន ហើយគាត់តែងតែជានាយករដ្ឋមន្ត្រីមិនមានគុណវឌ្ឍគ្រប់គ្រាន់ សម្រាប់ការអញ្ជើញជាផ្លូវការឲ្យទៅបំពេញទស្សនកិច្ចនៅសហរដ្ឋអាមេរិក។



យោធានៃសហរដ្ឋអាមេរិក និងយោធាកម្ពុជាជួបជុំគ្នារយៈពេលពីរសប្តាហ៍ជារៀងរាល់ឆ្នាំដើម្បីចូលរួមក្នុងការបង្វឹកទ័ពរួមគ្នា។

“ខ្ញុំគិតថា គួរកត់សម្គាល់ឲ្យបានខ្លាំងថា សហរដ្ឋអាមេរិក ការពិតទៅគឺជាទីផ្សារនាំចេញធំបំផុតសម្រាប់ប្រទេសកម្ពុជា ទោះបីជាយើងបែងចែកពិភពលោករវាងប្រទេសទាំងពីរក៏ដោយ។ ហើយយើងនឹងបន្តរកវិធីបង្កើនទំនាក់ទំនងពាណិជ្ជកម្មដោះដូរទំនិញ និងវិនិយោគបន្ថែមទៀត ដូចជា តាមរយៈការដោះស្រាយបញ្ហាអំពើពុករលួយ និងរកវិធីពង្រឹងស្ថាប័នច្បាប់របស់ប្រទេសកម្ពុជា។”[24]

នេះជាសម្រង់សម្តីរបស់លោក ចន ឃើរី រដ្ឋមន្ត្រីក្រសួង ការបរទេសសហរដ្ឋអាមេរិក ដែលថ្លែងទៅកាន់អ្នកសារព័ត៌មានក្នុងរាជធានីភ្នំពេញ កាលពីខែមករា ឆ្នាំ 2016។

ផ្នែកទីពីរនៃអតិក្រមនោះហាក់ដូចជាត្រូវបានបំភ្លេចចោល។ កាលពីដើមឆ្នាំ 2016 លោកប្រធានាធិបតីសហរដ្ឋអាមេរិក បារ៉ាក់ អូបាម៉ា បានស្នើសុំឲ្យលោក ហ៊ុន សែន មានវត្តមាននៅក្នុងកិច្ចប្រជុំកំពូលរវាងសហរដ្ឋអាមេរិកនិងអាស៊ាន នៅរដ្ឋកាលីហ្វ័រញ៉ា ដោយផ្តោតសំខាន់ទៅលើការពង្រឹងទំនាក់ទំនងពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិក និងបណ្តាប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍។ [25]មុននោះបន្តិច រដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិក លោក ចន ឃើរី បានបំពេញទស្សនកិច្ចក្នុងដំណាក់កាលរៀបចំកិច្ចប្រជុំមកជួបលោកនាយក រដ្ឋមន្ត្រី ក្នុងរាជធានីភ្នំពេញ។[26]ក្នុងចំណោមសំណើមួយចំនួនដែលលោក ហ៊ុន សែន បានលើកឡើងគឺ ស្នើឲ្យសហរដ្ឋអាមេរិកបង្កើនការនាំចូលពីប្រទេសកម្ពុជា ដោយកាត់លុបបំបាត់កូតា និងពន្ធនាំចូល ក្រុមហ៊ុនសហរដ្ឋអាមេរិកបង្កើនការវិនិយោគក្នុងប្រទេសកម្ពុជា និងស្នើឲ្យសហរដ្ឋអាមេរិកលុបចោលបំណុលប្រវត្តិសាស្ត្រមួយចំនួនរបស់ប្រទេសកម្ពុជា។[27]

វិធីសាស្ត្ររបស់លោក ហ៊ុន សែន នេះហាក់ដូចជាការសងសឹក។ រដ្ឋាភិបាលទីក្រុងវ៉ាស៊ីនតោនកំពុងរិះរកវិធីដាក់ឥទ្ធិពលក្នុង តំបន់អាស៊ីអាគ្នេយ៍ ដូចគ្នានឹងឥទ្ធិពលរបស់ប្រទេសចិននៅក្នុងតំបន់នេះដែរ ហើយប្រទេសកម្ពុជាដែលជាសម្ព័ន្ធមិត្តចាស់របស់ប្រទេសចិន និងជាគោលដៅវិនិយោគដ៏សំខាន់សម្រាប់វិនិយោចិន នឹងក្លាយជាទីផ្សារសំខាន់បំផុតមួយសម្រាប់កិច្ចខិតខំប្រឹងប្រែងទាំងនេះ។[28]ជាលទ្ធផល លោក ហ៊ុន សែន មិនត្រូវបានចាត់ទុកជាអ្នកកាន់អំណាចផ្តាច់ការដែលគួរទទួលខុសត្រូវលើ ការកេងប្រវ័ញ្ចជាលក្ខណៈប្រព័ន្ធលើប្រជាជន និងបរិស្ថានកម្ពុជាទេ ប៉ុន្តែជាដៃគូពាណិជ្ជកម្មសំខាន់ជាយុទ្ធសាស្ត្រ ដែលមានចំណាប់អារម្មណ៍ផ្ទាល់ខ្លួនដែលមានអំពើ ពុករលួយ ដែលអាចជាគោលដៅនៃគោលនយោបាយការបរទេសរបស់សហរដ្ឋអាមេរិក។

របាយការណ៍នេះបង្ហាញថា វិធីសាស្ត្រនេះមានផលប៉ះពាល់អាក្រក់ច្រើនណាស់។ របាយការន៍នេះបង្ហាញពីការប៉ុនប៉ងរបស់សហរដ្ឋ អាមេរិក និងរដ្ឋាភិបាលផ្សេងៗទៀតក្នុងការជំរុញឲ្យរបបរបស់លោក ហ៊ុន សែន បញ្ចប់ការប្រព្រឹត្តិអំពើពុករលួយ និងការរំលោភសិទ្ធិមនុស្សទ្រង់ទ្រាយធំ។ ដោយមានជំនួយដែលនៅតែហូរចូល និងកិច្ចព្រមព្រៀងវិនិយោគសម្រាប់ពិភាក្សា នោះគ្រួសាររបស់លោក ហ៊ុន សែន នៅតែមិនបញ្ឈប់ការកេងប្រវ័ញ្ចរបស់ខ្លួនដែរ។ ទោះបីស្តាប់ឮសារទាំងនេះច្បាស់ ពួកគេនៅតែបន្តពង្រីកប្រតិបត្តិការក្រុមហ៊ុនឯកជនរបស់ពួកគេ ដែលជាហេតុបណ្តាលឲ្យពួកគេមានលទ្ធភាពក្នុងការបង្កើនទ្រព្យ ដែលចាំបាច់សម្រាប់ការថែរក្សាការគ្រប់គ្រងអំណាចរយៈពេល 30 ឆ្នាំរបស់ពួកគេ។[29]

រដ្ឋាភិបាលសហរដ្ឋអាមេរិក និងរដ្ឋាភិបាលផ្សេងៗទៀតដែលជាម្ចាស់ជំនួយសំខាន់ៗ និងដៃគូពាណិជ្ជកម្មធំៗរបស់ប្រទេសកម្ពុជា គួរប្រើប្រាស់ឥទ្ធិពលរបស់ខ្លួន ដើម្បីធានាឲ្យមានការកែទម្រង់ដែលនឹងជួយបញ្ឈប់ការកេងយកទ្រព្យសម្បត្តិ។ ពួកគេក៏ណែនាំដល់បណ្តាក្រុមហ៊ុនដែលវិនិយោគក្នុងប្រទេសកម្ពុជា ឲ្យមានការយល់ដឹងអំពីហានិភ័យផ្នែកច្បាប់ ហិរញ្ញវត្ថុ និងកេរ្តិ៍ឈ្មោះ ក្នុងការប្រកបអាជីវកម្មនៅក្នុងបរិយាកាសពុករលួយបែបនេះ។






ប្រជាជនកម្ពុជាតវ៉ាប្រឆាំងនឹងច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាលនៅខាងក្រៅព្រឹទ្ធសភានៅខែកក្កដា ឆ្នាំ 2015។ ទោះបីជាការប្រឆាំងយ៉ាងខ្លាំងក្លាទាំងនៅក្នុងប្រទេស និងនៅក្រៅប្រទេសក្តី ច្បាប់នេះនៅតែត្រូវបានអនុម័តកាលពីមួយខែមុន។

# ក្រុមហ៊ុនក្នុងប្រទេសកម្ពុជា និងអំណាចនៃទិន្នន័យ

គ្រួសារត្រកូលហ៊ុនត្រូវបានគេដឹងច្បាស់ថាមានទំនាក់ទំនងជាមួយនឹងក្រុមហ៊ុននិងសហគ្រាសឧស្សាហកម្មមួយចំនួនក្នុងប្រទេសកម្ពុជា ក៏ប៉ុន្តែពីមុនមិនដែលមាននរណាព្យាយាមបញ្ជាក់លាតត្រដាងពីកម្រិតវិសាលភាពនៃការគ្រប់គ្រងរបស់ពួកគេចំពោះវិស័យជំនួញរបស់ប្រទេសទេ។ ដោយប្រើប្រាស់ទិន្នន័យដែលទទួលបានពីការចុះបញ្ជីក្រុមហ៊ុនរបស់ក្រសួងពាណិជ្ជកម្មប្រទេសកម្ពុជា អ្នកស៊ើបអង្កេតរបស់ អង្គការគ្លូបប៊ិលវីតណែសអាចបើកបង្ហាញថាតើគ្រួសារត្រកូលហ៊ុនកាន់កាប់ឬគ្រប់គ្រងដោយចំណែកលើក្រុមហ៊ុននានាដែលមានចំណែកទុនភាគហ៊ុនសរុបទាំងអស់ច្រើនជាង200លានដុល្លាសហរដ្ឋអាមេរិក។[30]នេះទំនងគ្រាន់តែជាចំណែកមួយដ៏តូចក្នុងចំណោមចំណែកដ៏ធំៗដែលបានផ្តល់ឲ្យមេធាវីទាំងឡាយនូវការតែងតាំងក្លែងក្លាយ ក្រុមហ៊ុនសំបកឬជាក្រុមហ៊ុនដែលមិនបើកបញ្ចេញឲ្យគេដឹងដែលតាមការស្មានត្រូវបានប្រើប្រាស់ដោយអ្នកមានអំណាចបុណ្យសក្តិខាងនយោបាយរបស់ប្រទេសកម្ពុជាក្នុងការបិទបាំងការពាក់ព័ន្ធក្នុងមុខជំនួញពាណិជ្ជកម្មរបស់ពួកគេ។[31]ក្នុងចំណោមក្រុមហ៊ុនទាំងឡាយដែលគ្រួសារត្រកូលហ៊ុនកាន់កាប់ឬគ្រប់គ្រងដោយផ្នែកមានមួយចំនួនដែលត្រូវបានចោទប្រកាន់ពីបទល្មើសសង្គមនិង បរិស្ថានដ៏អាក្រក់ ឧទាហរណ៍ក្រុមហ៊ុនយុនសៀ នាំចេញនាំចូលដែលមានជាប់ពាក់ព័ន្ធក្នុងរឿងការរំលោភយកដីធ្លីនិងការបណ្តេញចេញដោយបង្ខំនិងក្រុមហ៊ុន Garuda ដែលយោងតាមសារព័ត៌មានក្នុងស្រុកថាបានគាបសង្កត់ដោយអំពើរហឹង្សាទៅលើការតវ៉ារបស់កម្មកររោងចក្រកាត់ដេរសំលៀកបំពាក់[32]

ទិន្នន័យក្រសួងពាណិជ្ជកម្មដែលបានជូនដំណឹងពីការស៊ើបអង្កេតលើករណីនេះកាលម្តងនោះស្ថិតក្នុងការឃ្លាំមើលតាមអ៊ីនធឺណែតជាសាធារណៈ ក៏ប៉ុន្តែក្នុងខែមេសាឆ្នាំ2 0 1 5 រដ្ឋាភិបាលបានរឹតបណ្តឹងការអាចចូលទៅកាន់ការមើលនេះ។[33]កាលពីមុន គេអាចធ្វើការឆែកមើលដោយមិចបញ្ចេញអត្តសញ្ញាណផ្ទាល់ខ្លួនទៅលើការចុះបញ្ជីក្រុមហ៊ុនតាមគេហទំព័រអនឡាញរបស់ក្រសួង។ ចំណុចនេះបានជួយឲ្យអ្នកស៊ើបអង្កេតនិងសកម្មជននានាអាចចូលទៅបើកមើលព័ត៌មានស្តីពីភាពជាកម្មសិទ្ធរបស់ក្រុមហ៊ុនដោយមិនត្រូវបានដឹងឬកំណត់អត្តសញ្ញាណបានដោយរដ្ឋាភិបាលទេដែលបន្ថយលទ្ធភាពដែលពួកគេអាចប្រឈមនឹងវាយបកសងសឹងនៅពេលដែលពួកគេចុះផ្សាយឬធ្វើអ្វីមួយចំពោះអ្វីដែលពួគគេបានរកឃើញ។ ក៏ប៉ុន្តែ ពេលឥឡូវនេះ អ្នកប្រើប្រាស់ត្រូវតែចុះឈ្មោះដើម្បីទទួលបានការអាចl o g i n ចូលមើលបាន ដែលជួយឲ្យ រដ្ឋាភិបាលអាចត្រួតពិនិត្យថាតើនរណាកំពុងតែប្រើប្រាស់ប្រព័ន្ធទិន្នន័យរបស់ពួកគេនិងតើពត៌មានអ្វីដែលពួកគេកំពុងស្វែងរក។[34]ក្នុងពេលដែលលោកនាយករដ្ឋមន្ត្រីកំពុងតែជ្រើសរើសក្រុមមន្ត្រីរាជការដើម្បីគ្រប់គ្រងមើលលើអ៊ីនធឺណែតសម្រាប់មតិយោបល់ដែលត្រូវបានចាត់ទុកថាជាការរិះគន់មកលើគោលនយោបាយរដ្ឋាភិបាល ជាគម្រោងមួយដែលនាំឲ្យមានការចាប់ខ្លួន ការចាប់ឃុំឃាំងនិងពាក្យបណ្តឹងដែលមនុស្សភាគច្រើនមិនចង់ប្រថុយគ្រោះថ្នាក់។[35]

ការអន្តរាគមន៍របស់រដ្ឋាភិបាលក្នុងការបង្អាក់ការចូលទៅឆែកមើលព័ត៌មានកម្មសិទ្ធក្រុមហ៊ុនគឺជាផ្នែកមួយនៃការវាយប្រហារកាន់តែ ទូលំទូលាយឆ្ពោះលើតម្លាភាពនិងគណនីយភាពក្នុងប្រទេសកម្ពុជា។ ច្បាប់គ្រប់គ្រងលើអង្គការក្រៅរដ្ឋាភិបាលដែលទើបត្រូវបាន អនុម័តថ្មីៗនេះអនុញ្ញាតិឲ្យរដ្ឋាភិបាលបិទឬហាមឃាត់អង្គការក្រៅរដ្ឋាភិបាលណាដែលនិយាយប្រឆាំងនឹងគោលនយោបាយរបស់ខ្លួន។[36] ច្បាប់ទូរគមនាគមន៍ឆ្នាំ 2015 បានផ្តល់ឲ្យរដ្ឋាភិបាលនូវអំណាចតាមដានដោយគ្មានការត្រួតពិនិត្យសមល្មមគ្រប់គ្រាន់និងចាប់ដាក់ទោសបណ្តាញទំនាក់ទំនងអេឡិចត្រូនិកណាក៏ដោយដែល"អាចធ្វើឲ្យប៉ះពាល់ដល់សន្តិសុខជាតិនិងសណ្តាប់ធ្នាប់សាធារណៈ។"[37] ការគ្រប់គ្រងតាមអនឡាញកាន់តែត្រូវបានពង្រឹងដោយ"ក្រុមធ្វើសង្គ្រាមបច្ចេកវិទ្យាពត៌មានវិទ្យា"របស់រដ្ឋាភិបាលដែលត្រូវបានបង្កើតឡើងក្នុងខែតុលាឆ្នាំ2014 ដើម្បី"ការពារគោលជំហរនិងកេរ្តិ៍ឈ្មោះកិត្យានុភាពរបស់រដ្ឋាភិបាល"។[38]

ការបំបិទសេរីភាពលទ្ធិប្រជាធិបតេយ្យកំពុងកាន់តែធ្វើឲ្យមានការលំបាកសម្រាប់ប្រជាជនកម្ពុជាក្នុងការត្រួតពិនិត្យនិងសម្តែងមតិអំពីអំពើរពុករលួយដែលមាននៅចំចំណុចបេះដូងនៃប្រព័ន្ធសេដ្ឋកិច្ចនិងនយោបាយរបស់ពួកគេ។ ជាត្រឡប់មកវិញកត្តានេះផ្តល់ផលល្អដល់ជនល្មើសដោយមាននិទ្ទណ្ឌភាព ផ្តុំអំណាចជាមួយនិងបុព្វសិទ្ធិនិងកាន់តែពង្រីកគម្លាតរវាងអ្នកមាននិងអ្នកក្រ។[39]អ្នករិះគន់និងគូរបដិបក្សខាងនយោបាយជាច្រើនរបស់លោកហ៊ុនសែនត្រូវតែស្វែងរកការនិរទេសខ្លួនទៅក្រៅប្រទេស។[40]

ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីបោះពុម្ភផ្សាយរបាយការណ៍នេះ អង្គការគ្លូបប៊ិលវីតណែស Global Witness បានបំលែងទិន្នន័យដែលរកបានមកដោយលំបាកពីគេហទំព័រក្រសួងពាណិជ្ជកម្មមកដាក់លើអនឡាញ វិញដែលជាបណ្តុំទិន្នន័យអាចស្វែងរកបានពេញលេញមកដាក់នៅលើគេហទំព័រវ៉ែបសាយរបស់យើង។ ដោយត្រូវបានចាប់ផ្តើមបើកដំណើរការបន្ត បន្ទាប់ជាមួយនឹងការបោះពុម្ភផ្សាយនេះ គេហទំព័រក្រុមហ៊ុនកម្ពុជារបស់យើងអនុញ្ញាតិឲ្យអ្នកសារពត៌មាន អ្នកវិនិយោគទុននិងអង្គការក្រៅរដ្ឋាភិបាលធ្វើការវិភាគថាតើនរណាជាម្ចាស់ គ្រប់គ្រងឬមានភាគហ៊ុនធំជាងគេនៅក្នុងក្រុមហ៊ុននានានៅក្នុងប្រទេសកម្ពុជាដោយគ្មានភ័យព្រួយពីការចាប់ពិរុទ្ធ ការកាត់ទោសឬក៏អាក្រក់ជាងនេះទៅទៀត។[41]

យើងសង្ឃឹមថាបណ្តុំទិន្នន័យនេះក៏នឹងអាចត្រូវបានប្រើប្រាស់ផងដែរដោយក្រុមហ៊ុននិងអ្នកវិនិយោគទុនដែលកំពុងតែពិចារណាឬក៏បានរកស៊ីក្នុងជំនួញជាមួយនឹងកម្ពុជារួចទៅហើយ។ វាគួរតែអាចត្រូវបានប្រើប្រាស់ជាចំណុចចាប់ផ្តើមដ៏សំខាន់មួយសម្រាប់ដំណើរការខិតខំប្រឹងប្រែងនាពេលខាងមុខ ដែលអាចជួយឲ្យអ្នកវិនិយោគទុនថ្លឹងថ្លែងពីកម្រិតនៃការប្រថុយប្រថានដោយមើលឃើញថាតើនរណាដែលពួកគេកំពុងចាប់ដៃរកស៊ីជាមួយ។ បើគ្មានធនធាននេះទេ ពួកគេនឹងព្យាយាមទាំងលំបាកក្នុងការកំណត់ថាតើនរណានឹងបានចំណេញពីការវិនិយោគរបស់ពួកគេ ដោយទុកឲ្យពួកគេប្រឈមនឹងគ្រោះថ្នាក់ផ្នែកច្បាប់និងហិរញ្ញវត្ថុដ៏ធំសម្បើម។ សំខាន់ជាងនេះទៅទៀត ការប្រើប្រាស់បណ្តុំទិន្នន័យនេះនឹងជួយពួកគេក្នុងការកំណត់ថាតើការវិនិយោគរបស់ពួកគេកំពុងតែជួយបង្កើនឲ្យមានអំពើរពុករលួយ ការរំលោភសិទ្ធិមនុស្ស អយុត្តិធម៌សង្គមឬ បទល្មើសបរិស្ថាននិងអ្វីដែលអាចធ្វើឲ្យមានការខូចខាតមិនថាចំពោះតែប្រជាជនសាមញ្ញនៅក្នុងប្រទេសកម្ពុជាឬកេរ្តិ៍ឈ្មោះរបស់ពួកគេកាន់តែខ្លាំងក្លាឡើង។

# មែកធាងគ្រួសារហ៊ុន



គតិព្រឹទ្ធបណ្ឌិត
ប៊ុន រ៉ានី
(ភរិយាលោកហ៊ុនសែន)
ប្រធានកាកបាទក្រហមកម្ពុជា ហើយត្រូវបានចោទប្រកាន់ថា ប្រើប្រាស់កាកបាទក្រហមជានយានដើម្បីគាំទ្រការកាន់អំនាចរបស់គណបក្សប្រជាជនកម្ពុជា។
នាយករដ្ឋមន្ត្រី
ហ៊ុន សែន
(ស្វាមី អ្នកស្រី ប៊ុន រ៉ានី)
បានកាន់កាប់ប្រទេសកម្ពុជា អស់រយៈពេល បីទសវត្សតាមរយៈការក្លែងបន្លំសន្លឹកឆ្នោត និងការប្រើប្រាស់កម្លាំងបាយគាបសង្កត់គូរនយោបាយប្រឆាំង។
លោក ហ៊ុន នេង
(ស្វាមីលោកស្រី លាង វួចឆេង)
ជាសមាជិកសភាជាមួយគណបក្ស ប្រជាជនកម្ពុជា ជាអ្នកដែលគំរាមបុគ្គលិក Global Witness ជាសាធារណៈ ថាលោក នឹងវាយពួកគេរហូតទាល់តែក្បាលពួកគេបែក។
លោក ហ៊ុន សាន
ជាឪពុកលោក ហ៊ុន ជា ដែលជាម្ចាស់ក្រុមហ៊ុនផ្នែកពាណិជ្ជកម្ម និង ដឹកជញ្ជូន។
អ្នកស្រី ហ៊ុន សេងនី
ពាក់ព័ន្ធនឹងក្រុមហ៊ុនដែលជាប់ចោទពីបទរំលោភយកដីធ្លី ការកាប់ព្រៃឈើខុសច្បាប់ និងការប្រើប្រាស់ហិង្សារគាបសង្កត់លើបុគ្គលិករោងចក្រកាត់ដេរដែលធ្វើការតវ៉ា។
អ្នកស្រី ឌី ប្រឹម
ត្រូវចោទប្រកាន់ពីបទ សូកប៉ាន់បុគ្គលិកស៊ីវិល 200,000ដុល្លាអាមេរិក ដើម្បីបង្កើតសំណុំរឿងលើដីកម្មសិទ្ធិរបស់បុរសពោះម៉ាយ ចំណាស់ម្នាក់។
លោក ឌី ចូច
(លែងលះអ្នកស្រី សេង គាង)
ពីមុនមកធ្លាប់ដឹកនាំឲ្យមានការកាប់ ព្រៃឈើ ជាអ្នកដែលកាប់បំផ្លាញព្រៃឈើខុសច្បាប់ជាច្រើន និង ប្រើប្រាស់ អំពើហឹង្សារលើប្រជាពលរដ្ឋក្នុងសហគមន៍។
លោក ហ៊ុន ម៉ាណែត
(ស្វាមី ពេជ្រ ចាន់ម៉ូនី)
ជាអ្នកដែលមានមុខមាត់ធំដុំ នៅក្នុងជួរកងកំលាំងប្រដាប់អាវុធកម្ពុជា ហើយត្រូវបានគេរាយការណ៍ និងជឿថា នឹងមានលទ្ធភាពស្នងតំណែងជានាយករដ្ឋមន្ត្រីបន្តពី ឪពុក។
ហ៊ុន ម៉ានិត
(ស្វាមី ហុក/ឌី ចិន្តាវី និងជាកូនប្រសារលោក ម៉ែន ភក្តី)
ឧត្តមសេនីយ៍ឯក នៅក្នុងជួរទ័ព និង ជានាយកក្រុមហ៊ុនផ្គត់ផ្គង់ថាមពលធំទីពីរ បើ ទោះបីជាមានច្បាប់ហាមឃាត់មិនមន្ត្រីយោធាគ្រប់គ្រងក្រុមហ៊ុនណាមួយក៏ដោយ។
ហ៊ុន ម៉ានី
(ស្វាមី យឹម ឆាយ និងជាបងប្អូនថ្លៃ យឹម លាង)
ជាសមាជិកសភាវ័យក្មេង បំផុតនៅក្នុងគណបក្សប្រជាជនកម្ពុជា ដែលបានរៀបការជាមួយនឹងកូនស្រីរបស់ នាយករដ្ឋមន្ត្រីស្តីទីនៃប្រទេសកម្ពុជា។
ហ៊ុន តូ
(ស្វាមី Thai Jackie Tai Hien)
ពាក់ព័ន្ធនឹងការរត់ពន្ធអាភៀន តំលៃមួយពាន់លានដុល្លាអាមេរិក ទៅប្រទេសអូស្ត្រាលី និង ជាម្ចាស់កម្មសិទ្ធនៃរថយន្តស្ព័តទំនើបៗតំលៃលើសពីមួយលានដុល្លាអាមេរិក។
ហ៊ុន សៀងហេង
(ស្វាមី សុខ សុភ័ក្ត្រ)
បានរៀបការជាមួយអ្នកស្រីសុខ សុភ័ក្ត្រដែល ជាប្រធានក្រុមហ៊ុន iOne ដែលជាក្រុមហ៊ុនលក់រាយផលិតផល Apple នៅកម្ពុជា។
ហ៊ុន ជា
បានក្លាយជាឧត្តមសេនីយ៍ត្រី នៅឆ្នាំ ២០១៤ បើទោះបីជាធ្លាប់មានប្រវត្តិ បំពានច្បាប់ធ្ងន់ធ្ងរ ព្រមទាំងការពាក់ព័ន្ធនឹងការបាញ់បោះនិងបើកឡានបុក
ហ៊ុន ម៉ាណា
(ភរិយា ឌី វិជ្ជា)
ទទួលបានប្រាក់ចំណេញដែលចុះបញ្ជីពីម្ភៃពីរក្រុមហ៊ុន ដែលមានតំលៃ ៦៦លានដុល្លា ដោយរាប់បញ្ចូលទាំង ក្រុមហ៊ុន ទស្សនាវដ្តីមួយ ប៉ុស្តិ៍វិទ្យុ និងទូរទស្សន៍ដែលគាំទ្រគណបក្សប្រជាជនកម្ពុជា។ អ្នកស្រី មានបណ្តាញអាជីវកម្មជាច្រើនទៀតដែលពាក់ព័ន្ធនឹង គ្រួសារបេក្ខជនតំណាងរាស្ត្រ ឡៅ ម៉េងឃីន។
ហ៊ុន ម៉ាលី
(ភរិយា សុខ ពុទ្ធិវុទ្ធ)
មានប្រាក់ចំណេញពីផ្នែកថាមពល បដិសណ្ឋារកិច្ច ផ្សព្វផ្សាយ ឱសថស្ថាន និងក្រុមហ៊ុន ព្រមទាំងជាម្ចាស់កម្មសិទ្ធិផ្សារទំនើបទីមួយនៅ ទីក្រុងភ្នំពេញ។
ហ៊ុន គឹមឡេង
(រៀបការជាមួយ ណេត សាវឿន)
រៀបការជាមួយអគ្គស្នងការនគរបាលជាតិ និងមានចំណងទាក់ទងយ៉ាងរឹងមាំជាមួយម៉ាកអន្តរជាតិល្បីៗ ដូចជា Hard Rock Café និង Gloria Jeans Coffees ។
ហ៊ុន ចាន់ថា
(ពីមុនរៀបការជាមួយ ឌី វិជ្ជា)
មានប្រាក់ចំនូលដែលចុះបញ្ជីចំនួន ២៧លានដុល្លា និងមានជំនួញជាមួយឧកញ៉ា គិត ម៉េងដែលជាប្រធានអង្គជំនុំពាណិជ្ជកម្មកម្ពុជា។
ហ៊ុន ចន្ទ
ប្រធានក្រុមហ៊ុន Heritage Investment ជាក្រុមហ៊ុនហិរញ្ញវត្ថុមានតម្លៃប្រាំសែនដុល្លារសហរដ្ឋអាមេរិក។
ចំណុចសំខាន់
រៀបអាពាហ៍ពិពាហ៍ជាមួយ
បង/ប្អូនបង្កើតរបស់
បងប្អូនជីដូនមួយរបស់
ឪពុក/ម្តាយរបស់

# អាណាចក្រជំនួញរបស់គ្រួសារត្រកូលហ៊ុន

ចាប់តាំងពីលោកហ៊ុនសែនបានកាន់កាប់តំណែងជាសហនាយករដ្ឋមន្ត្រីក្នុងឆ្នាំ 1993 មក គាត់បានក្ដោបក្ដាប់តួនាទីជាយុទ្ធសាស្ត្រក្នុង រដ្ឋាភិបាល ជួរនគរបាលប៉ូលីស យោធា រដ្ឋសភា តុលាការនិងផ្នែកសប្បុរសធម៌ជាមួយនិងសាច់ញាតិនិងមិត្តភក្តិដើម្បីធានាពីការគ្រប់គ្រងទាំងស្រុងលើរចនាសម្ព័ន្ធរដ្ឋ។[42]ច្រើនឆ្នាំកន្លងមករចនាសម្ព័ន្ធចាត់តាំងទាំងនេះបានបន្តចូលដល់វិស័យឯកជន ដោយមានតំណែងនាយក តំណែងចាងហ្វាង និងការចូលហ៊ុនភាគច្រើនចុងបញ្ចប់ស្ថិតក្នុងដៃសមាជិកគ្រួសារនេះឬអ្នកជិតស្និទ្ធ ជាមួយ។[43]កត្តានេះបានបង្កើតឲ្យមានចរន្តហូរនៃទ្រព្យសម្បត្តិដែលរីកលូតលាស់និងបិទជិតដ៏ធំសម្បើមមួយ ដែលចងប្របាច់បញ្ចូលគ្នាដោយយុទ្ធសាស្ត្ររៀបការទាក់ទងគ្នាទៅវិញទៅមក។[44]កត្តានេះបានបង្កើតឲ្យមានចរន្តហូរនៃទ្រព្យសម្បត្តិដែលរីកលូតលាស់និងបិទជិតដ៏ធំសម្បើមមួយ ដែលចងប្រ បាច់បញ្ចូលគ្នាដោយយុទ្ធសាស្ត្ររៀបការទាក់ទងគ្នាទៅវិញទៅមក។

ការក្ដោបក្ដាប់លើសេដ្ឋកិច្ចរបស់លោកនាយករដ្ឋមន្ត្រីគឺមួយផ្នែកបានដោយសារតែវិសាលភាពទំហំនៃការកាន់កាប់មុខជំនួញរបស់គ្រួសារគាត់ដូចជាវិសាលភាពដ៏ធំមួយនៃវិស័យសេដ្ឋកិច្ច ដែលមានសរុបទាំងអស់មាន20។[45]

មកទល់ពេលនេះចំនួនដ៏ច្រើនជាងគេបំផុតនៃក្រុមហ៊ុនដែលត្រូវបានគ្រប់គ្រងគ្រួសារនេះគឺជា**ក្រុមហ៊ុនពាណិជ្ជកម្ម** ដែលស្មើនឹងប្រហែល 15% នៃចំនួនសរុបដែលមាន17 ក្រុមហ៊ុន។[46]នេះគឺជាវិស័យដែលពោរពេញទៅដោយអំពើពុករលួយ។ ក្នុងឆ្នាំ 2013 ការនាំចេញនាំចូលរបស់ប្រទេសកម្ពុជាមានតម្លៃច្រើនជាង 18 កោដិលានដុល្លា។[47]ក្នុងឆ្នាំដដែលនេះ ក្រុមប្រឆាំងអំពើពុករលួយសុច្ចរិតភាពហិរញ្ញវត្ថុសកលបានប៉ាន់ប្រមាណថាប្រទេសកម្ពុជាខាតបង់ប្រាក់ចំនួន 4 កោដិលានដុល្លាទៅក្នុងលំហូរហិរញ្ញវត្ថុខុសច្បាប់ ដែលក្នុងនោះទឹកប្រាក់ចំនួន 3.86 កោដិលានដុល្លាគឺបានមកពីការគែបន្លំវិក័យបត្រមុខជំនួញឲ្យខុស។[48] ទម្រង់នៃការលាងលុយកខ្វក់ខុសច្បាប់ ការ គែបន្លំវិក័យបត្រជំនួញកើតឡើងនៅពេលដែលក្រុមហ៊ុនទាំងនោះចាត់ចែងគ្រប់គ្រងដោយក្លែងបន្លំនូវតម្លៃ បរិមាណ ឬគុណភាពនៃទំនិញឬសេវាកម្មដែលបាននឹងកំពុង នាំចូលឬនាំចេញនៅលើឯកសារដែលបានដាក់ជូនគយ។[49]អង្គការគ្លូបប៊ិលវីតណែស Global Witness ទំនងជាបានបើកកកាយរកឃើញនូវការក្លែងបន្លំមួយក្នុងឆ្នាំ 2015 នៅពេលដែលអ្នកស៊ើបអង្កេតអាចទទួលបានឯកសារនានាដែលបង្ហាញពីឧកញ៉ាដែលកាប់ឈើខុសច្បាប់និងមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងលោកហ៊ុនសែន គឺលោកទ្រីភាពដែលបាន ផ្លាស់ប្ដូរតម្លៃឈើដ៏ច្រើនសម្បើមដែលបាននឹងកំពុងនាំចេញទៅកាន់ទីក្រុងហុងកុងដោយគេជពន្ធគយយ៉ាងជាក់ស្ដែង។[50]

**វិស័យធនធានធម្មជាតិ** របស់ប្រទេសកម្ពុជាគឺជាជម្រើសមួយផ្សេងទៀតសម្រាប់ការវិនិយោគរបស់គ្រួសារត្រកូលហ៊ុន។ យើងបានបង្កើតការកាន់កាប់ក្ដោបក្ដាប់របស់គ្រួសារត្រកូលហ៊ុនក្នុងក្រុមហ៊ុនកសិកម្មជាច្រើន អ្វីដែលលេចធ្លោគួរឲ្យកត់សម្គាល់ជាងគេគឺវិស័យជ័រកៅស៊ូ ដែលជាដំណាំធំចំបងទីពីររបស់ប្រទេសកម្ពុជាបន្ទាប់ពីដំណាំស្រូវ។[51]គ្រួសារនេះក៏មានបណ្ដាញទំនាក់ទំនងជាមួយក្រុមហ៊ុនរុករករ៉ែចំនួនប្រាំទៀតផងដែរដែលមានអាជ្ញាប័ណ្ណសម្រាប់គម្រោងរុករករ៉ែដែលមិនទាន់ចំរ៉ាញ់នៅក្នុងខេត្តយ៉ាងហោចណាស់ចំនួន5។[52]ជាមួយនឹងការទាញយកផលពីប្រេងកាតនិងរ៉ែប្រទេសកម្ពុជាដែលនឹងត្រូវចាប់ផ្ដើមក្នុងពេលឆាប់ៗនេះ វាគឺជាពេលវេលាដ៏សំខាន់សម្រាប់ឧស្សាហកម្មធនធានរ៉ែដែលកំពុងមានការកើនឡើងរបស់ប្រទេសកម្ពុជាហើយអ្នកដែលពាក់ព័ន្ធក្នុងឧស្សាហកម្មនេះនឹងរកបានកម្រៃដ៏ច្រើនសម្បើម។[53]របាយការណ៍របស់អង្គការគ្លូប ប៊ិលវីតណែសក្នុងរយៈពេលម្ភៃឆ្នាំចុងក្រោយនេះក៏បានបង្ហាញពីអំពើពុករលួយ ការរំលោភសិទ្ធិមនុស្សនិងការបំផ្លិចបំផ្លាញបរិស្ថាននៅចំកណ្ដាលបេះដូងនៃវិស័យនេះ ដោយបង្ហាញ ថាតើអ្នកធំមានអំណាចដែលគ្រប់គ្រងប្រទេសនេះអាចលួយប្លន់ទ្រព្យសម្បត្តិ ធនធានធម្មជាតិជាតិដោយមិនមានទោសអ្វីទាល់តែសោះបានដោយរបៀបណា ក្នុងនោះទីមួយគឺព្រៃឈើ បន្ទាប់មកប្រេងឧស្ម័ននិងរ៉ែបម្រុងទុក និងថ្មីៗបំផុតនេះគឺដីធ្លីសម្រាប់ជំនួញកសិកម្ម។[54]

**វិស័យសំណង់និងអចលនទ្រព្យ** ឥឡូវនេះគឺជាជំនួញធំនៅក្នុងប្រទេសកម្ពុជាដែលមានការវិនិយោគក្នុងឆ្នាំ 2015 សរុបជាទឹកប្រាក់ចំនួន 3.34 កោដិលានដុល្លាដែលកើនឡើង 33%លើសកាលពីឆ្នាំមុន។[55] វិស័យនេះ ដែលគ្រួសារត្រកូលហ៊ុនមានភាគហ៊ុនក្នុង 7ក្រុមហ៊ុន ត្រូវបានគេរាយការណ៍ថាមានការពុករលួយស៊ីសំណូកជាមួយនិងអ្នកមានទ្រព្យសម្បត្តិធំៗដែលមានគេនិយាយថាអាចបង់ប្រាក់សូកប៉ាន់ដល់អ្នកត្រួតពិនិត្យហើយបន្ទាប់មកមិនអើរពើរចំពោះច្បាប់ប្បញ្ញត្តិ។[56]

**ប្រព័ន្ធផ្សព្វផ្សាយ**របស់ប្រទេសកម្ពុជាគឺប្រមូលផ្ដុំផ្ដោតនៅក្នុងដៃអ្នកនយោបាយនិងអ្នកជំនួញធំៗដែលភាគច្រើននៃអ្នកទាំងនោះមានកម្មសិទ្ធគ្រប់គ្រងក្រុមហ៊ុនផ្សព្វផ្សាយឯកជន។[57] គ្រួសារត្រកូលហ៊ុនគ្រប់គ្រងក្រុមហ៊ុនផ្សព្វផ្សាយចំនួនពីរគឺទូរទស្សន៍បាយ័ននិងកាសែតកម្ពុជាថ្មី ដែលជួយធ្វើឲ្យពួកគេអាចផ្សព្វផ្សាយតាមរយៈទូរទស្សន៍ វិទ្យុនិងការបោះពុម្ពផ្សាយ ។[58] ក្នុងឆ្នាំ 2015 អង្គការ Freedom House បានចាត់ចំណាត់ថ្នាក់បរិស្ថានសារព័ត៌មានប្រទេសកម្ពុជាថា "មិនមានលក្ខណៈសេរី" ដោយថ្លែងថា "*ប្រព័ន្ធផ្សព្វផ្សាយភាគច្រើនគឺគាំទ្រលំអៀងទៅរកបក្សនយោបាយដោយបើកចំហរដែលទុកកន្លែងដ៏ តិចតួចសម្រាប់ ទស្សនៈដែលមិនលំអៀងនិងអ្នកសារព័ត៌មានដំណើរការប្រតិបត្តិក្នុងប្រយោជន៍ សាធារណៈ។*"[59]

**តំបន់សេដ្ឋកិច្ចពិសេស** សមាជិកគ្រួសារត្រកូលហ៊ុននិងបក្សពួករបស់គេក៏គ្រប់គ្រងលើសលប់លើតំបន់សេដ្ឋកិច្ចពិសេសប្រទេសកម្ពុជាផងដែរ ក្នុងនោះមានដូចជាសួនឧស្សាហកម្មដែលត្រូវបានបែងចែកដោយច្រើនសម្រាប់ការផលិតទំនិញនានាជាកន្លែងដែលការផ្ទុករោងចក្រនិងកម្មករជាច្រើនមាននៅទីនោះជាប់ៗគ្នា។[60] ច្បាប់ជំនួញនិងពាណិជ្ជកម្មមានភាពខុសគ្នាពីបណ្ដាប្រទេសនានា ដែលផ្ដល់ដល់ក្រុមហ៊ុនដែលធ្វើការវិនិយោគក្នុងតំបន់សេដ្ឋកិច្ចពិសេសនូវផលប្រយោជន៍សារពើរពន្ធបន្ថែមជាច្រើនដូចជាសម្បទានលើពន្ធគយនិងពន្ធលើតម្លៃបន្ថែម VAT។[61]

ក្នុងទំនិញដែលមានតម្លៃ 12កោដិលានដុល្លាដែលត្រូវបាននាំចេញដោយប្រទេសកម្ពុជាក្នុងឆ្នាំ 2015 ហើយប្រហែល10%បានមកពីតំបន់សេដ្ឋកិច្ចពិសេសទាំងនេះ។[62] ក្រុមហ៊ុននានាដែលដាក់ពាក្យស្នើរសុំអភិវឌ្ឍន៍តំបន់ទាំងនោះហើយទទួលធ្វើការរបង្កើតនិងគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសមួយ ជាដំបូងត្រូវមានការអនុញ្ញាតិពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលមានសមាសភាពរដ្ឋមន្ត្រីជាន់ខ្ពស់ រដ្ឋាភិបាលនិងដែលត្រូវបានដឹកនាំដោយលោកហ៊ុនសែនផ្ទាល់។[63] ក្រុមប្រឹក្សានេះធ្វើការពិនិត្យពាក្យស្នើរសុំវិនិយោគនិងប្រាក់ឧបត្ថម្ភលើកទឹកចិត្តនានា ដែលផ្ដល់ឲ្យសមាជិករបស់ខ្លួននូវអំណាចដ៏ធំសម្បើមលើការសម្រេចចិត្តវិនិយោគរបស់ប្រទេសកម្ពុជា។[64]

ថ្មីៗនេះប្រទេសកម្ពុជាបានអនុម័តយល់ព្រមឲ្យមានតំបន់សេដ្ឋកិច្ចពិសេសចំនួន34 ដែលមិនដូចក្នុងប្រទេសផ្សេងៗដែលវាត្រូវបានគ្រប់គ្រងដោយក្រុមហ៊ុនឯកជនជាជាងដោយរដ្ឋាភិបាល។[65] ក្នុងចំណោមតំបន់សេដ្ឋកិច្ចពិសេស 31ដែលមានព័ត៌មានយ៉ាងហោចណាស់មាន12 តំបន់ដែលត្រូវបានបែងចែកដល់ឧកញ៉ាដែលធ្វើជំនួញដោយមានទំនាក់ទំនងខ្សែរបណ្ដាញជិតស្និទ្ធិជាមួយគ្រួសារត្រកូលហ៊ុនឬគណៈបក្សប្រជាជនកម្ពុជា។[66] នេះរួមបញ្ចូលទាំងឈ្មោះ ឌី ចិន្តាវី ដែលជាភរិយារបស់លោកហ៊ុនម៉ាណិត និង ម្ដាយរបស់នាងឈ្មោះម៉ែនភក្តី ដែលមានអាជ្ញាប័ណ្ណអភិវឌ្ឍន៍ក្រុមហ៊ុន D & M ក្នុងចំនួនទឹកប្រាក់ 52 លានដុល្លា(បារិត) ដែលជាតំបន់សេដ្ឋកិច្ចពិសេសស្ថិតក្នុងខេត្តស្វាយរៀង។[67] ក្រុមហ៊ុននាំចេញនាំចូល NLC ដែលត្រូវបានគ្រប់គ្រងដោយប្អូនស្រីថ្លៃរបស់លោកហ៊ុនសែនឈ្មោះ លាង វួចឆេង ដែលកាន់កាប់តំបន់សេដ្ឋកិច្ចពិសេសក្នុងខេត្តស្វាយរៀងដែលតាមបញ្ជីទិន្នន័យរដ្ឋាភិបាលដាក់ថាមានប្រាក់ទុនចំនួន 13 លានដុល្លា។[68]

សម្រាប់បញ្ជីទាំងស្រុងនៃការកាន់កាប់មុខជំនួញរបស់គ្រួសារត្រកូលហ៊ុន សូមមើលក្រាហ្វិកព័ត៌មាននៅលើទំព័រ 16 ឬ ឧបសម្ព័ន្ធ 1 លើទំព័រ 33 ។



# ផ្ទះហោប៉ៅនៃគ្រួសារត្រកូលហ៊ុន

អាណាចក្រសាជីវកម្មនៃគ្រួសាររបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន សន្ធឹងកាត់គ្របដណ្ដប់លើវិស័យអាជីវកម្មភាគច្រើនដែលផ្ដល់ផលចំណេញច្រើនបំផុតរបស់កម្ពុជា។ ដូច្នេះ វាច្រើនពេកហើយដើម្បីឱ្យប្រជាពលរដ្ឋនៅភ្នំពេញអាចតស៊ូក្នុងការជៀសវាងជួរហោប៉ៅរបស់ពួកគេជាច្រើនដងក្នុងមួយថ្ងៃ...




**KEY**

1. កូនស្រីពៅរបស់លោក ហ៊ុន សែនជាប្រធានរបស់ TK Avenue ដែលជាផ្សារទំនិញបែបទំនើបទីមួយនៅទីក្រុងភ្នំពេញ។

2. លោកស្រី ហ៊ុន ម៉ាណា មានភាគហ៊ុនក្នុងក្រុមហ៊ុន K Thong Huot Telcom ដែលអះអាងថាមានសិទ្ធិចែកចាយផ្ដាច់មុខសម្រាប់ទូរស័ព្ទ Nokia នៅកម្ពុជា។

3. លោកស្រី ហ៊ុន ម៉ាណា ជាប្រធានក្រុមហ៊ុន NVC Coporation ដែលផលិតទឹកពិសាបរិសុទ្ធប្រកដប វីតាល់ ដែលគាំទ្រដោយ ក្រសួងទេសចរណ៍ សម្រាប់ការប្រើប្រាស់ក្នុងព្រឹត្តិការណ៍ផ្លូវការផ្សេងៗ។

4. ក្មួយប្រុសរបស់លោកគឺជានាយករបស់ក្រុមហ៊ុន LHR Asean Investment ដែលជាក្រុមហ៊ុនឥន្ធនៈ មានបណ្ដាញដ៏ធំជាមួយស្ថានីយ៍ឥន្ធនៈទូទាំងផ្ទៃប្រទេស។

5. “កូនស្រីច្បងបង្អស់របស់លោក ហ៊ុន សែន គឺលោកស្រី ហ៊ុន ម៉ាណា ជាម្ចាស់ក្រុមហ៊ុនកាសែត កម្ពុជាថ្មីដែលលីដែលមានអ្នកអានជាជនជាតិខ្មែរ ជិត 100,000 នាក់។“

6. ក្មួយស្រីរបស់លោកហ៊ុន សែន គឺជាប្រធានក្រុមហ៊ុនហាងកាហ្វេ Gloria Jean’s Coffees ដែលមានហាងចំនួនប្រាំសាខានៅកម្ពុជា

7. កូនលោក ហ៊ុន សែនទាំងបីនាក់ ត្រូវបានចុះបញ្ជីជាម្ចាស់ក្រុមហ៊ុនអគ្គិសនីឯកជនដែលលក់ថាមពលទៅឱ្យរដ្ឋ។

8. លោកស្រី ហ៊ុន ម៉ាណា ជាម្ចាស់ប្រព័ន្ធផ្សព្វផ្សាយបាយ័ន ដែលផ្សព្វផ្សាយតាមរយៈស្ថានីយទូរទស្សន៍ចំនួនបី និងនៅលើវិទ្យុបាយ័ន ដែលបានចាត់ទុកថាគាំទ្ររដ្ឋាភិបាល។

9. ភរិយារបស់ក្មួយប្រុសលោក ហ៊ុន សែន ជាម្ចាស់ហាង iOne ដែលជាក្រុមហ៊ុនលក់រាយផលិតផល Apple ឈានមុខគេរបស់កម្ពុជា។

**FIGURE 1: What business sectors do companies affiliated to the Hun family operate in?**



# អំណាចគ្រប់គ្រងដ៏លើសលប់របស់គ្រួសារត្រកូលហ៊ុនលើវិស័យថាមពល

**វិស័យថាមពលរបស់ប្រទេសកម្ពុជាក៏ធ្លាប់មានមូលដ្ឋានការវិនិយោគទុនច្រើនសម្រាប់គ្រួសារត្រកូលហ៊ុនដែរ។ តម្លៃអគ្គីសនីកម្ពុជាគឺមានតម្លៃខ្ពស់ជាងគេក្នុងចំណោមប្រទេសនៅក្នុងតំបន់និងនៅលើពិភពលោក។**[69]ក្នុងខែកក្កដាឆ្នាំ 2015 ប្រជាពលរដ្ឋដែលមានទីលំនៅក្នុងទីក្រុងភ្នំពេញបានត្អូញត្អែរតវ៉ាបន្ទាប់ពីពួកគេបានរងគ្រោះដោយសារតែតម្លៃអគ្គីសនីកើនឡើងមិនសមហេតុផលទោះបីជាទម្រង់ការ ប្រើប្រាស់នៅដដែលនិងមានការដាច់ភ្លើងញឹកញាប់ក៏ដោយ។[70] ក្នុងខែតុលាឆ្នាំដដែលនោះ ប្រជាជនកម្ពុជាបានទាមទារឲ្យមានការបញ្ចុះតម្លៃប្រេងសាំង ដោយពួកគេបានកត់សម្គាល់ឃើញថាតម្លៃប្រេងឆៅមានការធ្លាក់ចុះទូទាំងពិភពលោកពីតម្លៃជាង $90 ក្នុងមួយធុង(បារ៉ែល)មកត្រឹមតែ $50 តែប៉ុណ្ណោះក៏តម្លៃប្រេងឧស្ម័ននៅក្នុងប្រទេសកម្ពុជាមានការធ្លាក់ចុះត្រឹមតែ 16% តែប៉ុណ្ណោះ។[71]

ទីក្រុងភ្នំពេញស្រូបទាញយកអគ្គីសនីប្រម៉ាណ 90% នៃអគ្គីសនីរបស់ប្រទេស ខណៈដែលនៅតាមតំបន់ជនបទនានាដែលមានប្រជាជនរស់នៅប្រម៉ាណជា 80% មានទំនោរខ្វះខាតការទទួលបានអគ្គីសនីប្រើប្រាស់។[72] បញ្ហានេះត្រូវកំណត់ឲ្យមានការផ្លាស់ប្តូរ។ ក្នុងឆ្នាំ 2013 លោកហ៊ុនសែនបានសន្យាថាគ្រប់ភូមិទាំងអស់ក្នុងប្រទេសកម្ពុជានឹងមានអគ្គិសនីប្រើប្រាស់ត្រឹមឆ្នាំ 2020 ហើយគ្រប់គ្រួសារ ប្រម៉ាណ 70% នឹងមានអគ្គីសនីប្រើប្រាស់ត្រឹមឆ្នាំ2030។[73] ជាមួយនឹងការពង្រីកដ៏លឿនរហ័សនេះវាប្រហែលជាមិនគួរឲ្យភ្ញាក់ផ្អើលទេដែលគ្រួសារត្រកូលហ៊ុនមាន ភាគហ៊ុនធំក្នុងវិស័យថាមពលរបស់ប្រទេសនេះ។

យើងអាចបង្កើតទំនាក់ទំនងបណ្តាញគ្រួសារដល់ទៅប្រាំ*ក្រុមហ៊ុនថាមពល។[74] ប្តីរបស់ហ៊ុនម៉ាលី គឺលោកសុខ ពុទ្ធីវុទ្ធជានាយកគ្រប់គ្រងក្រុមហ៊ុន សូម៉ាថាមពល ដែលក្រសួងពាណិជ្ជកម្មបានចុះបញ្ជីថាមានចំណែកភាគហ៊ុនរួមចំនួន 10 លានដុល្លាសហរដ្ឋអាមេរិក។[75] ក្នុងឆ្នាំ 2012 ក្រុមហ៊ុន សូម៉ាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មមួយដែលមានទឹកប្រាក់ចំនួន 3 លានដុល្លាសហរដ្ឋអាមេរិកក្នុងគម្រោងថាមពលជីវៈឧស្ម័នដែលរកស៊ីជាមួយនឹងក្រុមហ៊ុនយក្សរបស់សហរដ្ឋអាមេរិកឈ្មោះ General Electric។[76] កិច្ចព្រមព្រៀងនេះគឺជាគម្រោងទីមួយដែលនឹងត្រូវអនុវត្តបន្ទាប់ពីមានកិច្ចព្រមព្រៀងអភិវឌ្ឍន៍បំលាស់ថាមពលរបស់ក្រុមហ៊ុន General Electric ក្នុងឆ្នាំ 2011 ជាមួយនិង រដ្ឋាភិបាលកម្ពុជា។[77]

លោកហ៊ុន តូ ដែលត្រូវបានចោទប្រកាន់ពីបទជាប់ពាក់ព័ន្ធ ផ្នែក ការរត់ពន្ធថ្នាំញៀនអន្តរជាតិនិងក្រុមជនលៀងលុយកខ្វក់ ដែលការចោទប្រកាន់ទាំងនេះត្រូវបានគាត់បដិសេធនោះ ត្រូវបានចុះក្នុងបញ្ជីថាជានាយកគ្រប់គ្រងក្រុមហ៊ុនប្រេង LHR Asean Import Export and Agent និងជានាយកនៃក្រុមហ៊ុនវិនិយោគ LHR Asean ផងដែរ។[78] អ្នកបន្ទាប់គ្រប់គ្រងបណ្តាញស្ថានីយប្រេងឥន្ធនៈទូទាំងប្រទេសកម្ពុជា។[79]



នៅឆ្នាំ 2015 ហ៊ុន សែន បានដំឡើងតំណែងកូនប្រុសកណ្តាលរបស់ខ្លួន ហ៊ុន ម៉ានិត ឲ្យធ្វើជាប្រធានអង្គភាពព័ត៌មានសម្ងាត់យោធាដែលពោរពេញដោយឥទ្ធិពលនៃប្រទេសកម្ពុជា។

អ្នកផ្គត់ផ្គង់អគ្គីសនីក្នុងស្រុកដ៏ធំជាងគេបង្អស់ទីពីរនៅក្នុងប្រទេសកម្ពុជា ក្រុមហ៊ុនអគ្គីសនីឯកជនកម្ពុជា គឺជាការធ្វើពាណិជ្ជកម្មរួមរវាងគ្រួសារអ្នកមានស្តុកស្តម្ភចំនួនបីគឺ គ្រួសារត្រកូលហ៊ុនរួមជាមួយនិងក្រុមសាច់ញាតិរបស់អគ្គស្នងការនគរបាលមុនដែលមានគេខ្លាចច្រើនគឺលោក ហុកឡង់ឌី និង ព្រឹទ្ធសភារបស់គណៈបក្សប្រជាជនកម្ពុជាគឺលោក លីយ៉ុងផាត់។[80]ក្រុមហ៊ុនទាំងនេះដំណើរការស្ថានីយថាមពលអគ្គីសនីធំជាងគេបង្អស់ជិតទីក្រុងភ្នំពេញដោយលក់អគ្គីសនីដល់អ្នកចែកចាយថាមពលអគ្គីសនីរដ្ឋគឺអគ្គីសនីកម្ពុជា EDC។[81]ក្រុមហ៊ុននេះគឺជាក្រុមហ៊ុនដែលបានគ្រប់គ្រងរួមគ្នាដោយកូនលោកហ៊ុនសែនបីនាក់មានលោកហ៊ុនម៉ាណិត ហ៊ុនម៉ាណានិងហ៊ុនម៉ានី រួមទាំងឈ្មោះម៉ែនភក្តី ដែលជាប្រពន្ធមេម៉ាយរបស់លោកហុក ឡង់ឌីផងនិងត្រូវជាម្តាយក្មេករបស់ឈ្មោះហ៊ុនម៉ាណិតនិងសាច់ញាតិរបស់ព្រឹទ្ធសភាលោកលីយ៉ុងផាត់ផងដែរ។[82]លោកឌី វិជ្ជា ដែលជាស្វាមីរបស់នាងម៉ាណានិងត្រូវជាកូនប្រុសរបស់លោកហុកឡង់ឌីធ្លាប់ជាម្ចាស់ភាគហ៊ុននៅក្នុងក្រុមហ៊ុនរហូតទាល់តែគាត់បានលាឈប់ក្នុងឆ្នាំ 2013។[83]ដោយសារជាសមាជិកម្នាក់ក្នុងជួរទាហាន តំណែងនាយកក្រុមហ៊ុនរបស់លោកហ៊ុនម៉ាណិតគឺខុសច្បាប់ក្រោមច្បាប់របស់ប្រទេស កម្ពុជា។[84]

គ្រួសារត្រកូលហ៊ុនក៏មានទំនាក់ទំនងបណ្តាញជាមួយនិងក្រុមហ៊ុនប្រេងសាំងកម្ពុជាតេលាផងដែរ។ អ្នកស្រីប៊ុនរ៉ានីធ្លាប់ជាម្ចាស់ហ៊ុនរហូតទាល់តែគាត់បានលាឈប់ក្នុងកាលបរិច្ឆេទមួយមិនត្រូវបានបើកបង្ហាញជាសាធារណៈ។[85]ឈ្មោះ ម៉ឹងកុម្ភៈ ដែលជាស្វាមី មុនរបស់អ្នកស្រីហ៊ុនម៉ាណានិងត្រូវជាកូនប្រុសរបស់ប្រធានមន្ទីរផ្នែកភស្តុភារនិងហិរញ្ញវត្ថុក្រសួងការពារជាតិធ្លាប់ជានាយកចាត់ការទូទៅនៃក្រុមហ៊ុននេះមុនពេលដែលគាត់បានលែងលះគ្នាជាមួយនឹងអ្នកស្រីហ៊ុនម៉ាណា។[86]ក្នុងឆ្នាំ2004 សារព័ត៌មានក្នុងស្រុកបានរាយការណ៍ថាក្រុមហ៊ុនកម្ពុជាតេលាបានចុះកិច្ចព្រមព្រៀងក្នុងការផ្គត់ផ្គង់ប្រេងសាំងដល់ក្រសួងមហាផ្ទៃនិងហិរញ្ញវត្ថុ។[87]វាមិនច្បាស់ថាតើលោកស្រីប៊ុនរ៉ានីឬក៏លោកម៉ឹងកុម្ភៈជាអ្នកដែលលាលែងពីការពាក់ព័ន្ធក្នុងមុខជំនួញជាមួយនឹងក្រុមហ៊ុនត្រង់ចំណុចនេះ។ បន្ថែមលើសពីនេះ ក្រសួងពាណិជ្ជកម្មបានចុះឈ្មោះលោក សុខពុទ្ធីវុធថាជានាយកគ្រប់គ្រងក្រុមហ៊ុនតេលា Tela E & P។[88]មិនមានព័ត៌មានណាមួយទាល់តែសោះត្រូវបានបង្ហាញជាសាធារណៈចំពោះក្រុមហ៊ុនដែលនាំឲ្យអ្នកស៊ើបអង្កេតទាញសេចក្តីសន្និដ្ឋានថាវាគឺជាផ្នែកមួយនៃឬយ៉ាងហោចណាស់មានការជាប់ពាក់ព័ន្ធជាមួយនឹងក្រុមហ៊ុនកម្ពុជាតេលា។ យ៉ាងណាក៏ដោយ វាត្រូវបានបង្ហាញជាយូរមកហើយថាក្រុមហ៊ុនកម្ពុជាតេលាគឺជាកូនជីងរបស់គ្រួសារត្រកូលហ៊ុននិងថាម្ចាស់ភាគហ៊ុនដែលមានឈ្មោះក្នុងបញ្ជីគឺគ្មានអ្វីក្រៅតែពីជា "អ្នកឈរឈ្មោះនៅពីក្រោយ" ក្នុងនោះដើម្បីបិទបាំងពីការពាក់ព័ន្ធរបស់គ្រួសារត្រកូលហ៊ុន។[89]

## អំណាចគ្រប់គ្រងដ៏លើសលប់របស់គ្រួសារត្រកូលហ៊ុនលើវិស័យថាមពល

គោរម្យងារឬឈ្មោះជាផ្លូវការរបស់លោកហ៊ុនសែនបានក្លាយ កាន់តែវែងទៅៗដោយសារតែភាពជានាយករដ្ឋមន្ត្រីរបស់លោកបានបន្តទៅមុខ។ ចាប់តាំងពីឆ្នាំ2007 គាត់ត្រូវបានផ្តល់គោរម្យងារជាផ្លូវការដែលត្រូវបានគេស្គាល់ថា"សម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែន" ដែលអាចបកប្រែជាសាមញ្ញថាជា"ស្តេចវនាយករដ្ឋមន្ត្រីនិងមេបញ្ជាការយោធាជាន់ខ្ពស់ផុតលេខ"។

ក្នុងខែឧសភាឆ្នាំ2016 កាសែតដែលមានឈ្មោះថា Associated Press បានរាយការណ៍ថាខ្លួនត្រូវបានហៅទៅចូលរួមក្នុងកិច្ចប្រជុំមួយរបស់ក្រសួងព័ត៌មានប្រទេសកម្ពុជានិងត្រូវបានណែនាំថាអ្នកសារព័ត៌មានទាំងអស់ត្រូវតែប្រើប្រាស់គោរម្យងារពេញរបស់លោកហ៊ុនសែនចាប់ពីពេលនេះតទៅក្នុងបន្ទាត់មាតិកាបើកផ្តើមរបស់ពួកគេ។[90]

*កំណែដើមនៃរបាយការណ៍នេះបានបង្ហាញថា ក្រុមហ៊ុន Jaya Holding Limited ដែលជាក្រុមហ៊ុនកម្ពុជាដែលលោកស្រី ហ៊ុន ម៉ាណា ជាប្រធាន គឺជាបុត្រសម្ព័ន្ធនៃក្រុមហ៊ុនសឹង្ហបូរី ជាមួយឈ្មោះស្រដៀងគ្នា។ ចាប់តាំងពីការប្រកាសផ្សាយជាសាធារណៈ យើងបានចាប់អារម្មណ៍ឃើញថា តាមពិតទៅមិនមានការជាប់ទាក់ទងគ្នារវាងក្រុមហ៊ុនទាំងពីរនេះឡើយ។





ហ៊ុន ម៉ាណា និង ឌី វិជ្ជា។ រូបថតទទួលបានពីទំព័រហ្វេសប៊ុករបស់ ហ៊ុន ម៉ាណា។

# ការក្រឡេកមើលផ្ទៃក្នុងផលប័ត្រវិនិយោគរបស់ ហ៊ុនម៉ាណា

កូនស្រីច្បងរបស់លោកហ៊ុនសែនគឺអ្នកស្រីហ៊ុនម៉ាណាមានការកាន់កាប់មុខជំនួញច្រើនជាងគេបង្អស់ក្នុងចំណោមសមាជិកគ្រួសារនេះ ដោយមានប្រាក់ហ៊ុនក្នុង 22 ក្រុមហ៊ុនជាមួយនិងចំណែកទុនដែលបានចុះបញ្ជីដែលមានទឹកប្រាក់ចំនួន 66,659,168 ដុល្លាសហរដ្ឋ អាមេរិក។[91] តួលេខនេះហាក់ដូចជាខ្ពស់ខ្លាំងគួរឲ្យកត់សម្គាល់ដោយសារតែវាមិនបានរាប់បញ្ចូលនូវប្រាក់ទុនវិនិយោគរបស់ក្រុមហ៊ុនប្រាំដែលអង្គការគ្លូបបលវីតណែស មិនអាចស្វែងរកឃើញទិន្នន័យហិរញ្ញវត្ថុ។

ក្រុមហ៊ុន 18 ក្នុងចំណោមក្រុមហ៊ុន 22 គឺអ្នកស្រីម៉ាណាត្រូវបានចុះបញ្ជីថាជាប្រធានឬនាយកគ្រប់គ្រងក្រុមហ៊ុននោះ ដែលផ្តល់ លទ្ធភាពឲ្យគាត់អាចក្តោបក្តាប់គ្រប់គ្រងលើការសម្រេចចិត្តនានារបស់ក្រុមហ៊ុន។ ប្រាក់ហ៊ុនមុខជំនួញរបស់គាត់លាតសន្ធឹងលើវិស័យធំៗជាច្រើនរបស់ប្រទេសកម្ពុជា ក្នុងនោះរួមមានវិស័យថាមពល សំណង់ ទេសចរណ៍ សេវាកម្មហិរញ្ញវត្ថុនិងបនល្បែង។ [92]មីៗនេះគាត់កំពុងតែសំឡឹងមើលដើម្បីពង្រីកអាណាចក្រមុខជំនួញរបស់គាត់ហើយនិងកំពុងតែអនុវត្តការគាបសង្កត់ខ្លាំងទៅលើក្រុមហ៊ុនឯកជនក្នុងស្រុកដើម្បីទទួលបានភាគហ៊ុនរបស់គាត់ក្នុងនោះដែរ នេះដោយយោងតាមប្រភពដែលអាចគួរទុកចិត្តបានមួយនៅក្នុងប្រទេសកម្ពុជា។[93]

**ប្រព័ន្ធផ្សព្វផ្សាយ:** លោកស្រីម៉ាណាគឺជាអ្នកមានទ្រព្យនិងអំណាចខ្លាំងលើប្រព័ន្ធផ្សព្វផ្សាយមួយក្នុងចំណោមពីរក្នុងប្រទេសកម្ពុជាដែលការក្តោបក្តាប់ការគ្រប់គ្រងទូទាំងវិទ្យុ ទូរទស្សន៍និងសារព័ត៌មានទាំងអស់។[94] គាត់ដឹកនាំនិងមានចំណែកហ៊ុន%100លើក្រុមហ៊ុនប្រព័ន្ធផ្សព្វផ្សាយបាយ័នដែលមានប្រព័ន្ធខ្ពស់។[95] ក្រុមហ៊ុននេះធ្វើការផ្សាយតាមរយៈស្ថានីយទូរទស្សន៍ចំនួន3 គឺទូរទស្សន៍បាយ័ន បាយ័នព័ត៌មាន និង ETV ហើយក៏មានវិទ្យុបាយ័នដែលត្រូវបានចាត់ទុកថាជាវិទ្យុនាំពាក្យតំណាងឈានមុខគេរបស់គណៈបក្សប្រជាជនកម្ពុជាផងដែរ។[96] យោងតាមព័ត៌មានដែលទទួលបានដោយអង្គការគ្លូបបិលវីតណែសក្នុងឆ្នាំ 2010 ជាផ្នែកមួយនៃផែនការដែលត្រូវបានគេស្គាល់ថាជា*"វប្បធម៌ចែករំលែក"* ដែលក្នុងនោះក្រុមហ៊ុនឯកជននានាដែលជាអ្នកឧបត្ថម្ភអង្គភាពយោធាគឺទូរទស្សន៍និងវិទ្យុបាយ័នជាអ្នកឧបត្ថម្ភកងវរសេនាតូចពីរកងពល។[97] អ្នកស្រីម៉ាណាក៏ដឹកនាំនិងកាន់កាប់ទាំងស្រុងលើកាសែតកម្ពុជាថ្មីផងដែរ ដែលជាកាសែតមួយក្នុងចំណោមកាសែតជាច្រើនដែលមានអ្នកអានជាភាសាខ្មែរច្រើនជាងគេបំផុតក្នុងប្រទេសកម្ពុជាហើយក៏ត្រូវបានស្គាល់ផងដែរថាជាកាសែតគាំទ្រគណៈបក្សប្រជាជនកម្ពុជា។[98] លោកស្រីម៉ាណាក៏កាន់កាប់ក្រុមហ៊ុនទីផ្សារនិងគ្រប់គ្រងព្រឹត្តិការណ៍ Bayon CM Organizer ដែលគាត់គ្រប់គ្រងរួមជាមួយនិងក្រុមហ៊ុន CMO របស់ប្រទេសថៃ។[99] លោកស្រីម៉ាណាគឺជានាយកក្រុមហ៊ុននិងក៏កាន់កាប់ចំណែកហ៊ុន %25 នៃក្រុមហ៊ុននេះផងដែរ។[100]

**ការផ្សាយពាណិជ្ជកម្ម:** លោកស្រីម៉ាណាជាប្រធានក្រុមហ៊ុនផ្សព្វផ្សាយ Moon Media ដែលឯកទេសខាងផ្សាយពាណិជ្ជកម្មខាងក្រៅហើយនៅពីក្រោយចំណែកនៃផ្ទាំងផ្សព្វផ្សាយធំៗនិងទម្រង់នៃការផ្សាយពាណិជ្ជកម្មធំៗដែលអ្នកមើលឃើញទូទាំងប្រទេស។[101] បញ្ជីអតិថិជនរបស់ក្រុមហ៊ុនមានដល់ទៅក្រុមហ៊ុនម៉ាកល្បីៗធំៗជាច្រើនដូចជា Visa, Unilever, Proctor & Gamble, Honda និង Mango។[102] នេះក៏រាប់បញ្ចូលទាំងប្អូនស្រីរបស់លោកស្រីហ៊ុនម៉ាណាគឺឈ្មោះ ហ៊ុន ម៉ាលី ដែលជានាយកនិងម្ចាស់ភាគហ៊ុនផងដែរ។[103]

**ទេសចរណ៍:** លោកស្រីគឺជាម្ចាស់ភាគហ៊ុនក្នុងក្រុមហ៊ុន The Museum Company Ltd ដែលគ្រប់គ្រង**សារមន្ទីរជាតិអង្គរ** ក្នុងខេត្តសៀមរាបហើយត្រូវបានចុះក្នុងបញ្ជីក្រសួងពាណិជ្ជកម្មថាមានទុនទាំងអស់ 2.5 លានដុល្លាសហរដ្ឋអាមេរិក។[104] សារមន្ទីរនេះបើកបង្ហាញពីវត្ថុបុរាណដ៏មានតម្លៃបំផុតជាច្រើនរបស់ប្រទេសកម្ពុជាដែលយកមកពីប្រព័ន្ធដ៏ធំទូលាយនៃប្រាសាទបុរាណនានានិងជារៀងរាល់ឆ្នាំភាគរយដ៏ច្រើននៃចំនួនអ្នកចូលទស្សនាដែលមកខេត្តសៀមរាបក្នុងមួយលានអ្នកបង់ប្រាក់ចំនួន$12 ដុល្លាសហរដ្ឋអាមេរិកក្នុងការចូលទស្សនា។[105] លោកស្រីម៉ាណាក៏ជានាយកក្រុមហ៊ុន MLM Resort Group ផងដែរ ដែលមិនមានព័ត៌មានបន្ថែមចំពោះក្រុមហ៊ុននេះទេ។[106]

**នេះគឺជាទស្សនៈទូទៅរបស់ក្រុមហ៊ុនជាតិ និងអន្តរជាតិដែល ហ៊ុន ម៉ាណា ទទួលបានផលប្រយោជន៍ ឬមានទំនាក់ទំនងជាមួយ៖**





ប្រព័ន្ធផ្សព្វផ្សាយ មូន ត្រូវបានគ្រប់គ្រងដោយ ហ៊ុន ម៉ាណា និងបង្កើតបញ្ជីអតិថិជនដ៏គួរឲ្យកោតសរសើរ ដែលរួមមានវីសា យូនីលីវើ និងស្រាបៀរថៃហ្គឺរ។

**អាកាសចរណ៍:** លោកស្រីម៉ាណាត្រូវបានចុះឈ្មោះក្នុងបញ្ជីថាជានាយកនៃក្រុមហ៊ុនអាកាសចរណ៍ 3 ដែលបានចុះបញ្ជីរួចរាល់មានដូចជា Helistar, Star Aviation និង Star Airline។[107] មិនមានព័ត៌មានណាមួយត្រូវបានបង្ហាញទេសម្រាប់ក្រុមហ៊ុនក្រោយពីរនេះ ក៏ប៉ុន្តែក្រុមហ៊ុន Helistar ត្រូវបានគេស្គាល់ច្រើនថាជាក្រុមហ៊ុនផ្តល់ការហោះហើរចំពោះអ្នកទេសចរជុំវិញប្រាសាទអង្គរដែលមានតម្លៃរហូតដល់ទៅ US5000$ ដុល្លាសហរដ្ឋអាមេរិក។[108] ការហោះហើរចេញពីមូលដ្ឋានកងកម្លាំងយោធាក្នុងក្រុងភ្នំពេញនិងសៀមរាប ក្រុមហ៊ុននេះក៏មានសេវាកម្មលើការជួលឧទ្ធម្ភាគចក្រហោះហើរសម្រាប់មន្ត្រីរដ្ឋាភិបាល ជនលំដាប់ VIPs ការហោះស្ទង់មើកលើដីសម្បទានកសិកម្មនិងការរុករករ៉ែផងដែរ។[109]

**រោងចក្រផលិត: ក្រុមហ៊ុន** NVC Corporation ដែលមានលោកស្រីម៉ាណាជាប្រធានគឺជាក្រុមហ៊ុនផលិតអាហារនិងភេសជ្ជៈដែលផលិត**ទឹកបរិសុទ្ធវីតាល់** Vital Premium Water ជាម៉ាកទឹកបរិសុទ្ធប្រកដបដែលឈានមុខគេមួយនៅក្នុងប្រទេសកម្ពុជា។110 គេហទំព័ររបស់ក្រុមហ៊ុនទឹកបរិសុទ្ធវីតាល់បានបញ្ជាក់ថា "*ទឹកនេះគឺជាផលិតផលជាតិតែមួយគត់ដែលត្រូវបានទទួលស្គាល់ជាដៃគូរផ្លូវការសម្រាប់ប្រើប្រាស់ក្នុងវេទិកាទេសចរអាស៊ានក្នុងឆ្នាំ 2011 ក្នុងប្រទេសកម្ពុជា។ ក្រសួងទេសចរក៏ណែនាំឲ្យមានការប្រើប្រាស់ទឹកនេះជាផ្លូវការសម្រាប់ក្នុងកម្មវិធីផ្សេងក្នុងថ្នាក់ជាតិនិងថ្នាក់អន្តរជាត់នានាផងដែរ*"។[111] មហ៊ុននេះក៏មានចែកចាយសិទ្ធិលក់បន្តដែលមានការចុះបញ្ជីជាមួយក្រុមហ៊ុនច្រើនជាង30ដែលជាកម្មសិទ្ធិរបស់ព្រឹទ្ធសភាដ៏មានអំណាចរបស់គណៈបក្សប្រជាជនកម្ពុជាគឺលោក ឡៅម៉េងឃិនដែលភរិយារបស់គាត់គឺអ្នកស្រី ចឹង សុភាព (ដែលត្រូវបានគេស្គាល់ថាយាយភូ) និងសមាជិកគ្រួសារនានារបស់ពួកគេ។[112] អ្នកទាំងពីរនាក់នេះក្តោបក្តាប់គ្រប់គ្រងក្រុមហ៊ុនស៊ូកាគូ Shukaku Inc និងភាភីម៉េច Pheapimex ដែលធ្លាប់បានទទួលខុសត្រូវចំពោះការកាប់ឈើខុសច្បាប់ដ៏សន្ធឹកសន្ធាប់និងការទន្ទ្រានរំលោភយកដីធ្លី ដែលបានធ្វើឲ្យប្រជាជនរាប់ពាន់គ្រួសារត្រូវ ផ្លាស់ប្តូរទីលំនៅ។[113]

**ហិរញ្ញវត្ថុ:** លោកស្រីម៉ាណាមានប្រាក់ទុនក្នុងក្រុមហ៊ុនចំនួនយ៉ាងហោចណាស់2 ក្នុងវិស័យហិរញ្ញវត្ថុ។ គាត់គឺជានាយកនិងជាម្ចាស់ភាគហ៊ុននៃ**ក្រុមហ៊ុនវិនិយោគរ៉ូយ៉ាល់គ្រុប** ដែលត្រូវបានគ្រប់គ្រងដោយលោកគិតម៉េង ជាឧកញ៉ាខាងជំនួញដែលមានកេរ្តិ៍ឈ្មោះល្បីរន្ទឺជាងគេមិនអាចប្រកែកបានដោយមានប្រាក់ហ៊ុនច្រើនក្នុងវិស័យធនាគារកសិកម្ម, វារីអគ្គីសនី ប្រព័ន្ធផ្សព្វផ្សាយ អចលនទ្រព្យនិងទូរគមនាគម ហើយត្រូវបានគេដឹងថាមានការពាក់ព័ន្ធក្នុងការរំលោភយកដីធ្លីនិងការកាប់ឈើខុសច្បាប់។[114] លោកស្រីម៉ាណាក៏ត្រូវបានចុះបញ្ជីក្នុងទិន្នន័យក្រសួងពាណិជ្ជកម្មផងដែរថាជា'អ្នកតំណាង'ឲ្យក្រុមហ៊ុន NH Holding ដែលមើលទៅទំនងដូចជាមានការចូលរួមជាមួយនិងក្រុមហ៊ុនសំណង់ 'បងប្អូន 5 នាក់' ដែលមានបណ្តាញទំនាក់ទំនងជាមួយនឹងគ្រួសារព្រឹទ្ធសភាមកពីគណៈបក្សប្រជាជនលោក ឡៅម៉េងឃិន។[115] លោកស្រីក៏ជានាយកក្រុមហ៊ុនវិនិយោគ Ocasis Cambo Investment Group និងក្រុមហ៊ុន Ocasis Cambo Investment ដែលបានចុះបញ្ជីផងដែរ។[116]

**ទូរគមនាគមន៍:** តាមរយៈការក្តោបក្តាប់ក្រុមហ៊ុន NH
លោកស្រីម៉ាណាមានចំណែកភាគហ៊ុន 6 ភាគរយក្នុងក្រុមហ៊ុន**វៀតថែល(កម្ពុជា)** ដែលគ្រប់គ្រងផ្នែកខាងផ្តល់សេវកម្មទូរស័ព្ទដៃដ៏ធំជាងគេបង្អស់មួយក្នុងប្រទេសកម្ពុជាឈ្មោះថាមិត្តហ្វូន។[117] ក្រុមហ៊ុន**វៀតថែល(កម្ពុជា)**គឺជាសាខានៃក្រុមហ៊ុនបណ្តាញប្រតិបត្តការទូរស័ព្ទដៃដ៏ធំជាងគេរបស់វៀតណាមឈ្មោះថា ក្រុមហ៊ុន**វៀតថែលគ្រុប** ដែលជាសហគ្រាសគ្រប់គ្រងដោយរដ្ឋទាំងស្រុងមួយត្រូវបានដំណើរការដោយក្រសួងការពារជាតិរបស់ប្រទេស។[118] មានការចូលហ៊ុនជាមួយនឹងលោកស្រីម៉ាណាក្នុងក្រុមហ៊ុនវៀតថែល(កម្ពុជា) និងដោយការបន្ថែមទំនាក់ទំនងក្រុមហ៊ុនជាមួយនឹងផ្នែកយោធាគឺលោក តៅ តឿន ដែលត្រូវជាភរិយារបស់លោករដ្ឋមន្ត្រីក្រសួងការពារជាតិគឺលោក ទាបាញ់។[119] ក្នុងឆ្នាំ 2010 លោកហ៊ុនសែនបានអនុម័តគាំទ្រជាសាធារណៈក្រុមហ៊ុនមិត្តហ្វូននិងបានណែនាំឲ្យមន្ត្រីយោធាកម្ពុជាទាំងអស់ប្រើប្រាស់សេវកម្មក្រុមហ៊ុននេះ។[120] ក្នុងវិស័យទូរគមនាគមន៍នេះផងដែរ លោកស្រីម៉ាណាទំនងដូចជាមានការចូលរួមគ្នាជាមួយនិងក្រុមហ៊ុន **ត្រាហ្គុនរ៉ូយ៉ាល់គ្រុប** Dragon Royal Group តាមរយៈតំណែងនាយករបស់គាត់ចំពោះក្រុមហ៊ុនសារទូរគមនាគមន៍ **ត្រាហ្គុនរ៉ូយ៉ាល់តេឡេខម** Dragon Royal Telecom ដែលបានចុះបញ្ជីចំណែកទុនចំនួន US2$ លានដុល្លាសហរដ្ឋអាមេរិក។[121] ក្រុមហ៊ុននេះកាន់កាប់សណ្ឋាគារប្រណិតនិងខន់ដូក្នុងខេត្តសៀមរាប ហើយមានគម្រោងនឹងពង្រីកទៅជាក្រុមហ៊ុនឱសថ អចលនទ្រព្យ ប្រេងសាំងនិងធនធានធម្មជាតិផ្សេងៗទៀត។[122] លោកស្រីម៉ាណាក៏ជានាយកនិងម្ចាស់ភាគហ៊ុននៃក្រុមហ៊ុន **ខេថុងហ៊្វួតតេឡេខម** K Thong Huot Telecom ផងដែរដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ 2002 ដើម្បីចែកចាយទូរស័ព្ទម៉ាកណូគៀរ Nokia នៅក្នុងប្រទេសកម្ពុជា។[123] ក្រុមហ៊ុននេះក៏ជាដៃគូរជំនួញក្នុងស្រុកនៃក្រុមហ៊ុនកុំព្យូទ័រម៉ាក Lenovo-IBM ផងដែរ ហើយក៏មានអាជ្ញាប័ណ្ណចែកចាយពិសេសសម្រាប់ផលិតផលម៉ាក Pioneer និង Electrolux ផងដែរ។[124]

ជាមួយនិងសមាជិកគ្រួសារបីនាក់ផ្សេងទៀតរបស់គាត់ និងសាច់ញាតិពីរនាក់ទៀតរបស់ព្រឹទ្ធសភាលោក លី យ៉ុងផាត់  ម៉ាណាជានាយកនិងជាម្ចាស់ភាគហ៊ុនក្នុងក្រុមហ៊ុនអគ្គីសនីឯកជនកម្ពុជា Cambodia Electricity Private ផងដែរ ដែលជាក្រុមហ៊ុនផ្គត់ផ្គង់អគ្គីសនីក្នុងស្រុកដ៏ធំជាងគេបង្អស់ទីពីររបស់ប្រទេសកម្ពុជា។[125] លោកលីយ៉ុងផាត់និងភរិយារបស់លោកឈ្មោះ គីមហ៊ាង មានឈ្មោះល្បីមិនល្អក្នុងការកាន់កាប់ក្រុមហ៊ុនស្ករសដែលបានប្រព្រឹត្តអំពើរំលោភសិទ្ធិមនុស្ស ក្នុងនោះរួមមានការបណ្តេញចេញដោយបង្ខំឃោឃៅនិងការរំលោភយកដីធ្លី ពលកម្មកុមារនិងការប្រើប្រាស់កងកម្លាំងប្រដាប់អាវុធដើម្បីគំរាមគំហែងអ្នកស្រុក ភូមិ។[126] នៅក្នុងលិខិតមកកាន់អង្គការ គ្លូបប៊ិលវីតណែសចុះថ្ងៃទី 25 ខែមករា ឆ្នាំ 2016 លោកលីយ៉ុងផាត់និងអ្នកស្រីហ៊ាងបានបដិសេធរាល់ការចោទប្រកាន់ដែលបានធ្វើឡើងក្នុងរបាយការណ៍នេះលើរូបគាត់ទាំងពីរនាក់ហើយនិងក្រុមហ៊ុនរបស់ពួកគេគឺក្រុមហ៊ុន LYP Group និងក្រុមហ៊ុនស្ករសក្នុងខេត្តកំពង់ស្ពឺ។

**សំណង់:** លោកស្រីម៉ាណាជានាយកក្រុមហ៊ុន NVN Corporation ដែលជាក្រុមហ៊ុនសំណង់និងត្រូវបានចុះបញ្ជីថាមានទុនចំនួន US0.5$ លានដុល្លា។ គាត់ក៏មានទុនបន្ថែមក្នុងវិស័យសំណង់តាមរយៈក្រុមហ៊ុន NH Holding ដែរ។[127]ក្រុមហ៊ុនទាំងពីរទំនងដូចជាមានបណ្តាញទំនាក់ទំនងរឹងមាំខ្លាំងជាមួយនិងគ្រួសារព្រឹទ្ធសភាលោក ឡៅម៉េង គិនដែលមកពីគណៈបក្សប្រជាជនកម្ពុជា។[128]លោកស្រីម៉ាណាក៏ជានាយកអរគីដេវីឡា3 Orkide Villa 3ផងដែរ។[129] ក្រសួងពាណិជ្ជកម្មចុះបញ្ជីក្រុមហ៊ុនដែលមានឈ្មោះស្រដៀងនេះគឺអរគីដេវីឡា Orkide Villa ដែលត្រូវបានដឹកនាំដោយលោកឧកញ៉ា ខៀវ ស ស៊ីលាភ ដែលមានខ្សែរបណ្តាញទំនាក់ទំនងជំនួញជាច្រើនជាមួយនឹង គ្រួសារត្រកូលហ៊ុន។[130] ក្រុមហ៊ុនទាំងពីរត្រូវបានចុះបញ្ជីក្នុងអាសយដ្ឋានដូចគ្នាតែមួយ។[131] ក្នុងខែវិច្ឆិកាឆ្នាំ 2015 ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកបានពណ៌នាអរគីដេវីឡាថាជា *"អ្នកអភិវឌ្ឍន៍ដែលមានការរីកចម្រើនលឿនជាងគេបង្អស់"* មួយរបស់កម្ពុជាបន្ទាប់ពីលោក ស៊ីលាភបានប្រកាសជាសាធារណៈថាក្រុមហ៊ុននឹងធ្វើការសាងសង់ខន់ដូដែលមានទំហំទឹកប្រាក់ចំនួន 350$ លានដុល្លាសហរដ្ឋអាមេរិកនិងគម្រោងផ្សារទំនើបដែលនឹងគ្របដណ្តប់លើផ្ទៃដីចំនួន 36 ហិកតាក្នុងតំបន់ក្រុងភ្នំពេញ។[132]

ក្នុងខែមករាឆ្នាំ 2016 អង្គការគ្លូប៊ិលវីតណែស បានទំនាក់ទំនងទៅលោកស្រី ហ៊ុនម៉ាណានិងមនុស្សផ្សេងទៀតរួមទាំងក្រុមហ៊ុនដែលបានលើកឡើងក្នុងជំពូកនេះលើកលែងតែលោក ម៉ឹង កុម្ភៈដែលមិនអាចទំនាក់ទំនងបាន។ នៅក្នុងលិខិតរបស់យើងយើងបានស្នើរសុំការផ្តល់យោបល់ទាក់ទងទៅនឹងភស្តុតាងដែលបានលម្អិតខាងលើ។ មានតែលោក សុខ ពុទ្ធីវុធទេដែលបានឆ្លើយតប។ សារអេឡិច ត្រូនិចរបស់គាត់មានបង្ហាញនៅលើទំព័រ 20។



អង្គភាពល្បាតព្រៃឈើប្រើប្រាស់ឧទ្ធម្ភាគចក្រដែលជារបស់ហេលីស្តារ ដែលត្រូវបានគ្រប់គ្រងដោយ ហ៊ុន ម៉ាណា។ រូបថតទទួលបានពីទំព័រហ្វេសប៊ុករបស់ Wildlife Alliance នៅខែមីនា ឆ្នាំ 2016។



កុមារដែលធ្វើការនៅក្នុងចំការស្ករសដែលត្រូវបានកាន់កាប់ជាកម្មសិទ្ធិដោយទីប្រឹក្សាផ្នែកសេដ្ឋកិច្ចពិសេសរបស់ ហ៊ុន សែន និងសមាជិកព្រឹទ្ធសភាពរបស់ CPP ដែលពោរពេញដោយអំណាចគឺលោក លី យ៉ុងផាត់។

## ការគាំទ្រនយោបាយដោយងារជាឧកញ៉ា

ជាប្រពៃណីសម្រាប់អ្នកដែលចូលរួមចំណែកដល់ទំនិញ និងសេវាកម្មសាធារណៈងារ "ឧកញ៉ា" បច្ចុប្បន្នត្រូវបានប្រើប្រាស់សម្រាប់អ្នកជំនួញដែលបានចូលរួមចំណែកជាវិភាគទានជាប្រាក់ចំនួនយ៉ាងតិច 100,000 ដុល្លារអាមេរិកដល់គណបក្សរបស់លោក ហ៊ុន សែន។ បន្ទាប់មក ពួកគេនឹងបង្កើនឱកាសរក្សាកិច្ចសន្យាឬអាជ្ញាប័ណ្ណដែលអាចផ្តល់ប្រាក់ចំណេញខ្ពស់ ក្នុងការធ្វើនិស្សារណកម្មលើធនធានធម្មជាតិ។ គិតត្រឹមឆ្នាំ 2014មានឧកញ៉ាយ៉ាងហោចណាស់ 700 នាក់ បើប្រៀបធៀបទៅនឹងមួយទសវត្សមុនមានត្រឹមតែ 20 នាក់ប៉ុណ្ណោះ។[133] នេះបញ្ជាក់ពីខ្សែកម្រិតព្រំដែនមិនច្បាស់លាស់ដែលមានការកើនឡើងរវាងវិស័យស្ថាប័នរដ្ឋនិងឯកជនក៏ដូចជាការរីកលូតលាស់លឿនរហ័សនៃខ្សែបណ្តាញអំណាចចាត់តាំងរបស់លោកហ៊ុនសែន។ ឧកញ៉ាជាច្រើន ត្រូវបានរកឃើញថាមានជាប់ពាក់ព័ន្ធនឹងការរំលោភសិទ្ធិមនុស្សនិងបង្ករឲ្យមានការបំផ្លិចបំផ្លាញបរិស្ថានដោយនិទ្ទណ្ឌភាព។

អង្គការគ្លូបប៊ិលវីតណែសជម្រុញឲ្យរដ្ឋាភិបាលកម្ពុជាដហូតវិញនូវងារជាឧកញ៉ាកិត្តយសចំពោះអ្នក ត្រូវបានរកឃើញថាមានការរំលោភច្បាប់ប្រទេសកម្ពុជាឬបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិហើយបញ្ឈប់លែងឲ្យមានប្រព័ន្ធដែលមានការផ្តល់គោរម្យងារជាថ្នូរទៅនឹងការបរិច្ចាកប្រាក់ 100,000 ដុល្លាសហរដ្ឋអាមេរិក។

ក្រាហ្វិចព័ត៌មានខាងក្រោមបង្ហាញពីក្រុមហ៊ុនទាំងអស់របស់ប្រទេសកម្ពុជាដែលសមាជិកត្រកូលហ៊ុនមានចំណែកភាគហ៊ុនក្នុងនោះដូចបានបង្ហាញរួចមកហើយនៅពេលដែលមានការស្រាវជ្រាវពី ទិញយកមកគ្រប់គ្រងដោយប្រទូស្តរ៉ាយ។ សម្រាប់ព័ត៌មានលម្អិតចំពោះការ ក្តោបក្តាប់របស់ពួកគេ សូមមើលឧបសម្ព័ន្ធ 1 នៅលើទំព័រ 33។



# ទំនាក់ទំនងគ្រួសារត្រកូល ហ៊ុនចំពោះផលិតផលម៉ាកល្បីៗអន្តរជាតិ

ប្រទេសកម្ពុជាធ្លាប់បានទទួលកំណើនសេដ្ឋកិច្ចលឿនរហ័សរយៈពេលពីរទសវត្សចុងក្រោយនេះហើយកំពុងតែបង្កើនចំនួនក្រុមហ៊ុននិងអ្នកវិនិយោគអន្តរជាតិដែលបានចូលមកក្នុងទីផ្សារកម្ពុជាយ៉ាងច្រើន ដែលបានទាក់ទាញមួយផ្នែកដោយនិយតកម្មការិយាធិបតេយ្យតិចតួចនិងកម្លាំងពលកម្មទាបរបស់ប្រទេសកម្ពុជា។[134] ក្នុងឆ្នាំ 2015 ប្រទេសអង់គ្លេសធ្លាប់ជាអ្នកវិនិយោគទុបបរទេសធំជាងគេទីពីរក្នុងប្រទេស កម្ពុជាបន្ទាប់ពីប្រទេសចិន។[135] សហរដ្ឋអាមេរិកគឺជាដៃគូរពាណិជ្ជកម្មនិងជាទីផ្សារនាំចេញដ៏ធំជាងគេបង្អស់របស់ប្រទេស កម្ពុជាហើយពាណិជ្ជកម្មរវាងប្រទេសទាំងពីរមានតម្លៃសរុបប្រមាណជា 3 កោដិលានដុល្លាសហរដ្ឋអាមេរិកក្នុងមួយឆ្នាំ។[136]ប្រទេសទាំងពីរថ្មីៗនេះកំពុងតែចចារគ្នាលើកិច្ចព្រមព្រៀងវិនិយោគទ្វេភាគីក្នុងគោលដៅជំរុញលើកទឹកចិត្តឲ្យមានការវិនិយោគបន្ថែមពីសំណាក់សហរដ្ឋអាមេរិកមកក្នុងប្រទេស។[137]

គ្រួសារត្រកូលហ៊ុនគឺជាអ្នកបើកផ្លូវដ៏ចំបងឲ្យមានលំហូរចូលទុនវិនិយោគបរទេសចូលមកក្នុងប្រទេស កម្ពុជានិងបានព្យាយាមបង្កើតទំនាក់ទំនងជំនួញជាមួយនឹងក្រុមហ៊ុនផលិតផលម៉ាកល្បីៗធំៗជាច្រើន។ ទំនាក់ទំនងនេះរួមបញ្ចូលទាំងភាពជាដៃគូរផ្លូវការ ការទិញសិទ្ធិលក់បន្តពីឈ្មោះឬក្រុមហ៊ុនម្ចាស់ដើម កិច្ចព្រមព្រៀងចែកចាយជាពិសេសនិងទំនាក់ទំនងជាមួយអតិថិជន។ ក្រុមហ៊ុនអន្តរជាតិទាំងនេះមិនបានដឹងច្បាស់ចំពោះឬមិនព្រួយបារម្ភពីការជ្រើសរើសដៃគូរជំនួញរបស់ពួកគេ ដែលទំនាក់ទំនងគ្រួសារជាមួយលោក ហ៊ុនសែនគួរតែត្រូវដាស់តឿនពីគ្រោះថ្នាក់ទាក់ទងទៅនឹងការប្រថុយប្រថានខ្ពស់នៃអំពើរពុក រលួយ។

ខាងក្រោមនេះគឺជាបណ្តាញទំនាក់ទំនងគ្រួសារត្រកូលហ៊ុនជាមួយនិងក្រុមហ៊ុនផលិតផលម៉ាកល្បីៗអន្តរជាតិដែលអង្គការគ្លូបប៊លវីតណែសអាចកត់សម្គាល់ឃើញវាទំនងដូចជាមានច្រើនជាងនេះទៅទៀត។

ឈ្មោះសុខ សុភ័ក្រ ភរិយារបស់ក្មួយប្រុសលោកហ៊ុនសែនឈ្មោះ សៀង ហេង មានទំនាក់ទំនងជាមួយនឹងក្រុមហ៊ុនអេឡិចត្រូនិកយក្សពិភពលោកពីរ។ គាត់ជានាយិកាក្រុមហ៊ុនអាយវ័ន iOne,ជាក្រុមហ៊ុនចែកចាយលក់រាយផលិតផលឈានមុខម៉ាក Apple នៅក្នុងប្រទេសកម្ពុជា ហើយក៏ជានាយកក្រុមហ៊ុន Cemtes ជាក្រុមហ៊ុនដែលមានគេហទំព័ររបស់ខ្លួននិយាយថាជា 'ភ្នាក់ងារដែលត្រូវបានទទួលស្គាល់' របស់ប្រទេសកម្ពុជាសម្រាប់ផលិតផលម៉ាកកាណុង Canon។[138]។ឈ្មោះ ពេជ្រ ច័ន្ទមុន្នី ដែលជាភរិយារបស់លោកហ៊ុន ម៉ាណែត ជានាយកក្រុមហ៊ុន G Gear ដែលជាក្រុមហ៊ុនផ្គត់ផ្គង់និងចែកចាយបន្តជាពិសេសនូវផលិតផលនានាដែលផលិតដោយក្រុមហ៊ុនអេឡិចត្រូនិចចំរុះជាតិសាសន៍នៃប្រទេសកូរ៉េខាងត្បូងគឺក្រុមហ៊ុន LG Electronics។[139]

ក្នុងវិស័យអេឡិចត្រូនិចនេះផងដែរ ឈ្មោះ ហ៊ុនម៉ាណា ដែលជានាយកនិងជាម្ចាស់ភាគហ៊ុននៃក្រុមហ៊ុន ទូរគមនាគមន៍ ខេថុងហួត ជាដៃគូរនៃក្រុមហ៊ុនផលិតកុំព្យុទ័រម៉ាក ឡេណូវ៉ូអាយប៊ីអឹម Lenovo-IBM ដែលអះអាងថាមានសិទ្ធិចែកចាយពិសេសសម្រាប់ផលិតផលម៉ាក Electrolux និង Pioneer ក្នុងប្រទេសកម្ពុជា និងផលិតផលទូរស័ព្ទដៃម៉ាកណូគៀ Nokia ក្នុងប្រទេសកម្ពុជានិងប្រទេសឡាវ។[140] ណូគៀត្រូវបានទិញដោយក្រុមហ៊ុនMircrosoft នៅក្នុងឆ្នាំ2014។[141]

លោកស្រី ហ៊ុនម៉ាណា ជានាយកក្រុមហ៊ុន Moon Media ដែលក្នុងនោះប្អូនស្រីរបស់គាត់ឈ្មោះ ហ៊ុន ម៉ាលីគឺជាម្ចាស់ ភាគហ៊ុន។[142] ដោយត្រូវបានចុះបញ្ជីថាជាក្រុមហ៊ុន 'ផ្សព្វផ្សាយពាណិជ្ជកម្ម Moon Advertising' ក្រុមហ៊ុននេះមានឯកទេសខាងផ្សព្វផ្សាយរកទីផ្សារខាងក្រៅនិងអួតអាងពីការមានបញ្ជីអតិថិជនដែលមានឈ្មោះល្បីធំៗអន្តរជាតិដូចជា Visa, Unilever, Proctor & Gamble, Honda, Mango, and ស្រាបៀរ Tiger ។[143]

ខណ:ដែលឈ្មោះ ហ៊ុន ម៉ាលី គឺជានាយកមជ្ឈមណ្ឌល TK Avenue ដែលជាផ្សារទំនើបលក់ទំនិញដែលមានតម្លៃថ្លៃក្នុងទីក្រុងភ្នំពេញ។[144] ដែលរួមមានហាងដូចជា Mango, Zara និង Adidas ក្រុមហ៊ុនចំណុះរបស់ប្រទេសសឹង្ហបូរីដូចជា Guardian Pharmacy, Aussino furniture, Shiseido cosmetics, Pedro Footwear and Accessories និង Samsung។[145]

ស្វាមីរបស់គាត់ លោក សុខពុទ្ធីវុធ ជានាយកប្រតិបត្តិនៃក្រុមហ៊ុន សូម៉ាគ្រុប។[146] ក្នុងឆ្នាំ 2012 ក្រុមហ៊ុនថាមពលសូម៉ា បានចុះកិច្ច ព្រមព្រៀងថាមពលជីវ:ឧស្ម័នដែលមានតម្លៃចំនួន 3 លានដុល្លាសហរដ្ឋ អាមេរិកជាមួយនិងក្រុមហ៊ុនចំរុះដ៏ធំរបស់សហរដ្ឋអាមេរិកគឺក្រុមហ៊ុន General Electric (GE)។[147] ទស្សនាវដ្តី Forbes ចុះបញ្ជីក្រុមហ៊ុន GE ថាជាក្រុមហ៊ុនផលិតផលល្បីដែលមានតម្លៃខ្ពស់ជាងគេបង្អស់លំដាប់ពិភពលោកធំទី10 ហើយ ban ដាក់ការលក់ប្រចាំឆ្នាំរបស់ពួកគេក្នុងតម្លៃ 122កោដិលានដុល្លាសហរដ្ឋអាមេរិក។[148]

ក្មួយស្រីរបស់លោក ហ៊ុនសែន ឈ្មោះ ហ៊ុនគឹមឡេង ក៏មានទំនាក់ទំនងរឹងមាំជាមួយនឹងក្រុមហ៊ុនផលិតផលម៉ាកល្បីៗអន្តរជាតិផង ដែរ។ គាត់គឺជានាយកក្រុមហ៊ុនកាហ្វេ Gloria Jean's Coffees ក្នុងប្រទេសកម្ពុជា ហើយក៏ត្រូវបានចុះបញ្ជីជានាយក គណ:នាយក និងមានភាគហ៊ុន%75ក្នុងក្រុមហ៊ុន Hard Rock Caf's សាខាប្រទេសកម្ពុជា។[149]។ក្រុមហ៊ុនវិនិយោគចំរុះដ៏ធំទូទាំងពិភពលោករបស់អ្នកស្រី គឹមឡេងបានអះអាងនៅលើគេហទំព័ររបស់ខ្លួនថាបានជួយនាំមកប្រទេសកម្ពុជានូវហាងអាហារបែបជប៉ុន Yoshinoya និងភោជនីយដ្ឋានចក្រភពចិន Emperors of China Restaurant។[150]



ហ៊ុន គឹមឡេង។
រូបថតទទួលបានពីគេហទំព័រ Prae Legal។

ឈ្មោះ ពេជ្រ ច័ន្ទមុន្នី ដែលជាភរិយារបស់លោក ហ៊ុន ម៉ាណែត ត្រូវបានចុះបញ្ជីថាជានាយកក្រុមហ៊ុនចំនួន 7 ដោយក្រសួងពាណិជ្ជកម្ម ហើយក៏ជានាយកនិងម្ចាស់ភាគហ៊ុននៃក្រុមហ៊ុនគ្រប់គ្រងយីហោម៉ាកល្បីៗដែលទិញសិទ្ធិអាហារនិងភេសជ្ជ:ផងដែរ។[151] មកទល់ពេលនេះក្រុម ហ៊ុនបាននាំមកនូវក្រុមហ៊ុនតែគុជបែបចិនតៃវ៉ាន់ឈ្មោះ Chatime, myBurgerLab, ដែលជាក្រុមហ៊ុនរបស់ប្រទេសម៉ាឡេស៊ី និងគុយទាវទូក ដែលមកពីប្រទេសថៃ។[152] គេហទំព័ររបស់ខ្លួនបានរាយនាមក្រុមហ៊ុនដៃគូររបស់ខ្លួនដែលមានដូចជាក្រុមហ៊ុនស្រាបៀហៃនេនីគែន Heineken Beer ក៏ដូចជាក្រុមហ៊ុនជាច្រើនទៀតដែលជាប់ពាក់ព័ន្ធទៅនឹងគ្រួសារត្រកូលហ៊ុន។[153] ឈ្មោះ ច័ន្ទមុន្នី ក៏ត្រូវបានចុះបញ្ជីថាជានាយកនៃរោងភាពយន្តឡេជែនស៊ីនីម៉ា Legend Cinema ផងដែរដែលជារោងភាពយន្តដំបូងទីមួយទទួលបានសិទ្ធិក្នុងការបញ្ចាំងខ្សែភាពយន្តខ្នាតធំបែបហូលីវូតនៅក្នុងប្រទេសកម្ពុជា។[154]

ឈ្មោះ ហ៊ុន សែនី ដែលជាប្អូនស្រីរបស់លោកនាយករដ្ឋមន្ត្រីហ៊ុនសែន គឺជានាយកក្រុមហ៊ុនបោះដុំ UNT[155] ដែលនាំចូលនូវផលិតផលម៉ាកល្បីធំៗជាច្រើនមកក្នុងប្រទេសកម្ពុជាដែលរួមមានស្រោមអនាម័យម៉ាក Durex, កាហ្វេ Nescafe Gold និងការ៉េម Nestle ។[156] គាត់ក៏មានភាគហ៊ុន %50 ក្នុងក្រុមហ៊ុនវិនិយោគ អ៊ែតវូត Attwood Investment Group* ដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនិងក្រុមហ៊ុននាំចេញនាំចូលអ៊ែតវូត ដែលជាក្រុមហ៊ុនចែកចាយភេសជ្ជះគ្រឿងស្រវឹងដែលមានតម្លៃថ្លៃច្រើនជាងគេបង្អស់នៅក្នុងប្រទេសកម្ពុជា។[157] ក្រុមហ៊ុនអ៊ែតវូតបាននាំចូលមកនូវទំនិញដាក់តាំងជាច្រើនដូចជាស្រាដែលមានម៉ាកល្បីលើអន្តរជាតិមកក្នុងប្រទេសកម្ពុជានិងមានសិទ្ធិចែកចាយបន្តពិសេសសម្រាប់ស្រាម៉ាកចន្នីវកឃើរ Johnnie Walker, Hennesey និងស្រាបៀរ Corona ។[158]

ឈ្មោះ សេង ឃាង ដែលជាប្រពន្ធមុនរបស់បងប្អូនជីដូនមួយលោកហ៊ុនសែនឈ្មោះ ឌីចូច និងដែលមានទំនាក់ទំនងស្និទ្ធនឹងអ្នកស្រី ប៊ុន រ៉ានី ត្រូវបានចុះបញ្ជីថាជានាយកនៃក្រុមហ៊ុនរោងចក្រផលិតសំលៀកបំពាក់ឈ្មោះ Grand Harvest International ដែលជាសាខាក្រុមហ៊ុនដែលមានមូលដ្ឋានក្នុងទីក្រុងហុងកុងឈ្មោះសហគ្រាស GHI Ltd ដែលផលិតសំលៀកបំពាក់សម្រាប់ម៉ាកល្បីៗដែលគេធ្លាប់បានស្គាល់ជាអន្តរជាតិមួយចំនួនរួមមាន Tommy Hilfiger, Polo Ralph Lauren, All Saints, Armani Exchange, Forever 21 and Fred Perry ។[159]

ភរិយារបស់លោកហ៊ុន ម៉ានី ឈ្មោះ យឹមឆាយ សព្វថ្ងៃជានាយកក្រុមហ៊ុន Decampharma ដែលត្រូវបានចុះបញ្ជីថាមានទុនរួមសរុបចំនួន 50,000$ ដុល្លាសហរដ្ឋអាមេរិក។[160] បងស្រីថ្លៃរបស់គាត់ឈ្មោះ ហ៊ុន ម៉ាលី កាន់កាប់ភាគហ៊ុន %10 នៅក្នុងក្រុមហ៊ុន ខណ:ដែលក្រុមហ៊ុនផលិតឱសថរបស់ប្រទេសដាណាម៉ាកកាន់កាប់ភាគហ៊ុនចំនួន %35 ។[161] ក្រុមហ៊ុនផលិតឱសថ Missionpharma គឺជាក្រុមហ៊ុនលក់រាយផលិតផលឱសថ "លំដាប់ថ្នាក់លេខមួយ" សម្រាប់គម្រោងនានាដែលត្រូវបានផ្តល់ហិរញ្ញវត្ថុដោយអង្គការជំនួយអភិវឌ្ឍន៍រដ្ឋាភិបាលសហរដ្ឋអាមេរិកហៅកាត់ថា USAID។[162]

អង្គការគ្លូបប៊លវីតណែសបានសរសេរលិខិតទៅក្រុមហ៊ុនផលិតឱសថ Missionpharma ក្នុងឆ្នាំ 2015។ ក្រុមហ៊ុនបានឆ្លើយតបនៅថ្ងៃទី 26 ខែមករាឆ្នាំ 2016 និងបានបញ្ជាក់ពីភាគហ៊ុនដែលមានក៏ប៉ុន្តែបានប្រាប់ថា ក្រុមហ៊ុនផលិតឱសថ Decampharma បច្ចុប្បន្ននេះមិនដំណើរការទេ។ ក្រុមហ៊ុនក៏បានបញ្ជាក់ថាខ្លួនមិនផ្គត់ផ្គង់ដោយផ្ទាល់ដល់អង្គការ USAID ទេក៏ប៉ុន្តែផ្ទុយទៅវិញគឺផ្គត់ផ្គង់គម្រោងក្នុងប្រទេសអាហ្វ្រិកដែលដំណើរការដោយដៃគូរអនុវត្តគម្រោងផ្សេងក្រោមជំនួយមូលនិធីពី USAID។ ក្រុមហ៊ុនផលិតឱសថ Missionpharma មិនមានសកម្មភាពណាមួយដែលត្រូវបានផ្តល់មូលនិធិក្នុងប្រទេសកម្ពុជាទេ។

* ចាប់តាំងពីការបោះពុម្ពផ្សាយនូវរបាយការណ៍នេះ ក្រុមហ៊ុនវិនិយោគអ៊ែតវូតគ្រុប (Attwood Investment Group Co Ltd (AIG)) បានទាក់ទងមកយើងដើម្បីប្រាប់ថា ភាគហ៊ុនរបស់ AIG និងរបស់ក្រុមហ៊ុន Attwood Import Export Co Ltd គឺជាកម្មសិទ្ធិទាំងស្រុងរបស់ លោកស្រី Lim Chhiv Ho (លឹម ឈីវ ហូ) ហើយថា ហ៊ុន សេងនី ឬសមាជិកទាំងឡាយរបស់ក្រុមគ្រួសារនាយករដ្ឋមន្ត្រីមួយណាក៏មិនជាប់ពាក់ព័ន្ធជាមួយនឹងបណ្តាក្រុមហ៊ុនទាំងនេះក្នុងមធ្យោបាយណាមួយឡើយ។

## គ្រោះថ្នាក់ចំពោះអ្នកវិនិយោគបរទេស

លើសពីការគិតពីក្រមសីលធម៌ដែលអ្នកវិនិយោគបរទេសគួរតែថ្លឹងថ្លែងនៅពេលដែលពិចារណាពីទំនាក់ទំនងពាណិជ្ជកម្មជាមួយនឹងគ្រួសារត្រកូលហ៊ុន ការធ្វើជំនួញជាមួយពួកគេឬជាមួយនឹងអ្នកមានអំណាចមានទ្រព្យសម្បត្តិផ្សេងទៀតដែលជាជនជាតិកម្ពុជាក៏អាចបង្ហាញពីច្បាប់ដ៏តឹងរឹង ហានិភ័យកេរ្តិ៍ឈ្មោះនិងហិរញ្ញវត្ថុនានា។ ដោយសារតែកង្វះតម្លាភាពនិងអំពើរពុករលួយដែលរីក រាលដាលពាសពេញ ទើបធ្វើឲ្យការធ្វើជំនួញដែលពាក់ព័ន្ធនឹងរដ្ឋាភិបាលកម្ពុជា រួមមានទាំងលទ្ធកម្មសាធារណ:កិច្ចសន្យាផ្នែក ហេដ្ឋារចនា សម្ព័ន្ធនិងការបែងចែកធនធានធម្មជាតិ នាំឲ្យមានហានិភ័យខ្ពស់សម្រាប់អ្នកវិនិយោគ បរទេស។[163] ក្រុមហ៊ុននានាដែលកំពុងពិចារណាចុះកិច្ចព្រមព្រៀងមួយក្នុងន័យដែលពាក់ព័ន្ធជាមួយនិងរដ្ឋគួរតែពង្រឹងការប្រុងប្រយ័ត្នខ្ពស់ដើម្បីធានាថាវាមិនមានហានិភ័យពីអំពើរពុករលួយក្នុងនោះ។

ចំពោះបរិបទច្បាប់ក្នុងស្រុក ច្បាប់ប្រឆាំងនឹងអំពើរពុករលួយឆ្នាំ 2010 របស់ប្រទេសកម្ពុជាបានធ្វើឲ្យទៅជាខុសច្បាប់នូវសកម្មភាពណាដែលគេដឹងថាអាចមានផលប្រយោជន៍ពីអំពើពុករលួយ។[164] ក្រុមហ៊ុនអន្តរជាតិណាមួយដែលទាញយកប្រយោជន៍ពីទំនាក់ទំនងគ្រួសារត្រកូលហ៊ុនដើម្បីនាំឲ្យមានកិច្ចព្រមព្រៀងដែលពាក់ព័ន្ធនឹងធនធានឬហេដ្ឋារចនាសម្ព័ន្ធរដ្ឋជាគោលការណ៍អាចនឹងងាយប្រឈមនឹងការជាប់ចោទពីបទល្មើសឧក្រិដ្ឋដែលទាញយកផលប្រយោជន៍ពីអំពើរពុករលួយនិងសិទ្ធិតែងតាំង។ បញ្ហានេះកំពុងកើតឡើងដោយពួកគេបានដឹងច្បាស់ ដែលក្នុងករណីខ្លះពួកគេអាចប្រឈមនឹងការកាត់ឲ្យជាប់គុកនិងការពិន័យផងឬពួកគេត្រូវការកែលម្អនិតិវិធីខិតខំប្រឹងប្រែងរបស់ពួកគេជាបន្ទាន់ដើម្បីធានាថាពួកគេយល់ថាតើពួកគេកំពុងតែធ្វើជំនួញជាមួយនរណា។[165]

ក្រុមហ៊ុននានាមិនគួរពឹងផ្អែកទៅលើទម្លាប់នៃការកាច់បំបាក់របស់រដ្ឋាភិបាលកម្ពុជាឬក៏ធ្វើព្រងើយកន្តើយពីច្បាប់របស់ខ្លួនមិនថាទោះក្នុងស្ថានភាពនេះទេ។ អ្នកវិនិយោគបរទេសក៏ប្រថុយប្រថាននឹងការលេងបន្លំចំពោះច្បាប់ប្រឆាំងអំពើរពុករលួយដែលមានអំណាចក្នុងដែនអំណាចច្បាប់ផ្សេងដូចជាច្បាប់របស់ប្រទេសអង់គ្លេសនិងសហរដ្ឋអាមេរិកទេ។ ក្នុងឆ្នាំ 1977ច្បាប់អនុវត្តប្រឆាំងអំពើរពុករលួយបរទេសរបស់សហរដ្ឋអាមេរិក (FCPA)បានហាមឃាត់*"ការផ្តល់ការបង់ប្រាក់ ការទូទាត់ប្រាក់ ការសន្យាឬ ការអនុញ្ញាតិឲ្យមានការទូទាត់ប្រាក់ឬអ្វីក៏ដោយដែលមានតម្លៃដល់មន្ត្រីបរទេសដើម្បីមានឥទ្ធិពលលើច្បាប់ឬការសម្រេចចិត្តរបស់មន្ត្រីបរទេសនោះក្នុងដែនសមត្ថកិច្ចរបស់គេឬដើម្បីធានាចំពោះផលប្រយោជន៍ដែលមិនសមស្របណាមួយផ្សេងទៀតដើម្បីទទួលបានឬទទួលមកវិញនូវជំនួញ"*។[166] ច្បាប់នេះក៏បានហាមឃាត់ផងដែរដល់ក្រុមហ៊ុននានាមិនឲ្យប្រព្រឹត្តអំពើរពុករលួយដោយការបង់ប្រាក់ដល់មន្ត្រីបរទេសតាមរយ:ភាគីទីបីឬអន្តរការីណាម្នាក់។[167] បទប្បញ្ញត្តិប្រឆាំងការសូកប៉ាន់ទាំងនេះមិនត្រឹមតែអនុវត្តចំពោះប្រជាជននិងមុខជំនួញសហរដ្ឋអាមេរិកប៉ុណ្ណោះទេក៏ប៉ុន្តែក៏អនុវត្តផងដែរចំពោះក្រុមហ៊ុនដែលត្រូវបានចុះបញ្ជីនៅលើតារាងភាគហ៊ុនសហរដ្ឋអាមេរិកឬដែលតម្រូវឲ្យមានការដាក់របាយការណ៍ពិនិត្យតាមកាលកំណត់ជាមួយនឹងគណ:កម្មាការផ្លាស់ប្តូរសន្តិសុខ(SEC)។[168] ច្បាប់នេះក៏មានបន្តអនុវត្តចំពោះ មុខជំនួញណាដែលត្រូវបានធ្វើឡើងជារូបិយប័ណ្ណដុល្លាសហរដ្ឋអាមេរិកផង ដែរ។[169] កត្តានេះនាំឲ្យអ្នកវិនិយោគនៅក្នុងប្រទេសកម្ពុជាស្ថិតក្រោមហានិភ័យខ្លាំងដោយសារតែរូបិយប័ណ្ណប្រាក់ដុល្លាសហរដ្ឋអាមេរិកគឺជារូបិយប័ណ្ណតែមួយគត់ដែលត្រូវបានប្រើប្រាស់សម្រាប់ការធ្វើជំនួញមិនមែនក្នុងស្រុកក្នុងប្រទេសកម្ពុជា។

ស្របពេលជាមួយគ្នានេះ ច្បាប់ប្រឆាំងនឹងការសូកប៉ាន់ឆ្នាំ 2010 របស់ប្រទេសអង់គ្លេសក៏អនុវត្តចំពោះជនជាតិអង់គ្លេសទាំងអស់ឬអ្នកដែលមានទីលំនៅក្នុងប្រទេសអង់គ្លេសក៏ដូចជាអង្គការនានាមិនថាដែលត្រូវបានបង្កើតឡើងក្នុងប្រទេសអង់គ្លេសឬធ្វើជំនួញរបស់ពួកគេយ៉ាងហោចណាស់មួយផ្នែកនៅក្នុងប្រទេសអង់គ្លេស។[170] ច្បាប់នេះហាមឃាត់បុគ្គលណាមួយពីការផ្តល់ ការសន្យាឬការឲ្យ*"ផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុឬជាអ្វីផ្សេងទៀតដល់ជនដទៃ"* ហើយច្បាប់នេះអនុវត្តទាំងចំពោះវិស័យសាធារណ:និងឯកជន។[171] ក៏ដូចជាច្បាប់ប្រឆាំងអំពើរពុករលួយបរទេសរបស់សហរដ្ឋអាមេរិក (FCPA) ដែរ គឺថាច្បាប់ហាមឃាត់ការស៊ី សំណូកសូកប៉ាន់ក៏ត្រូវអនុវត្តចំពោះអំពើរពុករលួយដែលធ្វើឡើងដោយភាគីទីបីផងដែរ។[172]

ដូចគ្នានេះដែរ ក្រោមច្បាប់បទល្មើសឧក្រិដ្ឋឆ្នាំ 1995 របស់ប្រទេសអូស្ត្រាលី ដែលចែងថាវាគឺជាការប្រព្រឹត្តខុសក្នុងការផ្តល់ឬស្នើរដល់នរណាម្នាក់(ដោយផ្ទាល់ឬដោយប្រយោល) នូវផលប្រយោជន៍ដែលមិនស្របច្បាប់ដោយសារតែបុគ្គលនោះមានបំណងចង់បានឥទ្ធពលលើមន្ត្រីសាធារណ:បរទេសដោយការប្រើប្រាស់ភារកិច្ចការងាររបស់ពួកគេដើម្បីទទួលបានឬទទួលមកវិញនូវមុខជំនួញឬផលប្រយោជន៍ជំនួញមួយ។[173] អាជ្ញាធរអូស្ត្រាលីអាចកាត់ទោសក្រុមហ៊ុនឬបុគ្គលណាម្នាក់ដែលមានការប្រ




ការបើកហាង iOne ភ្នំពេញ ដែលជាក្រុមហ៊ុនលក់រាយផលិតផល Apple មុនដំបូងគេបង្អស់របស់ប្រទេសកម្ពុជា នៅក្នុងឆ្នាំ 2009។ iOne ត្រូវបានគ្រប់គ្រងដោយក្មួយស្រីរបស់ ហ៊ុន សែន។

ព្រឹត្តខុសដូច្នេះ ក្នុងករណីដែលទំនាក់ទំនងគ្រប់គ្រាន់មួយអាចត្រូវបានគេបង្កើតឡើងរវាងអង្គភាពដែលស្ថិតក្រោមការស៊ើបអង្កេតនិងប្រទេសអូស្ត្រាលី ក្នុងនោះមិនថាការប្រព្រឹត្តខុសនោះត្រូវបានធ្វើឡើងក្នុងប្រទេស អូស្ត្រាលីឬដោយជនជាតិអូស្ត្រាលីឬក្រុមហ៊ុនណានោះទេ។[174]

ជាមួយនឹង 38 ប្រទេសផ្សេងទៀត ប្រទេសអង់គ្លេស សហរដ្ឋអាមេរិកនិងប្រទេសអូស្ត្រាលីគឺជាប្រទេសហត្ថលេខីនៃសន្និបាតប្រឆាំងអំពើរស៊ីសំណូកសូកប៉ាន់ឆ្នាំ 1997 នៃអង្គការអភិវឌ្ឍន៍កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងការអភិវឌ្ឍន៍ (OECD) ដែលក៏បង្ហាញពី ហានិភ័យនានាសម្រាប់អ្នកវិនិយោគផងដែរ។[175] សន្និបាតនេះបង្កើតឲ្យមានបទដ្ឋានចងផ្អែកច្បាប់សម្រាប់រដ្ឋនានាដើម្បីធ្វើឲ្យមន្ត្រីសាធារណៈបរទេសដែលស៊ីសំណូកក្លាយទៅជាឧក្រិដ្ឋជនក្នុងការធ្វើជំនួញពាណិជ្ជកម្មជាលក្ខណៈអន្តរជាតិ។[176] ក្រោម សន្និបាតនេះ គ្រប់សមាជិកប្រទេសទាំង32 នៃអង្គការអភិវឌ្ឍន៍កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងការអភិវឌ្ឍន៍ (OECD) ដែលបន្ថែមចំពោះប្រទេសអង់គ្លេស សហរដ្ឋអាមេរិកនិងប្រទេសអូស្ត្រាលីក៏បានបញ្ចូលអ្នកវិនិយោគធំៗរបស់ប្រទេសកម្ពុជា ជប៉ុន កូរ៉េនិងកាណាដាផងដែរ ដែលតម្រូវឲ្យធ្វើការកាត់ទោសជនជាតិរបស់ខ្លួនពីបទល្មើសដែលបានប្រព្រឹត្តនៅបរទេស។[177]

គ្រោះថ្នាក់នៃការប្រថុយប្រថានទាំងនេះគឺមានច្បាស់ណាស់ ដូចជាប្រវត្តិសាស្ត្រថ្មីៗនេះបង្ហាញ។ ក្នុងខែ មិនាឆ្នាំ 2016 នាយកប្រតិបត្តិផ្សារមូលបត្ររបស់ប្រទេសអូស្ត្រាលីត្រូវបានបង្ខំចិត្តឲ្យលាលែងពីតំណែង ក្រោមការចោទប្រកាន់ដែលថាក្រុមហ៊ុនភ្នាល់ល្បែងដែលគាត់ធ្លាប់បានគ្រប់គ្រងម្តងនោះបានសូកប៉ាន់គ្រួសារត្រកូល ហ៊ុន អស់ជាច្រើចឆ្នាំមកហើយ។[178] ក្រុមហ៊ុនរបស់ប្រទេសអូស្ត្រាលីឈ្មោះ BHP Billiton ត្រូវបានរកឃើញថាបាន បង់ប្រាក់ដល់រដ្ឋាភិបាលកម្ពុជាក្នុងឆ្នាំ 2013 ដើម្បីដោះដូរជាមួយនឹងសិទ្ធិរុករករ៉ែក្នុងកិច្ចព្រមព្រៀងមួយដែលត្រូវបានចោទប្រកាន់ថាមានការគ្រប់គ្រងដោយលោកហ៊ុនសែនផ្ទាល់តែម្តង។[179] នៅក្នុងលិខិតមួយទៅកាន់អង្គការគ្លូបប៊ិលវីតណែសក្នុងឆ្នាំ 2008 ក្រុមហ៊ុនបានបញ្ជាក់ថាបានបង់ប្រាក់ដល់រដ្ឋាភិបាលចំនួន 1លានដុល្លាសហរដ្ឋអាមេរិកក៏ប៉ុន្តែបានថ្លែងថាវាគឺជាការធ្វើជំនួញផ្លូវការស្របទៅនឹងលក្ខខណ្ឌនានានៃកិច្ចព្រមព្រៀងរុករករ៉ែ។ ទោះបីជាមានការបដិសេធរបស់ពួកគេក៏ដោយ ការចោទប្រកាន់ទាំងនេះចំពោះក្រុមហ៊ុន BHP Billiton ក្នុងចំណោមអ្នកដទៃផ្សេង បាននាំឲ្យមានការស៊ើបអង្កេតដោយទាំងគណៈកម្មាការសន្តិសុខមូលបត្រសហរដ្ឋអាមេរិក (SEC) និងក្រសួងយុត្តិធម៌ ហើយក្រុមហ៊ុនដែលជាចុងក្រោយបានយល់ព្រមបង់ប្រាក់ពិន័យចំនួន25 លានដុល្លាសហរដ្ឋអាមេរិកដល់គណៈកម្មាការសន្តិសុខមូលបត្រសហរដ្ឋអាមេរិក (SEC) ចំពោះការរំលោភច្បាប់ប្រឆាំងអំពើរពុករលួយបរទេសរបស់សហរដ្ឋអាមេរិក (FCPA)។[180] នេះគឺជាការបង្ហាញទាំងស្រុងនៃការប្រថុយប្រថានផ្នែកច្បាប់ដ៏ធំជុំវិញអំពើរពុករលួយដែលលាតសន្ធឹងលើសពីដែនកំណត់ច្បាប់របស់ក្រុមហ៊ុនផ្ទាល់ឬទីដែលពួកគេធ្វើប្រតិបត្តិការ។

*“អ្នកវិនិយោគជនជាតិអាមេរិកជាទូទៅមានភាពស្ទាក់ស្ទើរអស់អែកចំពោះប្រព័ន្ធតុលាការរបស់ប្រទេសកម្ពុជាក្នុងការដោះស្រាយជម្លោះពាណិជ្ជកម្មនានាដោយសារតែតុលាការត្រូវបានគេមើលឃើញថាមិនអាចទុកចិត្តបាននិងងាយរងឥទ្ធពលនយោបាយពីខាងក្រៅឬអំពើរស៊ីសំណូកសូកប៉ាន់។ ជំនួញទាំងក្នុងស្រុកនិងបរទេសរាយការណ៍ជារឿយៗពីបញ្ហានានាជាមួយនឹងការគ្រប់គ្រងផ្នែកប្រព័ន្ធតុលាការដែលប្រែប្រួលមិនថិតថេរ អំពើរពុករលួយនិងការលំបាកក្នុងការពង្រឹងការវិនិច្ឆ័យក្តី។ សម្រាប់ហេតុផលទាំងនេះ ជម្លោះពាណិជ្ជកម្មភាគច្រើនថ្មីៗនេះត្រូវបានដោះស្រាយតាមរយៈការចរចារដែលត្រូវបានសម្របសម្រួលដោយក្រសួងពាណិជ្ជកម្ម ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សភាពាណិជ្ជកម្មកម្ពុជានិងស្ថាប័នផ្សេងៗទៀតដែលពាក់ព័ន្ធ។”*[181]

**សេចក្តីថ្លែងការស្តីពីបរិយាកាសវិនិយោគឆ្នាំ 2013 ដោយមន្ទីរដោះស្រាយជម្លោះសហរដ្ឋអាមេរិកសម្រាប់ប្រទេសកម្ពុជា។**

***គួរកត់សម្គាល់ថាស្ថាប័នទាំងបីដែលបានចុះបញ្ជីដោយមន្ទីរសន្តិសុខសហរដ្ឋអាមេរិកសម្រាប់ដោះស្រាយជម្លោះពាណិជ្ជកម្មក្រោមការគ្រប់គ្រងឬឥទ្ធិពលរបស់លោកហ៊ុនសែន។ ក្នុងឋានៈជានាយករដ្ឋមន្ត្រី គាត់គ្រប់គ្រងក្រសួង ពាណិជ្ជកម្ម គាត់ជាប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងដៃគូរជំនួញដ៏ជិតស្និទ្ធ និងជាមិត្តភក្តិផ្ទាល់ខ្លួនរបស់គាត់គឺលោកគិតម៉េងជាប្រធានសភាពាណិជ្ជកម្មកម្ពុជា។[182]នេះបានន័យថាស្ថាប័នតែមួយគត់ដែលគួរត្រូវដោះស្រាយជម្លោះពាណិជ្ជកម្មដោយមិនមានការពឹងពាក់លើប្រព័ន្ធតុលាការត្រូវបានគ្រប់គ្រងដោយអ្នកមានអំណាចនិងទ្រព្យសម្បត្តិដែល ពុករលួយខូចហើយមិនអាចពឹងពាក់ថាមានភាពឯករាជ្យនោះទេ។*

## ជាការឆ្លើយតបតែមួយគត់របស់ត្រកូលហ៊ុនចំពោះការចោទប្រកាន់នានារបស់អង្គការគ្លូបប៊ិលវីតណែស

កាលពីខែមករាឆ្នាំ 2016 អង្គការគ្លូបប៊ិលវីតណែសបានសរសេររបាយការណ៍ទៅសមាជិកទាំង27 របស់គ្រួសារត្រកូលហ៊ុនដែលបានលើកឡើងក្នុងរបាយការណ៍នេះរួមទាំងលោកនាយករដ្ឋមន្ត្រីផងដែរ។ មានតែស្វាមីរបស់ឈ្មោះ ហ៊ុន ម៉ាលី គឺលោក សុខពុទ្ធីវុធទេដែលបានឆ្លើយតប ដោយសារអេឡិចត្រូនិកដ៏វែងមួយចុះកាលបរិច្ឆេទថ្ងៃទី 8 ខែកុម្ភៈ។ នេះគឺជាសម្រង់សេចក្តីផ្នែកខ្លះនៃសារៈ

- “ឃើញបញ្ហានិងដំណោះស្រាយជាច្រើន ក៏ប៉ុន្តែខ្ញុំបានឃើញម្តងហើយម្តងទៀតថាដំណោះស្រាយដ៏ល្អបំផុតគឺកម្រត្រូវបានអនុវត្តដោយត្រឹមត្រូវណាស់...
- អស់រយៈពេលជាច្រើនឆ្នាំ គ្រួសាររបស់ខ្ញុំបានជំទាស់មិនឲ្យខ្ញុំមានតួនាទីក្នុងជួររដ្ឋាភិបាលទេ។ ដូច្នេះខ្ញុំបានជ្រើសរើសវិស័យឯកជនដើម្បីសាកល្បងសមត្ថភាពរបស់ខ្ញុំក្នុងការកសាងអង្គការមួយដែលមានប្រសិទ្ធិភាព
- ខ្ញុំអាចយល់ការសន្និដ្ឋានរបស់អ្នកដែលថាខ្ញុំបានរំលោភអំណាចរបស់ខ្ញុំក្នុងការទទួលបានតំណែងដែលខ្ញុំកំពុងមានថ្ងៃនេះ ក៏ប៉ុន្តែខ្ញុំអាចធានាអះអាងប្រាប់អ្នកថាខ្ញុំទទួលយកការប្រកួតប្រជែងដ៏ខ្លាំងក្លាក្នុងការកសាងក្រុមវិស័យឯកជនដែលមានការទទួលខុសត្រូវនិងការគោរពមួយ។ ខ្ញុំទទួលស្គាល់ថាវាជាការងារដែលកំពុងដំណើរការ។
- ខ្ញុំយល់និងដឹងថាខ្ញុំរស់នៅក្រោមម្លប់គ្រួសាររបស់ខ្ញុំ។
- ខ្ញុំសង្ឃឹមថាសកម្មភាពនានារបស់ខ្ញុំនិងក្រុមរបស់ពួកយើងអាចជួយគាំទ្រដល់ការអភិវឌ្ឍន៍ប្រទេសកម្ពុជាក្នុងទម្រង់ឬមធ្យោបាយណាមួយ។ ដោយមានសមត្ថភាពធនធានមនុស្សច្រើននិងស្ថាប័នកាន់តែរឹងមាំ ខ្ញុំសង្ឃឹមថាយើងអាចបង្កើនល្បឿនដំណើរការផ្សះផ្សារនិងជួយធ្វើឲ្យប្រទេសកម្ពុជាក្លាយជាប្រទេសគំរូមួយដែលនឹងរួមចំណែកដោយវិជ្ជមានដល់សហគមន៍សកលលោកនាពេលអនាគត។
- ជាថ្មីម្តងទៀតសូមអរគុណសម្រាប់ការចាប់អារម្មណ៍របស់អ្នកចំពោះប្រទេសកម្ពុជា។ ខ្ញុំរំពឹងរង់ចាំមើលឃើញការយល់ដឹងពិតប្រាកដនិងផលប៉ះពាល់ជាវិជ្ជមានពីការងាររបស់អង្គការគ្លូបប៊ិលវីតណែសដើម្បីជួយប្រទេសរបស់ខ្ញុំ សហគមន៍អន្តរជាតិនិងពិភពលោក។"

# ការមិនគោរពច្បាប់របស់គ្រួសារត្រកូលហ៊ុន

ប្រធានបទសំខាន់មួយក្នុងចំណោមប្រធានបទជាច្រើនក្នុងការចង្អុលបង្ហាញឲ្យបានច្បាស់ពីប្រព័ន្ធគ្រប់គ្រងរដ្ឋរបស់ត្រកូលហ៊ុនគឺ និទ្ទណ្ឌភាព។[183] ប្រព័ន្ធតុលាការប្រទេសកម្ពុជាគឺស្ថិតក្រោមការគ្រប់គ្រងទាំងស្រុងរបស់លោកនាយករដ្ឋមន្ត្រី ដែលត្រូវបានប្រើប្រាស់ ដើម្បីការពារផលប្រយោជន៍ក្រុមគ្រួសាររបស់គាត់ដោយមិនអើរពើរពីការរំលោភច្បាប់របស់ពួកគេនិងការចាប់ដាក់ទោសឧក្រិដ្ឋអ្នករិះគន់របស់ពួកគេ។[184] ជាលទ្ធផល សមាជិកគ្រួសារនិងក្រុមហ៊ុននានាដែលពួកគេរកស៊ីជាមួយក្នុងនោះបានរំលោភច្បាប់ជាប្រចាំដែលមើលទៅទំនងដូចជាមិនខ្លាចរអាចំពោះការកាត់ទោសណាមួយទេ។ ចំណុចល្អគឺថា កត្តានេះអាចបានឃុំគ្រងការពារគ្រួសារត្រកូលហ៊ុនពីការប្រឈមជាមួយនឹងផលវិបាកដែលកើតចេញពីបទល្មើសតូចតាចឬការប្រព្រឹត្តមិនល្អនានា។[185] បើចំណុចអាក្រក់វិញគឺការ បណ្តេញចេញដោយបង្ខំដែលសហគមន៍ទាំងមូលបានប្រឈមនឹងការកំចាត់ចេញពីលំនៅដ្ឋានរបស់ពួកគេឬត្រូវបានប្លន់ដីស្រែចម្ការឬព្រៃឈើរបស់ពួកគេដោយមិនមានការដាក់ពិន័យទោសទណ្ឌឡើយ។[186]

ជំពូកនេះផ្តល់ជាឧទាហរណ៍ចំពោះមធ្យោបាយជាគន្លឹះមួយចំនួនដែលក្នុងនោះសមាជិកគ្រួសារត្រកូលហ៊ុននិងក្រុមហ៊ុននានាដែលមានទំនាក់ទំនងជាមួយពួកគេ អាចរួចខ្លួនដោយការរំលោភច្បាប់ជាច្រើនរបស់ប្រទេសកម្ពុជារួមមានទាំងបទប្បញ្ញត្តិច្បាប់ប្រឆាំងអំពើរពុករលួយក៏ដូចជាច្បាប់នានាដែលត្រូវបានតាក់តែងឡើងដើម្បីការពារសិទ្ធិមនុស្សយុត្តិធម៌សង្គមនិងបរិស្ថាន។



សមាជិកនៃអង្គភាពអង្គរក្សដ៏ខ្លាំងក្លារាប់ពាន់នាក់របស់ ហ៊ុន សែន ដែលមានមុខងារជាកងទ័ពឯកជនរបស់ ហ៊ុន សែន និងជាផ្នែកដ៏សំខាន់ក្នុងការរក្សាការក្តោបក្តាប់អំណាចរបស់គាត់។

*“ប្រព័ន្ធតុលាការនៅក្នុងប្រទេសកម្ពុជាគឺពុករលួយនិងកាន់តែអាក្រក់ទៅៗ ដែលធ្វើឲ្យវាស្ទើរតែមិនមែនជាមធ្យោបាយដ៏មានប្រយោជន៍ទាល់តែសោះសម្រាប់ប្រជាជនសាមញ្ញធម្មតាក្នុងការធានាឲ្យមានការកែទោសកំហុសឡើង វិញ។ អាជ្ញាធរនិងជនមានអំណាចបុណ្យសក្តិធំដែលមានបណ្តាញទំនាក់ទំនងជិតស្និទ្ធគ្នាក៏រំលោភលើប្រព័ន្ធតុលាការ ជារឿយៗ ដោយប្រើប្រាស់ការចោទប្រកាន់ពីបទល្មើសឧក្រិដ្ឋជាមធ្យោបាយក្នុងការគំរាមគំហែង យាយីនិងកំចាត់សកម្មជនសិទ្ធិមនុស្ស។ ស្របពេលជាមួយគ្នានេះ សម្រាប់បទល្មើសឧក្រិដ្ឋពិតប្រាកដជាច្រើន និទ្ទណ្ឌភាពឈ្នះ ដោយអ្នកមានទ្រព្យសម្បត្តិនិងឥទ្ធិពលសូកប៉ាន់ប៉ូលីសដើម្បីគេជផុតពីការឃុំឃាំងនិងតុលាការ។”*[187]

**-អង្គការលីកាដូ ជាអង្គការក្រៅរដ្ឋាភិបាល សិទ្ធិមនុស្សឈានមុខមួយរបស់ប្រទេសកម្ពុជា។**

## ការដាក់ប្រាក់វិនិយោគលើធនធានរដ្ឋ

អត្ថបទ ដកស្រង់- ការបោះឆ្នោតស្ទង់មតិដោយវិទ្យាស្ថានសាធារណៈរដ្ឋ និងអង្គការ USAID ទូទាំង24ខេត្តក្រុងក្នុងប្រទេសកម្ពុជាបានរកឃើញថា"អំពើរពុករលួយកាន់តែច្រើន"និង"ញាតិបក្សពួកនិយម"គឺជាហេតុផលពីរក្នុងចំណោមហេតុផលបីចំបងធំៗដែលអ្នកឆ្លើយសំណួរបានផ្តល់ថាតើហេតុអ្វីបានជាប្រទេសត្រូវបានដឹកនាំ "ខុសទិសដៅ"។[188]

គ្រួសារត្រកូលហ៊ុនគឺជាឧទាហរណ៍ដ៏ចំបងនៃវប្បធម៌បក្សពួកនិយមមួយដែលត្រូវបានប្រើប្រាស់ដោយអ្នកធំដែលមានអំណាចដែលក្នុងនោះភាពស្វាមីភ័ក្តខាងនយោបាយបើកផ្លូវឲ្យដល់ភាពមានបានដ៏សន្ធឹកសន្ធាប់។[189] អស់រយៈពេលជាច្រើនទសវត្សរ៍មកហើយ ក្រុមតូចនេះបានជួយខ្លួនឯងទទួលបានដីធ្លីមួយផ្នែកធំរបស់ប្រទេសកម្ពុជា មានដូចជាព្រៃឈើនិងធនធានធម្មជាតិ នានាជាច្រើនទៀតដោយមិនបានប្រឈមមុខទៅនឹងការសង្ស័យខ្លាំងពីសំណាក់ប្រទេសផ្តល់ជំនួយឬដៃគូរជំនួញទេ។ ដោយមានទ្រព្យធនធានធម្មជាតិនៅសល់តិចតួចដល់ទន្ទ្រានលួច *ការដណ្តើមយកដោយប្រទូស្តរ៉ាយ* បង្ហាញថាតើអ្នកធំមានអំណាចបានពង្រីកគំរូអាក្រក់ពុករលួយដល់សេដ្ឋកិច្ចប្រទេសកម្ពុជាដែលនៅសល់ដោយរបៀបណា។

ការស៊ើបអង្កេតនេះបានបើកបង្ហាញនូវឧទាហរណ៍ជាច្រើនអំពីកន្លែងដែលក្រុមហ៊ុននានាបានភ្ជាប់ខ្សែ បណ្តាញតភ្ជាប់ទំនាក់ទំនងដល់សមាជិកនានារបស់គ្រួសារត្រកូលហ៊ុនដែលបានព្យាយាមធានារក្សានូវកិច្ចសន្យាសាធារណៈដែលផ្តល់ផលកម្រៃច្រើននិងអាជ្ញាប័ណ្ណសម្បទានរដ្ឋ។ ទាក់ទងទៅនឹងប្រវត្តិនៃអំពើរពុករលួយរបស់លោកហ៊ុនសែននិងកង្វះខាតតម្លាភាពក្នុងវិស័យសាធារណៈដ៏ស្មុគស្មាញរបស់ប្រទេសកម្ពុជា គំរូនេះគួរមានការព្រមានដាស់តឿនខ្ពស់។ វាបង្ហាញថាសមាជិកគ្រួសាររបស់គាត់អាចត្រូវទទួលបានការប្រព្រឹត្តជាពិសេសក្នុងការបែងចែកធនធានរដ្ឋ។ នេះទោះបីជាការពិតដែលថាច្បាប់ក្រមព្រហ្មទណ្ឌប្រទេសកម្ពុជានិងច្បាប់ប្រឆាំងអំពើរពុករលួយឆ្នាំ 2010 ដែលដាក់ទោសទណ្ឌដល់ការអនុញ្ញាតិឲ្យមានប្រយោជន៍ដែលមិនយុត្តិធម៌ឬការប្រព្រឹត្តដែលប្រសើរជាងនេះដោយផ្តល់ឱ្យរដ្ឋត្រឡប់មកវិញ នូវការបរិច្ចាកប្រភេទណាមួយ ជាកាដូឬជាការសន្យា។[190]

សមាជិកនៃគ្រួសារត្រកូលហ៊ុនចាំបាច់ត្រូវផ្តល់ភស្តុតាងដើម្បីបង្ហាញថាធនធានរបស់រដ្ឋទាំងនេះត្រូវបានបែងចែកដល់ក្រុមហ៊ុននានាក្នុងភាពដែលស្របច្បាប់និងមិនមានអំពើរពុករលួយ។ បើត្រូវបានពន្យល់ផ្ទុយពីនេះ នោះឧទាហរណ៍ខាងក្រោមនឹងទំនងច្បាស់ជាក្លាយជាហេតុផលសង្ស័យការនាំឲ្យមានអំពើរពុក រលួយជាមិនខាន:

- សមាជិកគ្រួសារនិងដៃគូរជំនួញរបស់ពួកគេត្រូវបានផ្តល់ការអនុញ្ញាតិសម្បទានជាច្រើនក្នុងវិស័យធនធានធម្មជាតិ រួមមានទាំងអាជ្ញាប័ណ្ណសម្រាប់គម្រោងរុករករ៉ែក្នុងខេត្តយ៉ាងហោចណាស់ចំនួនប្រាំ អាជ្ញាប័ណ្ណបូមខ្សាច់សម្រាប់ដីលាតសន្ធឹងបួនគីឡូម៉ែត្រនៃទន្លេមេគង្គ និងយ៉ាងហោចណាស់ដីសម្បទានសេដ្ឋកិច្ចសម្រាប់កសិកម្មចំនួនបី។[191]
- ក្រុមហ៊ុនសំណង់សូម៉ាសាងសង់និងការអភិវឌ្ឍន៍ ដែលត្រូវបានគ្រប់គ្រងដោយកូនប្រសារប្រុសលោកហ៊ុនសែនគឺលោក សុខពុទ្ធីវុទ្ធ មានកិច្ចសន្យាសាងសង់ការិយាល័យរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលរដ្ឋរបស់ប្រទេសកម្ពុជានិងជាផ្នែកមួយនៃគម្រោងដែលមានតម្លៃទឹកប្រាក់ចំនួន 100 លានដុល្លាក្នុងការពង្រីកព្រលានយន្តហោះភ្នំពេញ។[192]
- ក្នុងចំណោមតំបន់សេដ្ឋកិច្ចពិសេសទាំង31 ដែលអង្គការគ្លូបប៊ិលវីតណែសអាចទទួលព័ត៌មានកម្មសិទ្ធសម្រាប់ (តំបន់សរុបទាំងអស់34) តំបន់ពីរត្រូវបានបែងចែកដល់ក្រុមហ៊ុនដែលជារបស់សមាជិកគ្រួសារត្រកូលហ៊ុន។ លិខិតអនុញ្ញាតិសម្រាប់យ៉ាងហោចណាស់តំបន់10ទៀតត្រូវបាន អនុញ្ញាតិដល់អ្នកជំនួញឧកញ៉ាដែលមានទំនាក់ទំនងជាមួយនឹងសមាជិកគ្រួសារនេះ។[193]
- អ្នកផ្គត់ផ្គង់ថាមពលក្នុងស្រុកធំជាងគេទីពីររបស់ប្រទេសកម្ពុជាគឺ ក្រុមហ៊ុនអគ្គីសនីឯកជនកម្ពុជា គឺត្រូវបានគ្រប់គ្រងមួយផ្នែកដោយឈ្មោះ ហ៊ុន

ម៉ាណា ហ៊ុនម៉ានិត និងហ៊ុន ម៉ាលី។ ក្រុមហ៊ុននេះលក់អគ្គីសនីដល់អ្នកផ្គត់ផ្គង់ថាមពលអគ្គីសនីរដ្ឋ EDC ដែល បង្ហាញពីទំនាស់ផលប្រយោជន៍យ៉ាងធ្ងន់ធ្ងរ។[194]

- ដ្ឋាភិបានបានផ្តល់អាជ្ញាប័ណ្ណក្នុងការដំណើរការកាស៊ីណូ Le Macau ឲ្យដល់ក្រុមហ៊ុនវីណា Vina (HK) ជាក្រុមហ៊ុនមួយដែលគ្រប់គ្រងដោយឈ្មោះ គីមហ៊ាង ជាភរិយារបស់ព្រឹទ្ធសភាលោក លី យ៉ុងផាត់ និងបានរាប់បញ្ចូលឈ្មោះហ៊ុន ម៉ាណាជាម្ចាស់ចំណែកហ៊ុន។[195] នៅក្នុងលិខិតផ្ញើរមកកាន់អង្គការគ្លូបប៊ល់វីតណែស ចុះថ្ងៃទី 25 ខែមករាឆ្នាំ 2016 ឈ្មោះ ហ៊ាងបានបដិសេធថាបានទទួលផលប្រយោជន៍ពីប្រព័ន្ធចាត់តាំងដែលត្រូវបានដឹកនាំដោយលោកហ៊ុនសែននិងដែលបង្កើនដល់ការអនុញ្ញាតិឲ្យមានអំពើរពុករលួយ។
- ក្រសួងទេសចរណ៍បានផ្តល់ជាអនុសាសន៍ឲ្យទឹកបរិសុទ្ធម៉ាកវីតាល់ដែលត្រូវបានផលិតដោយក្រុមហ៊ុន NVC ដែលមានឈ្មោះហ៊ុន ម៉ាណាជាអ្នកគ្រប់គ្រង ត្រូវបានប្រើប្រាស់ក្នុងគ្រប់កម្មវិធីបុណ្យផ្ទៃក្នុងថ្នាក់ជាតិទាំងអស់។[196]យ៉ោងតាមគេហទំព័ររបស់ក្រុមហ៊ុន ទឹកបរិសុទ្ធវីតាល់គឺជាផលិតផលជាតិតែមួយគត់ដែលត្រូវបានទទួលស្គាល់ថាជាដៃគូរផ្លូវការមួយសម្រាប់ប្រើប្រាស់ក្នុងវេទិការទេសចរអាស៊ានក្នុងឆ្នាំ 2011 ក្នុងប្រទេសកម្ពុជា។[197]
- ក្រុមហ៊ុនពិគ្រោះយោបល់និងប្រឹក្សាផ្នែកច្បាប់ HML របស់ឈ្មោះ ហ៊ុន គីមឡេងបានអះអាងនៅលើគេហទំព័ររបស់ខ្លួនថាខ្លួន *"បានឈរជើងលើទីតាំងដ៏ល្អជាពិសេសដើម្បីធានាពីកិច្ចសហប្រតិបត្តិការនិងលទ្ធផលល្អ"* ពីការបញ្ចុះបញ្ចូលក្រសួងនិងការិយាល័យនានារបស់ រដ្ឋាភិបាល។[198] ជាពិសេស ក្រុមហ៊ុនអះអាងថានឹងផ្តល់ជូនលទ្ធផលនៅពេលដែលពិភាក្សារកដំណោះស្រាយជាមួយនឹងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អង្គភាពថ្នាក់ខ្ពស់របស់រដ្ឋាភិបាលដែលទទួលបន្ទុកឃ្លាំមើលការខុសត្រូវវិនិយោគដែលត្រូវបានដឹកនាំដោយលោកហ៊ុនសែនដោយផ្ទាល់។[199]
- ក្រោយពីមានកិច្ចព្រមព្រៀងជម្រើសអភិវឌ្ឍន៍ថាមពលឆ្នាំ 2011របស់រដ្ឋាភិបាលកម្ពុជាជាមួយនិងក្រុមហ៊ុន General Electric ក្រុមហ៊ុនរបស់លោកសុខពុទ្ធីវុធឈ្មោះ សូម៉ាគ្រុប បានចុះកិច្ចសន្យាការងារដែលមានតម្លៃទឹកប្រាក់ចំនួន 3 លានដុល្លាសហរដ្ឋអាមេរិកលើកិច្ចព្រមព្រៀងថាមពលជីវៈឧស្ម័នជាមួយនឹងក្រុមហ៊ុនចំរុះសហរដ្ឋអាមេរិក។[200]

## តម្លៃចំពោះមនុស្សនិងបរិស្ថាន

វិសាលភាពនៃការកាន់កាប់វិស័យឯកជនរបស់គ្រួសារត្រកូលហ៊ុន ភាពអាចទទួលបាននូវកម្រៃដ៏ក្រាស់ក្រែលយ៉ាងច្បាស់របស់ពួកគេចំពោះធនធានរបស់រដ្ឋនិងនិទ្ទណ្ឌភាពរបស់ពួកគេចំពោះប្រព័ន្ធច្បាប់ប្រទេសកម្ពុជា ចង្អុលបង្ហាញកាន់តែខ្លាំងដល់ការពិតដែលថាលោកហ៊ុនសែនរបស់ប្រទេសកម្ពុជាត្រូវបានបង្កើតឡើងលើការអនុញ្ញាតិឲ្យមានអំពើរពុករលួយ។ ទាំងនេះគឺនៅឆ្ងាយពីបទល្មើសឧក្រិដ្ឋដែលគ្មានជនរងគ្រោះគឺថាការដឹកនាំរបស់គ្រួសារត្រកូលហ៊ុនបានបង្ករឲ្យមានផលវិបាកដ៏សែនអាក្រក់សម្រាប់ប្រជាជនរបស់ប្រទេសហើយក្រុមហ៊ុនជាច្រើនរបស់ពួកគេបានរួចខ្លួនជាមួយនឹង មិនត្រូវបានគេអើពើរចំពោះមុខច្បាប់របស់ប្រទេសកម្ពុជានិងធ្វើឲ្យ គ្រោះថ្នាក់ដល់ប្រជាជននិងបរិស្ថានជាបន្តបន្ទាប់។

ខាងក្រោមនេះគឺជាឧទាហរណ៍ជាក់លាក់មួយចំនួននៃស្នាមគំរូសង្គមនិងបរិស្ថានដ៏អាក្រក់របស់គ្រួសារត្រកូលហ៊ុន។



ហ៊ុន ម៉ាណា។ រូបថតទទួលបានពីទំព័រហ្វេសប៊ុករបស់នាង។

- កូនស្រីច្បងរបស់លោកហ៊ុនសែនគឺលោកស្រីហ៊ុនម៉ាណា ធ្លាប់ជានាយកនិងជាម្ចាស់ភាគហ៊ុនក្នុងក្រុមហ៊ុនរុករករ៉ែរបស់ប្រទេសចិនឈ្មោះ WS Mining Industry Holdings ចាប់ពីឆ្នាំ 2009ដល់ឆ្នាំ 2012។[200]

ក្នុងឆ្នាំ2008 ក្រុមហ៊ុននេះត្រូវបានផ្តល់ការអនុញ្ញាតិនូវអាជ្ញាប័ណ្ណរុករករ៉ែលើផ្ទៃដីចំនួន 97,000 ហិកតា (ជាតំបន់មួយដែលមានទំហំសឹងប្រហែលទីក្រុងប៉ែកឡាំងរបស់ប្រទេសអាឡឺម៉ង់) លើផ្ទៃដីជនជាតិភាគតិចគួយក្នុងភាគឥសាន្តប្រទេសកម្ពុជា ដែលនៅទីនោះសហគមន៍អាចរស់នៅបានភាគច្រើនដោយការទាញយករ៉ែដោយដៃ កសិកម្មលក្ខណៈទ្រង់ទ្រាយតូចនិងការប្រមូល អនុផលព្រៃឈើនានា។[202] នៅពេលដែលក្រុមហ៊ុនរុករករ៉ែបានចាប់ផ្តើម សហគមន៍ទាំងនេះត្រូវបានបង្ខំឲ្យចាកចេញឆ្ងាយពីធនធានធម្មជាតិដែលបានទ្រទ្រង់ពួកគេអស់ជាច្រើនជំនាន់មកហើយ ដោយបំបាត់ប្រភពចំបងនៃការរកទទួលទានចិញ្ចឹមជីវិតរបស់ពួកគេនិងបានរុញពួកគេឲ្យកាន់តែធ្លាក់ជ្រៅទៅក្នុងភាពក្រីក្រ។[203] យោធាត្រូវបានកែនឲ្យទៅយាមការពារប្រតិបត្តិការរុករករ៉ែរបស់ក្រុមហ៊ុន WS ដោយមានទាហានមកពីអង្គភាពអង្គរក្សរបស់លោកហ៊ុនសែនដែលទទួលបន្ទុកសន្តិសុខ។[204] ទាហានទាំងនោះបានបិទផ្លូវមិនឲ្យមានការចូលទៅកាន់វាលស្រែជាច្រើនរបស់សហគមន៍ហើយជាតិគីមីពុលត្រូវបានប្រើប្រាស់ដើម្បីចម្រាញ់មាសចេញពីដី ដែលធ្វើឲ្យរខ្វក់ការផ្គត់ផ្គង់ទឹកដោយខុសច្បាប់។ ប្រជាជនជាច្រើនត្រូវបានរាយការណ៍ថាបានធ្លាក់ខ្លួនឈឺហើយសត្វចិញ្ចឹមជាលក្ខណៈគ្រួសាររបស់ពួកគេជាច្រើនបានងាប់។[205] ដោយបំពាននឹងច្បាប់ប្រទេសកម្ពុជា អាជ្ញាធរមូលដ្ឋាននិយាយថាក្រុមហ៊ុនបាននាំយកកម្មករមកពីប្រទេសចិនឲ្យមកធ្វើការជាជាងជួលមនុស្សក្នុងមូលដ្ឋានឲ្យធ្វើការឲ្យពួកគេនៅពេលនោះ។[206]

ហ៊ុន ម៉ាណាបានកាត់ផ្តាច់ទំនាក់ទំនងជាមួយនឹងក្រុមហ៊ុនរុករករ៉ែWS របស់ចិនក្នុងឆ្នាំ 2012 ក៏ប៉ុន្តែបញ្ហាទាំងនេះមកទល់ពេលនេះនៅមិនទាន់ត្រូវបានដោះស្រាយនៅឡើយទេ។[207]



ប្រជាជននៅភ្នំពេញដែលកំពុងប្រឈមមុខនឹងការបណ្តេញចេញដោយក្រុមហ៊ុនដែលមានទំនាក់ទំនងជាមួយគ្រួសារហ៊ុន ដោយបោះពស់វែករស់ដែលកាចសាហាវ តាមបង្អួចចូលក្នុងផ្ទះរបស់គាត់នៅក្នុងឆ្នាំ 2013។

- បងថ្លៃប្រុសរបស់លោកហ៊ុន ម៉ានី ឈ្មោះ យឹម លៀង បានកាន់កាប់ដប់ភាគរយនៃក្រុមហ៊ុននាំចេញនាំចូលឃុនសៀចាប់តាំងពីខែកុម្ភៈឆ្នាំ 2011 នៅពេលដែលលោកឧកញ៉ាឃុនសៀ ដែលនៅបន្តកាន់កាប់ភាគហ៊ុនកៅសិបភាគរយដែលនៅសល់របស់ក្រុមហ៊ុន បានផ្ទេរចំណែកហ៊ុនរបស់គាត់។1208 លោកឃុនសៀត្រូវបានពណ៌នាដោយកាសែតក្នុងស្រុកថាជា "ជាអ្នកជំនួញម្នាក់ដែលមានទំនាក់ទំនងនយោបាយនិងមានភាគហ៊ុនច្រើនក្នុងវិស័យកសិកម្មនិងអចលនទ្រព្យ"។[209] ក្រុមហ៊ុននេះត្រូវបានចុះបញ្ជីថាមានទុនសរុបចំនួន 2 លានដុល្លាសហរដ្ឋអាមេរិកលើប្រព័ន្ធទិន្នន័យរបស់ក្រសួងពាណិជ្ជកម្ម។[210] ក្រុមហ៊ុននេះត្រូវបានផ្តល់ការអនុញ្ញាតិផ្ទៃដីសម្បទាន សេដ្ឋកិច្ចចំនួន 200 ,8 ហិកតាដើម្បីដាំដំណាំកៅស៊ូនិងដំណាំផ្សេងៗទៀតក្នុងខេត្តឧត្តរមានជ័យ ដែលស្ថិតក្នុងដែនជម្រកសត្វព្រៃគូលេន ព្រហ្មទេពនៅថ្ងៃទី 6ខែកក្កដាឆ្នាំ 2012 មិនលើសពីដប់ប្រាំបីខែបន្ទាប់ពីលោកលៀងបានក្លាយជាម្ចាស់ភាគហ៊ុន។[211] ការបែងចែកដីធ្លីដោយរដ្ឋាភិបាលនេះបានកើតឡើងពីរខែបន្ទាប់ពីលោកហ៊ុនសែនបានដាក់ការព្យួរទុកបណ្តោះអាសន្ននូវការចេញការអនុញ្ញាតិសម្បទានថ្មី។[212]



នគរបាលវាយបុរសម្នាក់ក្នុងអំឡុងពេលនៃការបំបែកក្រុមកម្មករនៃរោងចក្រកាត់ដេរ SL ដែលកំពុងធ្វើកូដកម្ម។ កម្មកររោងចក្រនេះបានអះអាងថាប្អូនស្រីរបស់ហ៊ុនសែន គឺជាអគ្គនាយកក្រុមហ៊ុន។

បន្ថែមលើសពីនេះ ក្រុមហ៊ុននាំចេញនាំចូលឃ៊ុនសៀ បានមានជម្លោះជាមួយនឹងប្រជាជនដែលមានទីលំនៅក្នុងខ័ណ្ឌទួលគោករាជធានីភ្នំពេញនៅពេលដែលក្រុមហ៊ុនបានព្យាយាមដណ្តើមកាន់កាប់ដីរបស់ពួកគេសម្រាប់ការអភិវឌ្ឍន៍ឡើងវិញ។ ក្រុមហ៊ុននេះត្រូវបានចោទប្រកាន់ពីបទអនុវត្តការបណ្តេញចេញទាំងបង្ខំនិងដាក់បញ្ចូលកងកម្លាំងដើម្បីគំរាមគំហែងនិងវាយប្រហារអ្នកភូមិដែលបដិសេធមិនព្រមរើចេញ រួមមានទាំងការដុតបង្ករអគ្គីភ័យនិងការបោះពស់វែករស់ចូលទៅក្នុងផ្ទះរបស់ពួកគេផងដែរ។[213] ជម្លោះនេះត្រូវបានចុះក្នុងសំណុំរឿងពាក្យបណ្តឹងដែលបានដាក់ជូនតុលាការឧក្រិដ្ឋកម្មអន្តរជាតិក្នុងខែតុលាឆ្នាំ 2014 ដែលពណ៌នាបទល្មើសឧក្រិដ្ឋ ពាក់ព័ន្ធដែលបានប្រព្រឹត្តដោយកក្រុមហ៊ុនឃុនសៀនាំចេញនាំចូលថាជា *"ព្រឹត្តិការណ៍វាយប្រហារជាច្រើននិងជាការប៉ុនប៉ងសម្លាប់ចំពោះ [ ឈ្មោះជនរងគ្រោះត្រូវបានដកចេញដោយសារហេតុផលសុវត្ថិភាព] ការកាត់ទោសផ្អែកលើហេតុផលនយោបាយ"*។[214] សំណុំរឿងនេះដែលចុះឈ្មោះក្រុមហ៊ុននេះថាជាក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុនដប់ផ្សេងទៀតដែលបានប្រព្រឹត្តបទល្មើសឧក្រិដ្ឋនៃការផ្ទេរដោយបង្ខំក្នុងប្រទេសកម្ពុជា ដោយជំទាស់ថារដ្ឋាភិបាលកម្ពុជា កម្លាំងសន្តិសុខរដ្ឋនិងមេដឹកនាំជំនួញដែលមានទំនាក់ទំនងនឹងរដ្ឋាភិបាលបានប្រព្រឹត្តិ'បទល្មើសឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ' ប្រឆាំងនឹងជនស៊ីវិលស្លូតត្រង់កម្ពុជាក្នុង កំឡុងពេលយុទ្ធនាការចាប់យកដីធ្លីដែលរីករាលដាលនិងមានលក្ខណៈជាប្រព័ន្ធរបស់ពួកគេ។[215]

- នៅពេលត្រូវបានសាកសួរដោយអ្នកយកព័ត៌មានក្នុងស្រុកអំពីករណីនេះ លោក យឹមឡេងបានបញ្ជាក់ថាគាត់ ជាម្ចាស់ដី ក៏ប៉ុន្តែបានអះអាងថាគាត់មិនបានដឹងពីបញ្ហានានាដែលកើតមានជាមួយនិងអ្នកភូមិមូលដ្ឋានទេ។[216] ដោយសារតែមុខតំណែងរបស់គាត់ក្នុងជួរកងទ័ពប្រទេសកម្ពុជា ភាគហ៊ុនរបស់លោកឡេងក្នុងក្រុមហ៊ុនឃុនសៀនាំចេញនាំចូលផ្ទុយទៅនឹងមាត្រា25នៃច្បាប់លក្ខន្តិកៈទូទៅឆ្នាំ1998របស់មន្ត្រីទាហាននៃកងយុទ្ធពលខេមរៈភូមិន្ទដែលហាមឃាត់មន្ត្រីទាហានមិនឲ្យ"ធ្វើជំនួញណាមួយដែលអាចធ្វើឲ្យប៉ះពាល់ដល់កិត្តយសនិងភាពថ្លៃថ្នូរនៃកងយុទ្ធពលខេមរៈភូមិន្ទ"។[217]
- សុខ ពុទ្ធីវុធ ដែលជាស្វាមីរបស់លោក ស្រីហ៊ុន ម៉ាលី និងជានាយកប្រតិបត្តិនៃសម្ព័ន្ធក្រុមហ៊ុនសោម៉ាគ្រុប ក៏មានការជាប់ពាក់ព័ន្ធទៅនឹងការរំលោភយកដីធ្លីក្នុងតំបន់ជាយក្រុងផងដែរ។ ក្រុមហ៊ុន។[218] សោម៉ាសាងសង់និងការអភិវឌ្ឍន៍ដែលមានរូបគាត់ជាប្រធាន គឺជាផ្នែកមួយនៃក្រុមវិនិយោគពង្រីកព្រលានយន្តហោះអន្តរជាតិភ្នំពេញ ជាគម្រោងមួយដែលត្រូវបានចាប់ផ្តើមក្នុងឆ្នាំ2014និងដែលមានពាក្យចរចាមអារាមថាមានទឹកប្រាក់ចំនួនជិត100លានដុល្លាសហរដ្ឋអាមេរិក។[219]

គម្រោងនេះគំរាមគំហែងក្នុងការជម្លាសប្រជាជនប្រហែលជិត165 គ្រួសារដែលត្រូវបានប្រាប់ថាផ្ទះរបស់ពួកគេនឹងត្រូវបានបំផ្លិចបំផ្លាញហើយថាពួកគេនឹងមិនទទួលសំណងណាមួយទេទោះបីជាពួកគេមានសិទ្ធិកាន់កាប់ដីរបស់ពួកគេក៏ដោយក្រោមច្បាប់ភូមិបាលប្រទេសកម្ពុជាឆ្នាំ2001។[220] ក្នុងឆ្នាំ 2012 អ្នកតវ៉ាចំនួនប្រាំបីនាក់មកពីសហគមន៍ត្រូវបានចាប់ខ្លួនដោយកងកម្លាំងប្រដាប់អាវុធហើយបានឃុំខ្លួនពួកគេចំនួន12ម៉ោងបន្ទាប់ពីពួកគេបានគូរសញ្ញាឲ្យជួយSOSនៅលើដំបូលផ្ទះរបស់ពួកគេដោយក្តីសង្ឃឹមថាលោកប្រធានាធិបតី  អូបាម៉ានឹងឃើញការអំពាវនាវសុំជំនួយខណៈដែលគាត់បានជិះយន្តហោះមកចូលរួមក្នុងកិច្ចប្រជុំជាន់ខ្ពស់ អាស៊ាន។[221] មួយឆ្នាំក្រោយមកដោយបានកត់សម្គាល់ឃើញថាក្រុមហ៊ុនហិរញ្ញវត្ថុអន្តរជាតិ (IFC) គឺជាផ្នែកមួយនៃគម្រោងផ្តល់ហិរញ្ញប្បទាន ទើបប្រជាជនដែលរងផលប៉ះពាល់ចំនួន 59 គ្រួសារបានដាក់ពាក្យបណ្តឹងជាផ្លូវការជូនដល់មន្ត្រីស៊ើបអង្កេតនិងទទួលពាក្យបណ្តឹងរបស់ពលរដ្ឋរបស់ក្រុមហ៊ុនហិរញ្ញវត្ថុអន្តរជាតិ (IFC)ពាក់ព័ន្ធទៅនឹងលទ្ធភាពនៃការបណ្តេញចេញទាំងបង្ខំ។ ពាក្យបណ្តឹងនោះនៅតែបើកចំហរនៅឡើយក្នុងពេលដំណើរការ។[222] ការងារនៅឯព្រលានយន្តហោះឥឡូវនេះទំនងដូចជាបានឈប់ទ្រឹងក៏ប៉ុន្តែអ្នកជំនាញខាងដីធ្លីរបស់កម្ពុជាបានប្រាប់អង្គការគ្លូបប៊ល់វីតណែសថាសហគមន៍មានការភ័យព្រួយថាការ ពន្យាពេលនោះគឺគ្រាន់តែជាល្បិចកលដើម្បីបង្ការកុំឲ្យមានការតវ៉ាមុនពេលមានការបោះឆ្នោតឃុំសង្កាត់របស់កម្ពុជាក្នុងឆ្នាំ2017 តែប៉ុណ្ណោះ។[223] ក្នុងខែឧសភាឆ្នាំ2016 សារព័ត៌មានក្នុងស្រុកបានរាយការណ៍ថាប្រជាជនចំនួន531 គ្រួសារដែលបានរងផលប៉ះពាល់ខ្លាំងដោយសារគម្រោងពង្រីកព្រលានយន្តហោះបា



ការបាត់បង់ព្រៃឈើនៅក្នុងប្រទេសកម្ពុជាបានកើនឡើងឆាប់រហ័សជាងនៅក្នុងបណ្តាប្រទេសដទៃទៀត នៅចន្លោះពីឆ្នាំ 2001 រហូតដល់ 2014 ដោយសារកាប់ឈើខុសច្បាប់ដោយគ្មានការទប់ស្កាត់ និងការដណ្តើមយកដីធ្លីដោយ ជនដែលមានអំណាចរបស់ប្រទេស។

នធ្វើការតវ៉ាជាសាធារណៈនៅខាងក្រៅទីស្តីការគណៈរដ្ឋមន្ត្រីដោយ ជម្រុញឲ្យពួកគេដោះស្រាយជម្លោះដែលបានបន្តរ៉ាំរ៉ៃនៅទីនោះចំនួន4ឆ្នាំមកហើយ។[224]ជម្លោះដីធ្លីនៅមិនទាន់ឃើញដំណោះស្រាយនៅឡើយទេ។

- ដែលត្រូវជាភរិយាមុនរបស់បងប្អូនជីដូនមួយលោកហ៊ុនសែនគឺលោក ឌី ចូច និងជាមនុស្សស្និទ្ធនឹងអ្នកស្រី ប៊ុនរ៉ានី ត្រូវបានបង្ហាញដោយអង្គការគ្លូបលវីតណែសក្នុងឆ្នាំ2007ថាជាមេខ្លោងធំក្នុងការរកស៊ីកាប់ឈើប្រទេសកម្ពុជាដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើសឧក្រិដ្ឋជាច្រើនរួមមានទាំងអំពើរពុករលួយ ចាប់ជំរិតនិងការប៉ុនប៉ងសម្លាប់ដោយចេតនា។[225] គាត់ជាថ្មីម្តងទៀតត្រូវបានភ្ជាប់ទៅនឹងបណ្តាញការការប់ឈើខុសច្បាប់ក្នុងឆ្នាំ2012 ពេលនោះនៅក្នុងនិងជុំវិញចម្ការកៅស៊ូដែលជាកម្មសិទ្ធរបស់ក្រុមហ៊ុនវៀតណាម។ ក្រៅពីបង្ករឲ្យមានការកាប់បំផ្លាញព្រៃឈើដ៏រីករាលដាលនោះមកសហគមន៍មូលដ្ឋានបានពណ៌នាប្រាប់អ្នកស៊ើបអង្កេតអង្គការគ្លូបលវីតណែសថាតើការកាប់បំផ្លាញព្រៃឈើខុសច្បាប់នោះបាននឹងកំពុងបំផ្លិចបំផ្លាញការរកទទួលទានចិញ្ចឹមជីវិតរបស់ពួកគេដោយរបៀបណាដែលពួកគេពីមុនរស់នៅពឹងផ្អែកលើការប្រមូលយកជ័រឈើដើម្បីយកមកធ្វើជាផលិតផលក្នុងស្រុក។[226]

ទោះបីជាមានភស្តុតាងជាក់ស្តែងនៃការពាក់ព័ន្ធរបស់គាត់ក្នុងការកាប់ឈើខុសច្បាប់និងបទល្មើសឧក្រិដ្ឋផ្សេងៗទៀតក៏ដោយ ក៏ឈ្មោះ សេងគាងនេះកាន់កាប់ក្រុមហ៊ុនចំនួន3។[227]តាមអ្វីដែលអង្គការគ្លូបលវីតណែសបានដឹងគឺថា មិនមានការចាត់វិធានការណ៍តាមផ្លូវច្បាប់ណាមួយដើម្បីប្រឆាំងនឹងគាត់ទេ។។



ហ៊ុន សេងនី។ រូបថតទទួលបានពី http://www.johnnyhon.com/Gallery/Cambodia/photos.htm

- **ហ៊ុន សេងនី** ដែលជាប្អូនស្រីរបស់លោកនាយករដ្ឋមន្ត្រីហ៊ុនសែន ត្រូវបានភ្ជាប់ទំនាក់ទំនងទៅនឹងក្រុមហ៊ុនបី ដែលត្រូវបានចោទប្រកាន់ថាបានរំលោភច្បាប់ប្រទេសកម្ពុជាដោយមិនមានការប្រឈមនឹងផលវិបាកផ្នែកច្បាប់អ្វីទាំងអស់។

យោងតាមសហគមន៍មូលដ្ឋាន ប្រព័ន្ធផ្សព្វផ្សាយនិងបុគ្គលិកសិទ្ធិមនុស្សនានាថាគាត់មានភាគហ៊ុនធំក្នុងក្រុមហ៊ុនកសិកម្មឈ្មោះ HLH Agriculture ។[228]។ ក្រុមហ៊ុននេះគឺជាសាខានៃក្រុមហ៊ុន HLH ដែលមានមូលដ្ឋានក្នុងប្រទេសសឹង្ហបូរីដែលថ្មីៗនេះបានសាងសង់អាគារផ្ទះល្វែងប្រណិតមួយនិងមជ្ឈមណ្ឌលលក់ទំនិញធំក្នុងខេត្តព្រះសីហនុនិងថ្មីៗនេះបានប្រកាសពីគម្រោងវិនិយោគដែលមានទឹកប្រាក់ចំនួន 10លានដុល្លាសហរដ្ឋអាមេរិកក្នុងផ្ទៃដីកសិកម្មចំនួន400 ហិកតាសម្រាប់រោងចក្រអាហារកែច្នៃ។[229] អង្គការគ្លូបលវីតណែសបានសរសេរទៅកាន់ក្រុមហ៊ុននេះក្នុងខែធ្នូឆ្នាំ2015ដោយស្នើរឲ្យពួកគេឆ្លើយតបទៅនឹងការចោទប្រកាន់ដែលថាពួកគេមានការទំនាក់ទំនងទៅនឹងឈ្មោះសេងនីឬទេ។ ក្នុងការឆ្លើយតបរបស់ពួកគេ នៅថ្ងៃទី 7ខែមករាឆ្នាំ2016 ពួកគេបានខកខានមិនបានបញ្ជាក់ឬបដិសេធពីទំនាក់ទំនងនេះ។ ក្នុងឆ្នាំ2010 ក្នុងការឆ្លើយតបចំពោះការចោទប្រកាន់នៃការរំលោភយកដីធ្លី មន្ត្រី រដ្ឋាភិបាលនិងអ្នកគ្រប់គ្រងក្រុមហ៊ុនកសិកម្ម HLH ម្នាក់បានបដិសេធប្រាប់អ្នករាយការណ៍ព័ត៌មានក្នុងស្រុកថាក្រុមហ៊ុនមិនមានទំនាក់ទំនងជាមួយនឹងឈ្មោះសេងនីទេ។[230]

ក្រុមហ៊ុនកសិកម្មHLH ត្រូវបានគេរាយការណ៍ថាបានជាប់ពាក់ព័ន្ធក្នុងជម្លោះដីធ្លីជាមួយនឹងអ្នកភូមិក្នុងខេត្តកំពង់ស្ពឺចាប់តាំងពីឆ្នាំ2010 និងត្រូវបានចោទប្រកាន់ដោយសហគមន៍ពីបទលួចកាប់ឈើខុសច្បាប់ក្នុងដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ក្នុងឆ្នាំ 2013។[231] របាយការណ៍ឆ្នាំ2012មួយរបស់អ្នកឆ្លើយឆ្លងព័ត៌មានពិសេសអង្គការសហប្រជាជាតិលើស្ថានការសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជាបាននិយាយលម្អិតថាតើក្រុមហ៊ុននេះបានចាប់ផ្តើមមានជម្លោះជាមួយនឹងសហគមន៍ជនជាតិភាគតិចស្ទួយដោយ ក្រុមហ៊ុននេះបានបញ្ជូលទឹកឲ្យជន់លិចដីស្រែចម្ការកសិកម្មរបស់ពួកគេនិងបានធ្វើឲ្យកខ្វក់ប្រភពទឹកក្នុងមូលដ្ឋាន។[232]

ក្នុងខែមិថុនាឆ្នាំ2014 សម្ព័ន្ធសាខាពេញសិទ្ធិរបស់ក្រុមហ៊ុនHLHគ្រុបគឺក្រុមហ៊ុនដឺឡូតធីសអភិវឌ្ឍន៍ D'Lotus Development បានចុះកិច្ចព្រមព្រៀងមួយក្នុងការទិញដីមួយផ្នែកដែលធ្លាប់ជាបឹងកក់ពីក្រុមហ៊ុនឯកជនឈ្មោះ ស៊ូកាគូ Shukaku Inc ដោយល្មើសនឹងច្បាប់ភូមិបាលប្រទេសកម្ពុជាដែលហាមឃាត់ម្ចាស់សម្បទានដីធ្លីមួយពីការលក់ដីបន្តដល់ក្រុមហ៊ុនមួយផ្សេងទៀត។[233]។សំណុំរឿងរំលោភដីធ្លីមួយដែលល្បីជាងគេក្នុងចំណោមសំណុំរឿងជាច្រើនក្នុងប្រទេសកម្ពុជា គឺការបែកចែកលក់ដីបឹងកក់ដល់ក្រុមហ៊ុនស៊ូកាគូដែលជាកម្មសិទ្ធរបស់ព្រឹទ្ធសភាលោកឡៅម៉េងឃិននិងភរិយារបស់លោកឈ្មោះជឹងសុភាព ដែលបាននាំឲ្យមានការ ជម្លាសប្រជាជនចំនួន4000គ្រួសារចេញដោយខុសច្បាប់។ ជាលទ្ធផល ក្នុងឆ្នាំ2011 ធនាគារពិភពលោកបានព្យួររាល់គ្រប់ការផ្តល់ហិរញ្ញប្បទានថ្មីៗដោយផ្ទាល់ដល់ប្រទេសកម្ពុជា។[234] ដោយប្រឈមមុខនឹងការជំទាស់តវ៉ាខ្លាំងពីសំណាក់ពលរដ្ឋសហគមន៍ បឹងកក់និងសង្គមស៊ីវិល ធនាគារពិភពលោកបានប្តូរត្រឡប់ការសម្រេចចិត្តនេះក្នុងខែ ឧសភាឆ្នាំ2016ទោះបីជាសមាជិក សហគមន៍ដែលរងផលប៉ះពាល់ជាច្រើនក្នុងតំបន់នេះនៅមិនទាន់បានទទួលការទូទាត់ប្រាក់ឬសំណងសមរម្យសម្រាប់ការបាត់បង់របស់ពួកគេនៅឡើយក៏ដោយ។[235]

អង្គការគ្លូបលវីតណែសបានដាក់ការចោទប្រកាន់ទាំងនេះទៅលើក្រុមហ៊ុនកសិកម្មHLH ក្នុងលិខិតរបស់ពួកយើងក្នុងខែធ្នូឆ្នាំ2015។ ជាការឆ្លើយតប ក្រុមហ៊ុនHLHគ្រុបបានបញ្ជាក់ថាក្រុមហ៊ុន D"Lotus Development បានចូលរួមចុះកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនស៊ូកាគូ ដើម្បីទទួលបានដីនោះ។ លិខិតនោះក៏បាននិយាយដែរថាក្នុងកំឡុងពេលដំណើរការការចរចារលើករណីប្រជាពលរដ្ឋបឹងកក់គឺមិនថាក្រុមហ៊ុនHLHឬ D"Lotus Development មានទំនាក់ទំនងពាក់ព័ន្ធជាមួយនឹងគាត់ឬលោកហ៊ុនសែនទេ។ កិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនស៊ូកាគូនោះគឺជាក់ស្តែងត្រូវបានបញ្ចប់កាលពីខែធ្នូឆ្នាំ2014មកម្លេះ *"ដោយសារតែបញ្ហាពាណិជ្ជកម្ម"*។ លិខិតរបស់ក្រុមហ៊ុនមិនបានយោងទៅលើការពិតដែលថាប្រសិនបើកិច្ចព្រមព្រៀងនោះនៅតែមានបន្តទៅមុខ នោះវាអាចនឹងខុសច្បាប់។

ឈ្មោះ ហ៊ុនសេងនី ក៏ទំនងដូចជាមានការជាប់ពាក់ព័ន្ធជាមួយនឹងរោងចក្រសំលៀកបំពាក់ SL Garment ដែលកម្មកររោងចក្រអះអាងថាពួកគេត្រូវបានប្រាប់ថាគាត់គឺជានាយកចាត់ការទូទៅរបស់ក្រុមហ៊ុន។ ក្នុងឆ្នាំ2013 សន្តិសុខឯកជនចំនួន75នាក់មកពីសាខាសន្តិសុខក្រុមហ៊ុនសេងនីគឺក្រុមហ៊ុន Garuda Group ត្រូវបានបញ្ជូនទៅកាន់រោងចក្រដើម្បីទប់ទល់ជាមួយកូដកម្មរបស់កម្មករ។[236] មន្ត្រីសហជីពកម្មករបានចោទប្រកាន់សន្តិសុខក្រុមហ៊ុនហ្គារ៉ូដា Garuda ពីបទគំរាមគំហែងនិងប្រើអំពើរហឹង្សាប្រឆាំងនឹងកម្មករដែលធ្វើកូដកម្ម។[237] ក្នុងខែមេសាឆ្នាំ2016 ការស៊ើបអង្កេតមួយត្រូវបានធ្វើឡើងដោយអង្គការអភិរក្សមួយនិងបានបោះពុម្ពផ្សាយក្នុងសារព័ត៌មានអន្តរជាតិ ដោយចោទប្រកាន់រោងចក្រសំលៀកបំពាក់SL ថាបានដុតកំទេចឈើខុសច្បាប់ដែលរឹបអូសបានពីតំបន់ការពារដើម្បីកំដៅទឹកសម្រាប់ម៉ាស៊ីនបោកគក់សំលៀកបំពាក់និងការស្ទីម។[238]

យោងតាមទិន្នន័យរបស់ក្រសួងពាណិជ្ជកម្ម ឈ្មោះសេងនី ក៏មានចំណែកភាគហ៊ុន* 50ភាគរយក្នុងក្រុមហ៊ុនវិនិយោគអ៊ែតវូតគ្រុប Attwood Investment Group ផងដែរ។[239] ក្រុមហ៊ុននេះត្រូវបានគ្រប់គ្រងដោយអ្នកជំនួញស្រីដែលកាក់កបម្នាក់គឺអ្នកស្រី លឹមឈីវហូនិងត្រូវបានបង្ហាញដោយអង្គការគ្លូបលវីតណែសថាមានការជាប់ពាក់ព័ន្ធនឹងដំណើរការរត់ពន្ធមួយដែលមានពាក់ព័ន្ធជាមួយនឹងឈើយោជាក្នុងឆ្នាំ2007។ សារព័ត៌មានក្នុងស្រុកបានរាយការណ៍ក្នុងឆ្នាំ2009ថាអាជ្ញាធរខេត្តព្រះសីហនុបានចោទប្រកាន់ក្រុមហ៊ុនពីបទបូមខ្សាច់រាប់ម៉ឺនតោនដោយខុសច្បាប់ដោយប្រើប្រាស់កប៉ាល់ដឹកខ្សាច់ដែលគ្មានច្បាប់អនុញ្ញាតិ។ ប្រជាជនមូលដ្ឋានបានអះអាងថាការបូមខ្សាច់នោះបាននឹងកំពុងតែបំផ្លិចបំផ្លាញទិន្នផលត្រីនិងមានផលប៉ះពាល់ជាអវិជ្ជមានដល់ការប្រកបរបរចិញ្ចឹមជីវិតរបស់ពួកគេ ជាការចោទប្រកាន់ដែលក្រុមហ៊ុននេះបានបដិសេធ។[241]

នៅពេលសរសេរនេះ អង្គការគ្លូបលវីតណែសមិនបានដឹងថាមានការស៊ើបអង្កេតណាមួយដោយអាជ្ញាធរចំពោះការចោទប្រកាន់នេះទេ នេះមិននិយាយដល់វិធានការណ៍ការថ្កោលទោសដែលត្រូវបានចាត់ប្រឆាំងទៅនឹងជនល្មើសខុសច្បាប់ផង។

*សូមយោងទៅរកការធ្វើបច្ចុប្បន្នភាពដែលបានដាក់សញ្ញាផ្កាយនៅទំព័រទី 19

## ការទាញយកប្រយោជន៍ពីនិទ្ទណ្ឌភាពផ្ទាល់ខ្លួន

ដោយសារតែព័ត៌មានចំពោះភាពជាកម្មសិទ្ធរបស់ក្រុមហ៊ុនក្នុងប្រទេសកម្ពុជាមិនសូវមានគ្រប់គ្រាន់ វាហាក់ដូចជាមិនមានអ្វីគួរឲ្យភ្ញាក់ផ្អើលទេដែលថាប្រជាជនកម្ពុជាមិនធ្លាប់បានចាប់ឲ្យគ្រួសារត្រកូលហ៊ុនទទួលខុសត្រូវចំពោះសកម្មភាពខុសច្បាប់នានារបស់ក្រុមហ៊ុនដែលពួកគេមានការពាក់ព័ន្ធជាមួយជាពិសេសនៅពេលដែលការពាក់ព័ន្ធនោះត្រូវបានបិទបាំង។ ទោះជាយ៉ាងណាក៏ដោយ កម្រិតនៃនិទ្ទណ្ឌភាពដែលត្រូវបានប្រើប្រាស់ដោយគ្រួសារនេះលាតសន្ធឹងបានយ៉ាងល្អកាត់ចូលក្នុងក្រុមហ៊ុនដែលរកស៊ីខុសច្បាប់ក្នុងការ បិទបាំងបទល្មើសនានាដែលត្រូវបានធ្វើដោយសមាជិកគ្រួសារនេះជាលក្ខណៈបុគ្គល។

មនុស្សបីនាក់ដែលមានប្រវត្តិដូចខាងក្រោមផ្តល់ជាឧទាហរណ៍ចំពោះទីដែលសមាជិកគ្រួសារនេះមើលទៅដូចជាបានរួចខ្លួនចំពោះបទល្មើសឧក្រិដ្ឋធ្ងន់ធ្ងរដែលគេបានប្រព្រឹត្ត ក៏ប៉ុន្តែផ្ទុយទៅវិញពួកគេបែរជាត្រូវបានទទួលនូវងារជាកិត្តយសឬតំណែងដ៏មានអំណាចក្នុងរចនាសម្ព័នរដ្ឋក៏ដូចជាការគ្រប់គ្រងដើម្បីបង្កើនការក្តោបក្តាប់មុខជំនួញជាច្រើនរបស់ពួកគេ។



- ក្មួយប្រុសរបស់លោកហ៊ុនសែនគឺលោក ហ៊ុន តូ ត្រូវបានជាប់ឈ្មោះថាជា'អ្នករត់ពន្ធថ្នាំញៀនដ៏ធំជាងគេ' ក្នុងបទសម្ភាសន៍ដែលត្រូវបានធ្វើឡើងដោយអង្គការគ្លូបបិលវីតណែស ជាមួយនិងប្រភពដែលអាចគួរទុកចិត្តបានក្នុងឆ្នាំ2006។[242] ការស៊ើបអង្កេតដូចគ្នានេះដែរក៏បានបង្ហាញថាគាត់ធ្លាប់មានការជាប់ពាក់ព័ន្ធទៅនឹងបណ្តាញក្រុមកាប់ឈើខុសច្បាប់ដ៏ធំរបស់ប្រទេសកម្ពុជាផងដែរនៅពេលនោះ។[243] លោក ហ៊ុន តូ នៅពេលនោះបានទទួលការចាប់អារម្មណ៍ជាសាធារណៈក្នុងឆ្នាំ 2012 នៅពេលដែលសារព័ត៌មានបានរាយការណ៍ជាថ្មីម្តងទៀតដោយភ្ជាប់រូបគាត់ទៅនឹងការជួញដូរថ្នាំញៀនប្រភេទណាកូទីនដែលមានតម្លៃជាង1កោដិលានដុល្លាសហរដ្ឋអាមេរិកទៅកាន់ប្រទេសអូស្រ្តាលី ដែលការចោទប្រកាន់ទាំងនេះត្រូវបានគាត់បដិសេធ។[244] The សារព័ត៌មាន The Age បានចោទប្រកាន់ថាលោក ហ៊ុន តូ ស្ថិតក្នុងប្រធានបទនៃការស៊ើបអង្កេតអស់រយៈពេលជាច្រើនឆ្នាំដោយ គណៈកម្មាការប្រឆាំងបទល្មើសឧក្រិដ្ឋប្រទេសអូស្រ្តាលីក្នុងការជួញដូរថ្នាំញៀនប្រភេទម្សៅហេរ៉ូអ៊ីននិងការលាងលុយកខ្វក់ ខណៈដែលថ្នាំញៀនត្រូវបានរត់ពន្ធជាលក្ខណៈដឹកឈើតាមកប៉ាល់។ ផែនការរបស់ប្រទេសអូស្រ្តាលីក្នុងការចាប់ខ្លួននិងសួរចម្លើយលោកតូក្នុងទីក្រុងមែលប៊ីន ត្រូវបានបង្វែរវិញនៅពេលដែលក្រសួងការបរទេសអូស្រ្តាលីបានបដិសេធមិនឲ្យវីសាដល់គាត់ដោយផ្អែកលើមូលដ្ឋានដែលថាការចាប់ខ្លួនគាត់ដោយប៉ូលីសអូស្រ្តាលីអាចបណ្តាលឲ្យមាន "ឧប្បទ្ទវហេតុទំនាក់ទំនងការទូត"។[245]



McLaren P1. រូបថតទទួលបានពីទំព័រហ្វេសប៊ុករបស់ ហ៊ុន តូ។

ដោយត្រូវបានគេស្គាល់ថាជាមនុស្សដែលចូលចិត្តសប្បាយហ៊ឺហា លោកហ៊ុន តូ ត្រូវបានគេនិយាយថាមានកម្មសិទ្ធរថយន្តទំនើប ដែលតាមដឹងថារួមមានទាំងរថយន្តកៃច្នៃម៉ាក McLaren P1 ដែលមានតម្លៃប៉ាន់ប្រមាណថាលើសពី1លានដុល្លាសហរដ្ឋអាមេរិក។[246] គាត់ក៏មានពាក្យចចាមអារ៉ាមដែរថាជាម្ចាស់កម្មសិទ្ធមណ្ឌលកំសាន្តរាត្រីពីមុនសម្រាប់កូនអ្នកមានៗមកបណ្តែតអារម្មណ៍ "ក្លឹបរាត្រីស្ពាក" ក្នុងទីក្រុងភ្នំពេញនិងត្រូវបានចុះបញ្ជីថាជានាយកក្រុមហ៊ុនចំនួនបួននិងក៏ជាចាងហ្វាងក្រុមហ៊ុន LHR វិនិយោគអាស៊ីផងដែរ ដែលដំណើរការ បណ្តាញស្ថានីយប្រេងឥន្ទនៈដ៏ធំមួយទូទាំងប្រទេសកម្ពុជា។[247]



- **ឌី ព្រឹម** ដែលជាបងប្អូនជីដូនមួយរបស់លោកហ៊ុនសែនត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារចំនួនពីរឆ្នាំកន្លះក្នុងឆ្នាំ 2011 ពីបទសូកប៉ាន់មន្ត្រីរាជការក្នុងទឹកប្រាក់ចំនួន 200,000 ដុល្លាដើម្បីក្លែងបន្លំកិច្ចសន្យាលើដីមួយកន្លែង។ ឯកសារក្លែងបន្លំនោះបានផ្តល់នូវភាពជាកម្មសិទ្ធដល់ឈ្មោះ ព្រឹម លើដីចំនួន5.6ហិកតាក្នុងទីក្រុងភ្នំពេញដែលតាមការពិតគឺជាកម្មសិទ្ធរបស់ស្ត្រីមេមាយវ័យចំណាស់ម្នាក់។[248] គ្មានដីកាចាប់ខ្លួនគាត់ដើម្បីដាក់គុកទេ នៅពេលនោះ តែផ្ទុយទៅវិញ ឈ្មោះ ឌី ព្រឹមនេះត្រូវបានផ្តល់ងារជាឧកញ៉ា។[249] តាមទម្លាប់ ការផ្តលមុខងារកិត្តយសដ៏កម្រ នេះគឺត្រូវបាន ផ្តល់ដោយព្រះមហាក្សត្រតែសព្វថ្ងៃនេះ ងារជាឧកញ៉ាគឺត្រូវបាន ផ្តល់ ដោយរដ្ឋាភិបាលដល់ជនណាដែលបរិច្ចាកប្រាក់ដែលមានចំនួនចាប់ពី US100,000$ ឡើងទៅដល់គណៈបក្សប្រជាជន កម្ពុជានិងធ្វើការប្តេជ្ញាចិត្តដោយមិនច្បាស់លាស់ថានឹងប្រើប្រាស់ទ្រព្យសម្បត្តិមួយផ្នែករបស់ខ្លួនចំពោះ"ការធ្វើអំពើរល្អកាន់តែច្រើន ជាងនេះ"។[250]

ក្នុងខែកុម្ភៈឆ្នាំ 2016 ភ្លាមៗបន្ទាប់ពីអង្គការគ្លូបបិលវីតណែសបានសរសេរលិខិតជូនដល់សមាជិកគ្រួសារត្រកូលហ៊ុនដើម្បីផ្តល់ឱកាសដល់ពួកគេក្នុងការឆ្លើយតបទៅនឹងការចោទប្រកាន់នានាដែលមាននៅក្នុងរបាយការណ៍នេះ ដែលមានសំណុំរឿងឈ្មោះ ឌី ព្រឹមដែលបានដាក់ជូនតុលាការឧទ្ធរណ៍ប្រទេសកម្ពុជានិងកំពុងតែបន្តនៅពេលសរសេរនោះ។ ក្នុងរយៈពេលប្រាំឆ្នាំចាប់តាំងពីការចោទប្រកាន់ត្រូវបានប្រមូលប្រឆាំងទៅនឹងឈ្មោះ ឌី ព្រឹមពេលនោះ ក៏ប៉ុន្តែភាគច្រើននៃដីដែលគាត់ត្រូវបានចោទប្រកាន់ថាខុសច្បាប់ នោះត្រូវបានលក់ចេញបាត់អស់ទៅហើយ។[251]



ហ៊ុន ជា ជាក្មួយប្រុសម្នាក់ទៀតរបស់លោកហ៊ុនសែន ត្រូវបានចាប់ខ្លួនក្នុងឆ្នាំ 2000 ជាមួយនិងបក្សពួកប្រាំមួយនាក់ទៀត ដែលពួកគេទាំងនោះសុទ្ធសឹងតែកូនរបស់មន្ត្រីរដ្ឋាភិបាល បន្ទាប់ពីមានការបាញ់បោះនៅក្នុងរង្គសាលមួយក្នុងទីក្រុងភ្នំពេញ។ លោកហ៊ុនសែនត្រូវបានដកស្រង់សម្តី ដែលនិយាយថា*"កូនទាំងអស់មិនថាកូននរណាទេ ទោះបីជាកូនរបស់ខ្ញុំក៏ដោយ ប្រសិនបើធ្វើខុសច្បាប់ ពួកគេត្រូវតែទទួលទោសតាមច្បាប់"*។ បួនថ្ងៃក្រោយមក លោកជា ត្រូវបានដោះលែងឲ្យនៅក្រៅឃុំ។[252]

រយៈពេលមិនដល់ពីរឆ្នាំ ក្រោយមក ក្នុងខែធ្នូឆ្នាំ 2011 លោកជានិងបងប្អូនជីដូនមួយច្បងរបស់គាត់គឺលោកហ៊ុន តូត្រូវបានចាប់ខ្លួនក្នុងការជាប់ពាក់ព័ន្ធនឹងការបាញ់បោះដែលបានកើតឡើងនៅឯភោជនីយដ្ឋានបៀរហ្គាឌិនពេលរាត្រីមួយក្នុងទីក្រុងភ្នំពេញ។ សារព័ត៌មានក្នុងស្រុកបានរាយការណ៍ថាឧប្បទ្ទវហេតុនេះគឺជាការប៉ុនប៉ងសម្លាប់មនុស្សយ៉ាងច្បាស់ក្រឡែតរបស់លោកហ៊ុន តូ។ ខ្មាន់កាំភ្លើងបានបាញ់ចំនួនជិតហាសិបគ្រាប់ដាក់លោកតូ លោកជានិងបក្សពួករបស់ពួកគេ ដែលក្នុងនោះរួមមានទាំងសាច់ញាតិរបស់លោកឧបនាយករដ្ឋមន្ត្រីស ខេងផងដែរ។ ប៉ូលីសមូលដ្ឋានបាននិយាយថាការបាញ់នោះគឺដោយសារតែ'ជម្លោះផ្ទាល់ខ្លួន'។[253] លោក ហ៊ុន ជាត្រូវបានចាប់ខ្លួននៅពេលនោះហើយលោកហ៊ុនសែនក្រោយមកក៏បានបញ្ជាឲ្យមានការចាប់ខ្លួនលោកហ៊ុន តូ ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ដែលបានកើតឡើងនោះ ដោយបានថ្លែងថា*"មិនថានរណាជានរណាទេ ក្មួយខ្ញុំ កូនខ្ញុំ ឬនរណាក៏ដោយ ត្រូវតែមានភាពស្មើគ្នាចំពោះមុខច្បាប់"*។ ពួកគេបានជាប់ឃុំឃាំងក្នុងគុកតិចជាងមួយសប្តាហ៍ ក៏ត្រូវបានដោះលែងវិញក្នុងពេលនោះដើម្បីចូលរួមពិធីមង្គលការរបស់បងប្អូនជីដូនមួយពួកគេគឺលោក ហ៊ុន ម៉ានិត ជាមួយនិងកូនស្រីរបស់លោកអគ្គនាយកនគរបាលជាតិហុក ឡង់ឌី។ សំណុំរឿងនេះត្រូវបាន បិទចោលពីរបីសប្តាហ៍បន្ទាប់មក ដែលតាមការចោទប្រកាន់គឺដោយសារតែកង្វះភស្តុតាងគ្រប់គ្រាន់។[254]

លោកជាក៏ត្រូវបានរាយការណ៍ថាមានការពាក់ព័ន្ធនឹងគ្រោះថ្នាក់ចរាចរបើកបុកហើយរត់ក្នុងឆ្នាំ 2008 ផងដែរដែលបណ្តាលឲ្យអ្នកបើកបរម៉ូតូបានស្លាប់បាត់បង់ជីវិត។ សំណុំរឿងនេះបានទៅដល់ដៃតុលាការក៏ប៉ុន្តែសាក្សីនានាដែលឃើញហេតុការណ៍ដែលតាមចោទបាននិយាយថាពូកគេបានឃើញលោកជាឈរនៅកន្លែងកើតហេតុបុកក្បែរយានជំនិះដែលសង្ស័យ។[255]

លោកជា ត្រូវបានតែងតាំងឲ្យក្លាយជាអគ្គមេបញ្ជាការឧត្តមសេនីយត្រីក្នុងជួរកងកម្លាំងប៉ូលីសកម្ពុជាក្នុងឆ្នាំ2014។[256]គាត់ក៏កាន់តំណែងជានាយកក្រុមហ៊ុនចំនួនបួនផងដែរក្នុងវិស័យពាណិជ្ជកម្មនិងដឹកជញ្ជូន។[257]

ខែមករាឆ្នាំ 2016 អង្គការគ្លូបបិលវីតណែសបានសរសេរទៅកាន់មនុស្សដែលបានរៀបរាប់ក្នុងជំពូក 20 ដោយស្នើរសុំឲ្យមានការឆ្លើយតបរបស់ពួកគេទាក់ទងទៅនឹងភស្តុតាងនានាដែលបាន បង្ហាញ។ មានតែឈ្មោះ សុខ ពុទ្ធីវុធទេដែលបានឆ្លើយតបលិខិតនោះ ក៏ប៉ុន្តែមិនបានឆ្លើយតបចំពោះការចោទប្រកាន់ជាក់លាក់ណាមួយដែលត្រូវបានធ្វើឡើងប្រឆាំងនឹងគាត់ទេ។ សារអេឡិចត្រូនិករបស់គាត់មានបញ្ជាក់ជូននៅលើទំព័រ20។ អង្គការគ្លូបបិលវីតណែសក៏បានសរសេរទៅក្រុមហ៊ុននានាដែលបានរៀបរាប់ខាងលើផងដែរក៏ប៉ុន្តែបានទទួលត្រឹមតែចម្លើយតបពីក្រុមហ៊ុនHLH គ្រុបប៉ុណ្ណោះដែលត្រូវបានសង្ខេបក្នុងទំព័រ24។

# ការដឹកនាំរបស់គ្រួសារត្រកូលហ៊ុន-ការពង្រឹងការគ្រប់គ្រងអំណាច

*“លោកនាយករដ្ឋមន្ត្រីហ៊ុនសែន កំពុងតែព្យាយាមលុបបំបាត់ចំណុចចន្លោះខ្វះខាតរវាងវិស័យនយោបាយនិងឯកជនដោយព្យាយាមបណ្តុះប្រើប្រាស់ទំនាក់ទំនងដែលមានប្រយោជន៍ជាមួយនិងឧកញ៉ាជំនួញដែលលេចធ្លោជាងគេនានារបស់ប្រទេស។ មេដឹកនាំជំនួញទាំងនេះចូលរួមជាប្រាក់កាស់ជាច្រើនដល់ គណៈបក្សកាន់អំណាចគឺគណៈបក្សប្រជាជនកម្ពុជា(CPP) ហើយលោកហ៊ុនសែនអាចពឹងពាក់ពួកគេក្នុងការផ្តល់មូលនិធិសប្បុរសធម៌និងគម្រោងការងារសាធារណៈនានានិងទាក់ទាញឲ្យមានការវិនិយោគបរទេស ជាសមិទ្ធិផលដែល គណៈបក្សប្រជាជនកម្ពុជាអាចទទួលបានលាភយសការ សរសើរ។ ជាការឆ្លើយតប ឧកញ៉ាជំនួញទាំងនោះទទួលបានមកវិញនូវភាពជឿជាក់និងភាពស្របច្បាប់ដោយសារមានការគាំទ្រពីលោកនាយករដ្ឋមន្ត្រី។ ទំនាក់ទំនងជានិមិត្តរូបទាំងនេះបង្ហាញពីបណ្តាញនៃឧកញ៉ាជំនួញតួអង្គនយោបាយ និងមន្ត្រីរដ្ឋាភិបាលនានាដែលបានបង្កើតឡើងក្នុង ប្រទេសកម្ពុជា ដែលជួយពង្រឹងវប្បធម៌និទ្ទណ្ឌភាពនិងដាក់កម្រិតលើដំណើរការកំណែទម្រង់ដូចជាអ្វីដែលលោកហ៊ុនសែនបានប្រកាសដោយខ្លួនឯងថា"សង្គ្រាមប្រឆាំងនឹងអំពើរពុករលួយ"។”*[258]

ដកស្រង់ចេញពីតេឡេក្រាមដែលមានចំណងជើងថា"ឧកញ៉ាដ៏កំពូលទាំងដប់របស់ប្រទេសកម្ពុជា" ដែលត្រូវបានបញ្ជូន ក្នុងឆ្នាំ2007ដោយស្ថានទូត អាមេរិកក្នុងទីក្រុងភ្នំពេញទៅទស្សនៈកិច្ច ក្រសួងរដ្ឋាភិបាលសហរដ្ឋអាមេរិកជាច្រើនក្នុងទីក្រុងវ៉ាស៊ីនតោន ឌីស៊ី Washington DC ។

ការក្តោបក្តាប់មុខជំនួញរបស់គ្រួសារត្រកូលហ៊ុនគឺជាផ្នែកនៃប្រព័ន្ធជំនួយគាំទ្រអំណាចមួយដ៏ទូលំទូលាយដែលពង្រីកខ្លួនបានយ៉ាងល្អហួសពីវិស័យឯកជនចូលទៅក្នុងស្ទើរគ្រប់ទិដ្ឋភាពក្នុងសង្គមកម្ពុជា។ ក្នុងកំឡុងពេលដែលលោកហ៊ុនសែនកាន់អំណាចជាងបីទសវត្សកន្លងមកនេះ ប្រព័ន្ធនេះត្រូវបានរក្សាតាមរយៈការដាក់បញ្ចូលនូវបក្សពួកនិយមការឃោសនាមនោគមវិជ្ជានយោបាយ ការបង្ក្រាប គាបសង្កត់និងការចងជាសម្ព័ន្ធមិត្តជាមួយនឹងពួកអ្នកមានទ្រព្យសម្បត្តិនានា។[259]

ជំពូកខាងក្រោមមើលហួសទៅលើការក្តោបក្តាប់វិស័យឯកជនរបស់គ្រួសារត្រកូលហ៊ុនដើម្បីពណ៌នាពីមធ្យោបាយសំខាន់ៗផ្សេងទៀតនានាដែលពួកគេរក្សាការគ្រប់គ្រង:

## ការិយាល័យសាធារណៈនិងកងកម្លាំងសន្តិសុខរដ្ឋ

នៅថ្ងៃទី10ខែមករាឆ្នាំ 2016 នៅក្នុងកិច្ចប្រជុំបិទទ្វារមួយរបស់គណៈបក្សប្រជាជនកម្ពុជា លោកហ៊ុនសែនបានព្រមានដល់មន្ត្រីរបស់លោកពីគ្រោះថ្នាក់នៃបក្សពួកនិយមដែលមានសម្រាប់រដ្ឋាភិបាលកម្ពុជានិងបានជំរុញឲ្យពួកគេដាក់សាច់ញាតិពួកគេឲ្យឆ្ងាយពីកិច្ចការរបស់ក្រសួង។[260]

ដោយសារតែកម្រិតខ្ពស់នៃអំពើរពុករលួយ អ្នកដែលមានតំណែងក្នុងការិយាល័យសាធារណៈអាចរួចខ្លួនជាមួយនឹងការប្រគល់ការងាររដ្ឋដល់សាច់ញាតិរបស់ពួកគេនិងគ្មាននរណាជាងគ្រួសារត្រកូលហ៊ុននោះទេ។ កត្តានេះមិនត្រឹមតែបង្ហាញថាពីការប្រាថ្នាចង់សម្របសម្រួលអំណាចប៉ុណ្ណោះទេក៏ប៉ុន្តែវាថែមទាំងបង្ហាញពីការមិនជឿទុកចិត្តកាន់តែជ្រៅដែលមានរវាងអ្នកមានទ្រព្យសម្បត្តិជាច្រើនរបស់កម្ពុជា។



### យោធា

កូនប្រុសច្បងរបស់លោកហ៊ុនសែនគឺលោក **ហ៊ុន ម៉ាណែត** ដែលត្រូវបានលើកសរសើរចំៗជារឿយៗថាជាអ្នកស្នងតំណែងបន្ទាប់ពីឪពុករបស់លោកនោះ គឺជាអគ្គមេបញ្ជាការជាន់ខ្ពស់ក្នុងជួរកងទ័ពនិងកាន់កាប់តំណែងចំនួនបួនសំខាន់ៗគឺ ជានាយរងអគ្គសេនាធិការកងយោធពលខេមរៈភូមិន្ទ ជាមេបញ្ជាការកងកម្លាំងពិសេសជាតិទទួលបន្ទុកប្រឆាំងអំពើភេរវកម្ម ជាអគ្គមេបញ្ជាការរងយោធានិងជាមេបញ្ជាការរងនៃអង្គភាពអង្គរក្សរបស់លោកនាយករដ្ឋមន្ត្រី។[261] អង្គភាពអង្គរក្សជាន់ខ្ពស់របស់លោកហ៊ុនសែនដែលមានសមាជិករាប់ម៉ឺននាក់ ធ្លាប់ត្រូវបានចោទប្រកាន់ជាយូរមកហើយថាបានរំលោភសិទ្ធិមនុស្សយ៉ាងសាហាវឃោរឃៅ។[262] នៅខែមិនាឆ្នាំ 1997 អង្គភាពនេះមានការជាប់ពាក់ព័ន្ធទៅនឹងការគប់គ្រាប់បែកដៃទៅលើការប្រមូលផ្តុំគ្នារបស់គណៈបក្សប្រឆាំងដែលក្នុងនោះមានមនុស្សចំនួន 16 នាក់បានស្លាប់បាត់បង់ជីវិតនិងច្រើនជាង150នាក់បានរងរបួស។[263] អង្គភាពនេះមានមុខងារជាកងកម្លាំងផ្ទាល់ខ្លួនរបស់លោកហ៊ុន សែននិងមានមុខងារចំបងគឺរក្សាការក្តោបក្តាប់អំណាចក្នុងដៃរបស់លោក។[264] ក្នុងឆ្នាំ2015 ទាហានបីនាក់មកពីអង្គភាពនេះបានវាយប្រហារយ៉ាងសាហាវឃោរឃៅទៅលើតំណាងរាស្ត្រគណៈបក្សប្រឆាំងពីររូបខណៈដែលពួកគេទាំងពីរបានចាកចេញពីរដ្ឋសភា។[265]



ប្អូនប្រុសកណ្តាលរបស់លោកម៉ាណែតគឺលោក ហ៊ុន ម៉ានិត ក៏មានតួនាទីជាអគ្គមេបញ្ជាការក្នុងជួរកងទ័ពផងដែរ។ ក្នុងឆ្នាំ2015 គាត់ត្រូវបានតំឡើងឋានន្តរស័ក្តជាប្រធានកងយោធពលខេមរៈភូមិន្ទ (RCAF) ផ្នែកអង្គភាពចារកម្មសម្ងាត់យោធាដ៏មានឥទ្ធិពល។[266] រឿងនេះត្រូវបានពណ៌នាដោយអ្នកអត្ថាធិប្បាយនយោបាយម្នាក់ក្នុងចំណោមអ្នកអត្ថាធិប្បាយជាច្រើនដែលមានការគោរពខ្ពស់បំផុតរបស់កម្ពុជាថាជាការប៉ុនប៉ងដោយលោកលោកនាយករដ្ឋមន្ត្រីក្នុងការពង្រឹងអំណាច។[267] ឈ្មោះ យឹម លាង ដែលជាបងថ្លៃប្រុសរបស់ឈ្មោះ ហ៊ុន ម៉ានី បានក្លាយជាឧត្តមសេនីយដ៏វ័យក្មេងជាងគេបង្អស់របស់ប្រទេសកម្ពុជាក្នុងជួរកងទ័ពអាកាសក្នុងឆ្នាំ 2002។[268] ក្នុងចលនាមួយផ្សេងទៀតក៏ត្រូវបានពណ៌នាដោយប្រភពមួយថាជាក្តោបក្តាប់អំណាចដោយលោកហ៊ុនសែនផងដែរ គាត់ត្រូវបានតែងតាំងធ្វើជាប្រធានអង្គភាពអង្គរក្សរបស់លោកព្រឹទ្ធសភាជាស៊ីមរហូតដល់ពេលដែលលោកជាស៊ីមបានទទួលមរណភាពក្នុងឆ្នាំ 2015។[269]



### ប៉ូលីស

កូនប្រសាររបស់លោកហ៊ុនសែនគឺលោក ឌី វិជ្ជា ដែលជាប្រមុខមន្ទីរសន្តិសុខកណ្តាលស្នងការប៉ូលីសជាតិ ដែលជាតំណែងដ៏មានអំណាចដែលដាក់គាត់ឲ្យទទួលខុសត្រូវលើអង្គភាពជាច្រើនរួមមានទាំងចារកម្មផ្ទៃក្នុងប្រទេសនិងមន្ទីរប្រឆាំងភេរវកម្មដែលបានដើរតួនាទីយ៉ាងសំខាន់មួយក្នុងការបង្ក្រាបនាពេលថ្មីៗនេះរបស់គណៈបក្សប្រជាជនទៅលើអ្នករិះគន់របស់ខ្លួន។[270] ក្មួយប្រុសលោកឈ្មោះ ហ៊ុន ជា ត្រូវបានតំឡើងឋានន្តរស័ក្តទៅជាអគ្គស្នងការប៉ូលីសផ្កាយមួយក្នុងឆ្នាំ2014 ទោះបីជាមានការប៉ះពាល់ទៅនឹងច្បាប់ក៏ដោយ។[271]





### នយោបាយ

ក្នុងឆាកនយោបាយ កូនប្រុសពៅគឺលោក ហ៊ុន ម៉ានី គឺជាតំណាងរាស្ត្រម្នាក់របស់គណៈបក្សប្រជាជនកម្ពុជាសម្រាប់ខេត្តកំពង់ស្ពឺ។[272] បងប្រុសរបស់លោកហ៊ុនសែនគឺលោក ហ៊ុន ណេង គឺជាអតីតអភិបាលខេត្តកំពង់ចាមនិងស្វាយរៀង ហើយសព្វថ្ងៃនេះកាន់តំណែងអមលោកហ៊ុន ម៉ានីក្នុងសភាថ្នាក់ទាបរបស់ប្រទេសកម្ពុជា។[273] បន្ទាប់ពីមានការចេញផ្សាយនូវរបាយការណ៍របស់អង្គការគ្លូបប៊លវីត ណែសឆ្នាំ 2007 ដែលរាយការណ៍ពី"មែកធាងគ្រួសារ" ដែលបានបង្ហាញថាតើសាច់ញាតិក្រុមគ្រួសាររបស់លោកហ៊ុនសែនបាននឹងកំពុងដឹកនាំក្រុមជួញដូរឈើខុសច្បាប់ដ៏មានអំណាចខ្លាំងជាងគេក្នុងប្រទេសកម្ពុជាបានដោយរបៀបណា ឈ្មោះនាងត្រូវបានរាយការណ៍ថាបាននិយាយថា "ប្រសិនបើពួកគេ (អង្គការគ្លូបប៊លវីតណែស)មកប្រទេសកម្ពុជា ខ្ញុំនឹងវាយសំពងពូកគេរហូតទាល់តែក្បាលរបស់ពួកគេត្រូវបែក"។[274]



កូនប្រុសរបស់លោក ហ៊ុន សែន ទាំងបីនាក់សុទ្ធតែបានទទួលអាហារូបករណ៍ ឬការបណ្តុះបណ្តាលពីយោធានៃសហរដ្ឋអាមេរិក។

## អាពាហ៍ពិពាហ៍ដើម្បីបង្កើតសម្ព័ន្ធភាព

ការរៀបអាពាហ៍ពិពាហ៍ដោយផ្សំផ្គុំ ទោះបីជាមានការថយចុះក៏ដោយ ក៏នៅតែមានកើតឡើងក្នុងសង្គមកម្ពុជា ដោយវាត្រូវបានគេប្រើប្រាស់សម្រាប់ជាមធ្យោបាយមួយក្នុងការបំពេញបង្គ្រប់ចំណងហិរញ្ញវត្ថុនិងគៀងគរគាំទ្រដល់សម្ព័ន្ធភាពនយោបាយ។ កូនទាំងប្រាំអ្នករបស់លោកហ៊ុនសែនត្រូវបានរៀបការជាមួយនឹងកូនអ្នកមានអំណាចនិងទ្រព្យសម្បត្តិស្តុកស្តម្ភរបស់កម្ពុជា ក៏ដូចជាក្មួយប្រុសនិងក្មួយស្រីជាច្រើនទៀតរបស់គាត់:

- កូនប្រុសច្បងរបស់លោកនាយករដ្ឋមន្ត្រីគឺលោក **ហ៊ុន ម៉ាណែត** បានរៀបការជាមួយនឹងឈ្មោះ ពេជ្រ ច័ន្ទមុន្នី ដែលជាកូនស្រីរបស់លោកពេជ្រសោភ័ណ្ឌ ជាសមាជិកម្នាក់ដ៏លេចធ្លោរបស់គណៈបក្សប្រជាជនកម្ពុជានិងជារដ្ឋលេខាធិការក្រសួងការងារ។[275]
- **ហ៊ុន ម៉ាណា** ជាកូនស្រីច្បងរបស់លោកហ៊ុនសែន បានរៀបការជាមួយនឹងលោកឌីវិជ្ជា ដែលជាកូនប្រុសរបស់លោកអគ្គស្នងការនគរបាលជាតិមុនដែលមានគេខ្លាចរអាបំផុតគឺលោក ហុកឡង់ឌី ។[276] កាលពីមុន លោកស្រីហ៊ុនម៉ាណាបានរៀបការជាមួយនឹងលោកម៉ឹង កុម្ភៈ ដែលជាកូនប្រុសរបស់លោកម៉ឹងសំផន ដែលជាឧត្តមសេនីយផ្កាយបីនិងជាប្រធានមន្ទីរក្រសួងការពារជាតិទទួលបន្ទុកផ្នែកភស្តុភារនិងហិរញ្ញវត្ថុ។[277] លោកវិជ្ជា ពីមុនបានរៀបការជាមួយនឹងក្មួយស្រីរបស់លោកហ៊ុនសែនឈ្មោះ ហ៊ុនចន្ថា។[278]
- **ហ៊ុន ម៉ានិត** ដែលជាកូនប្រុសកណ្តាលរបស់លោកហ៊ុនសែន បានរៀបការជាមួយនឹងឈ្មោះ ឌី ចិន្តាវីដែលជាប្អូនស្រីរបស់លោកឌី វិជ្ជា។[279]
- កូនប្រុសពៅគឺលោក ហ៊ុន ម៉ានី បានរៀបការជាមួយនឹងកូនស្រីរបស់លោកឧបនាយករដ្ឋមន្ត្រីយឹមឆាយលីក្នុងឆ្នាំ 2004។[280] ការរៀបអាពាហ៍ពិពាហ៍នោះត្រូវបានរាយការណ៍ដោយសារព័ត៌មានក្នុងស្រុកថាមានភាពហឹកហ៊ាក់គគ្រឹកគគ្រេង ដោយមានមន្ត្រីយោធាប៉ូលីសជាច្រើនបានចូលរួម ហើយមន្ត្រីប៉ូលីសជាច្រើននិងរថយន្តពន្លត់អគ្គីភ័យពីរគ្រឿងត្រូវបានដាក់ប្រចាំការដើម្បីធានាថាភ្ញៀវកិត្តយសដែលចូលរួមចំនួន3000នាក់និងយានជំនិះរបស់ពួកគេជាច្រើនរយគ្រឿងត្រូវបានករក្សាទុកដោយមានសុវត្ថិភាព។[281]
- កូនស្រីពៅឈ្មោះ **ហ៊ុន ម៉ាលី** បានរៀបការជាមួយនឹងឈ្មោះសុខ ពុទ្ធិវុធដែលជានាយកប្រតិបត្តិរបស់ក្រុមហ៊ុនសោម៉ានិងជាកូនប្រុសរបស់លោកសុខអាន ដែលក៏ជាឧបនាយករដ្ឋមន្ត្រីនិងជាសម្ព័ន្ធមិត្តដ៏យូរអង្វែងរាប់ឆ្នាំរបស់លោកហ៊ុនសែនផងដែរ។[282]
- ក្មួយស្រីរបស់លោកហ៊ុនសែន ឈ្មោះ **ហ៊ុន គឹមឡេង** បាបរៀបការជាមួយនឹងស្នងការប៉ូលីសជាតិលោក នេត សាវឿន។[283]
- ប្អូនប្រុសរបស់គឹមឡេង ឈ្មោះ **ហ៊ុនសៀងហេង** បានរៀបការជាមួយនឹងឈ្មោះ សុខ សុភ័ក្រ ដែលជាកូនស្រីរបស់លោកសុខផល ជាប៉ូលីសចារកម្មសម្ងាត់ដ៏មានអំណាចម្នាក់និងបច្ចុប្បន្នជាប្រធានមន្ទីរអន្តោប្រវេសន៍កម្ពុជា។[284]

ការរៀបការទាំងនេះមានផលប្រយោជន៍ទៅវិញទៅមកទាំងសងខាងនិងជួយឲ្យគ្រួសារត្រកូលហ៊ុនរក្សាបាននូវការគ្រប់គ្រងលើឆាកនយោបាយប្រទេសកម្ពុជា សេដ្ឋកិច្ចនិងជាចុងក្រោយសង្គម។ វាគឺជាការគ្រប់គ្រងដែលគ្រួសារនេះមិនរំពឹងថានឹងបែកខ្វែកគ្នាក្នុងពេលណាមួយឆាប់ៗនេះទេ។ លោក ហ៊ុនសែនដែលសព្វថ្ងៃមានអាយុហុកសិបបីឆ្នាំនិងជាមេដឹកនាំទី7ក្នុងលោកដែលកាន់អំណាចយូរជាងគេបានថ្លែងក្នុងឆ្នាំ 2013ថា គាត់មានផែនការបន្តនៅកាន់អំណាចរហូតទាល់តែគាត់មានអាយុ74ឆ្នាំ។[285] វាត្រូវបានសន្មត់ទុកជាយូរមកហើយថាគាត់កំពុងតែហ្វឹកហ្វឺនកូនប្រុសច្បងរបស់គាត់គឺលោកហ៊ុនម៉ាណែតឲ្យក្លាយទៅជាអ្នកស្នងតំណែងរបស់គាត់។[286] តែទោះជាយ៉ាងណាក៏ដោយ ក្នុងខែធ្នូឆ្នាំ2015 លោកហ៊ុន ម៉ានីក៏បានបង្ហាញពីបំណងរបស់គាត់ក្នុងការក្លាយជានាយករដ្ឋមន្ត្រីបន្ទាប់ផងដែរ។[287] ទាំងពីរផ្លូវនេះ វាទំនងហាក់ដូចជាគ្រួសារត្រកូលហ៊ុនមានគម្រោងក្នុងការដឹកនាំប្រទេសកម្ពុជាសម្រាប់ទសវត្សបន្តបន្ទាប់ខាងមុខទៀតហើយពួកគេបន្តរៀបចំរួចជាស្រេចនូវរចនាសម្ព័ន្ធនិងបណ្តាញទំនាក់ទំនងនានាដើម្បីធានាថាពួកគេស្ថិតនៅក្នុងអំណាចដដែល។

## សប្បុរសធម៌ /បញ្ចប់ ក្នុងផ្ទះ

*"គណ:បក្សប្រជាជនកម្ពុជាសព្វថ្ងៃនេះកំពុងតែធ្វើគម្រោងរាប់ពាន់ម៉ឺនគម្រោង មិនថាគម្រោងតូចមិនថាគម្រោងធំដែលក្នុងនោះថវិការដែលក្តីរៅបានមកពីថវិការជាតិគឺបានមកពីសមាជិកគណ:បក្សប្រជាជនកម្ពុជាដែលរួមមានទាំងមន្ត្រីយោធា កសិករ ជំនួញនិងអ្នកវិនិយោគទុន ដែលបានបូមបញ្ចូលធនធានទាំងឡាយចូលទៅក្នុងគម្រោងទាំងនេះដើម្បីជួយប្រជាជន។ នៅពេលមានការបោះឆ្នោតថ្នាក់ជាតិមកដល់ ប្រសិនបើប្រជាជនមិនបោះឆ្នោតជូនគណ:បក្ស(ប្រជាជនកម្ពុជា)ទេនោះ នោះនឹងមានការបាត់បង់នូវកម្លាំងចិត្តនិងមានការឈប់ផ្តល់ឲ្យ។ គ្រប់គម្រោងទាំងអស់នឹងត្រូវបានបញ្ចប់ មិនថាជាគម្រោងដូចជាការបូមទឹកបញ្ចូលស្រែដែលរាំងស្ងួត ខ្ញុំចំណាយប្រាក់រាប់លានរយដុល្លាសម្រាប់ទូទាត់លើគម្រោងនេះ រួមមានទាំងការចិញ្ចឹមកុមារកំព្រា កុមារពិការនិងអង្គការផ្សេងៗជាច្រើនទៀត។ ខ្ញុំមិនដែលធ្លាប់ប្រើប្រាស់ ថវិការជាតិទេ។"*[288]

**អត្ថបទដកស្រង់ចេញពីការថ្លែងជាសាធារណ:ដោយលោកហ៊ុនសែននៅថ្ងៃទី 5ខែមិនាឆ្នាំ 2013 មិនដល់4ខែមុនពេលការបោះឆ្នោតទូទៅថ្នាក់ជាតិខែកក្កដាឆ្នាំ2013ដែលគណ:បក្សប្រជាជន កម្ពុជាសឹងតែនឹងចាញ់ឆ្នោតទៅហើយ។**

សមាជិកគ្រួសាត្រកូលហ៊ុនក៏ទទួលខុសត្រូវគ្រប់គ្រងអង្គការជំនួយសប្បុរសធម៌ជាច្រើនផងដែរ។ ក៏ដូចជាការផ្តល់ភាពស្របច្បាប់និងការបង្ហាញការអាណិតអាសូរទៅលើគ្រួសារ ការរៀបចំចាត់ចែងនេះអនុញ្ញាតិឲ្យពួកគេរៃអង្គាសមូលនិធិសម្រាប់គម្រោងមនុស្សធម៌ដូចជាការជីកអណ្តូងទឹកនិងការជួសជុលស្ពាននិងសាលារៀន 'ការងារល្អៗ'ដែលអាចរួមចំណែកដល់គណ:បក្សដែលកំពុងកាន់អំណាច។[289]

លោកជំទាវទីមួយដើរតួនាទីយ៉ាងសំខាន់ក្នុងប្រកទ្ទាដែលកំពុងវិលជុំវាងសប្បុរសធម៌និងនយោ បាយ។ លោកស្រី ប៊ុន រ៉ានី គឺជាប្រធានកាកបាទក្រហមកម្ពុជា (CRC) ដែលជាអង្គការសប្បុរសធម៌មួយដ៏ធំជាងគេក្នុងប្រទេសកម្ពុជា។[290] ជាសមាជិកមួយនៃសហព័ន្ធកាកបាទកក្រហមអន្តរជាតិ កាកបាទកក្រហមកម្ពុជាអះអាងពីគោលការណ៍ស្នូលនៃបណ្តាញជាអព្យាក្រិតនិងឯករាជ្យប៉ុន្តែធ្វើសកម្មភាពបានតិចតួចដើម្បីបិទបាំងពីភាពស្មោះត្រង់ផ្នែកនយោបាយរបស់ខ្លួននិងបាននឹងកំពុងបង្ហាញថាជា"បណ្តាញផ្នែកមនុស្សធម៌"នៃគណ:បក្សប្រជាជនកម្ពុជា។[291] វាមានមុខងារជាអតិសុខុមប្រាណមួយរបស់ប្រព័ន្ធក្តោបក្តាប់អំណាចរបស់លោកហ៊ុនសែននិង គណ:កម្មាធិការកណ្តាលរបស់ខ្លួនដែលមានសមាសភាពជាដៃគូជំនួញរបស់គ្រួសារត្រកូលហ៊ុន មន្ត្រីគណ:បក្សប្រជាជនកម្ពុជានិងសមាជិកគ្រួសាររបស់ពួកគេ។[292]

ក្នុងខែតុលាឆ្នាំ2013 ក្រោយពីមានទឹកជំនន់ធ្ងន់ធ្ងរដែលបានធ្វើឲ្យមានការជម្លាសប្រជាជនរាប់ម៉ឺនគ្រួសារ លោកស្រីរ៉ានីបាននឹងកំពុងចែកអង្ករជាច្រើនបាវនិងសម្ភារ:ផ្គត់ផ្គង់ដទៃផ្សេងទៀតជាច្រើនដែលត្រូវបានផ្តល់ដោយម្ចាស់ជំនួយកាកបាទក្រហមកម្ពុជា (CRC)នៅឯព្រឹត្តការណ៍កាកបាទក្រហមកម្ពុជានៅមុខមនុស្សរាប់ម៉ឺននាក់។ ថ្លែងទៅកាន់ហ្វូងមហាជន និងក្រោយពីមានការរិះគន់ជាចំហរខ្លាំងក្លាចំពោះគណ:បក្សប្រឆាំង លោកស្រីរ៉ានីបានមានប្រសាសន៍ថា *"នៅពេលដែលមានគ្រោះទឹកជំនន់ឬឧប្បទ្ទហេតុណាមួយផ្សេងទៀត ពុកម៉ែបងប្អូនបានឃើញហើយថាមិនមានគណ:បក្សនយោបាយណាមកជួយបងប្អូននៅទីនេះទេ គឺមានតែគណ:បក្សប្រជាជនកម្ពុជាតែមួយគត់ នេះដោយសារតែគ្រប់មន្ត្រីរាជការទាំងអស់គឺមកពីគណ:បក្សប្រជាជនកម្ពុជា"*។[293]

ចន្លោះឆ្នាំ 2006 និង ឆ្នាំ2009 ចំណូលរបស់កាកបាទក្រហមកម្ពុជាមានទឹកប្រាក់ចំនួន 27.8 លានដុល្លាសហរដ្ឋអាមេរិក ដែល%71នៃទឹកប្រាក់នេះ (គឺស្មើនឹងក្រោម20លានដុល្លាបន្តិចបន្តួចប៉ុណ្ណោះ)បានមកពីប្រភពនានាក្នុងស្រុករួមមានទាំងលោកហ៊ុនសែននិងអ្នកឧកញ៉ាជំនួញនានាដែលមានទំនាក់ទំនងជាមួយនឹងគ្រួសាររបស់គាត់។[294] ស្របពេលដំណាលគ្នានោះដែរ កាកបាទក្រហមកម្ពុជាបានទទួលទឹកប្រាក់សរុបចំនួន8លានដុល្លាសហរដ្ឋអាមេរិកពីម្ចាស់ជំនួយអន្តរជាតិរួមមានទាំងគណ:កម្មាការកាកបាទក្រហមអន្តរជាតិ សហព័ន្ធកាកបាទក្រហមនិងអត្តច័ន្ទក្រហមអន្តរជាតិ អង្គការUNICEF អង្គការUNDPនិងដៃគូរកាកបាទក្រហមថ្នាក់ជាតិចំនួន11ផ្សេងទៀត រួមទាំង ទឹកប្រាក់ចំនួន1លានដុល្លាសហរដ្ឋអាមេរិកបានមកពីកាកបាទក្រហមអូស្រ្តាលីតែមួយគត់។[295]

ស្របពេលដំណាលគ្នានោះដែរ កាកបាទក្រហមកម្ពុជាបានទទួលទឹកប្រាក់សរុបចំនួន8លានដុល្លាសហរដ្ឋអាមេរិកពីម្ចាស់ជំនួយអន្តរជាតិរួមមានទាំងគណ:កម្មាការកាកបាទក្រហមអន្តរជាតិ សហព័ន្ធកាកបាទក្រហមនិងអត្តច័ន្ទក្រហមអន្តរជាតិ អង្គការUNICEF អង្គការUNDPនិងដៃគូរកាកបាទក្រហមថ្នាក់ជាតិចំនួន11ផ្សេងទៀត រួមទាំង ទឹកប្រាក់ចំនួន1លានដុល្លាសហរដ្ឋអាមេរិកបានមកពីកាកបាទក្រហមអូស្រ្តាលីតែមួយគត់។

សមាជិកសភាមកពីគណ:បក្សប្រជាជនកម្ពុជានិងជាកូនប្រុសពៅរបស់លោកហ៊ុនសែនគឺលោក ហ៊ុន ម៉ានី គឺជាប្រធានសហជីពសហព័ន្ធយុវជនកម្ពុជា (UYFC) ដែលជាអង្គការយុវជនដ៏ធំជាងគេបង្អស់មួយរបស់ប្រទេសកម្ពុជា។[296] ក្នុងនោះផងដែរត្រូវបានរាយការណ៏មកថាក៏បានដាក់បញ្ចូលបងថ្លៃប្រុសរបស់លោកហ៊ុនម៉ានីគឺលោកឌី វិជ្ជា ជាសមាជិកដែលមានឋានៈតួនាទីខ្ពស់ផងដែរ សហជីពសហព័ន្ធ យុវជនកម្ពុជា (UYFC) ត្រូវបានពណ៌នាដោយអ្នកអត្ថាធិប្បាយនយោបាយថា*"ជាអង្គការចាត់តាំងនយោបាយរបស់គណបក្សប្រជាជនកម្ពុជា"*ហើយត្រូវបានមើលឃើញយ៉ាងទូលំទូលាយថាជាដៃជើងយុវជនរបស់ខ្លួន ទោះបីជាការអះអាងរបស់អង្គការនេះថាមិនលំអៀងទៅរកគណបក្សនយោបាយណាមួយក៏ដោយ។[297] ក្នុងខែវិច្ឆិកាឆ្នាំ2015 លោកម៉ានីត្រូវបានផ្តល់រង្វាន់កិត្តយសសន្តិភាពហ្គូសស៊ី Gusi Peace Prize ដែលនៅក្នុងគេហទំព័ររបស់ខ្លួនបានអះអាងថា*"ជាកិត្តយសនិងការគោរពដែលត្រូវបាន ទទួលពានរង្វាន់ណូប៊ែលសន្តិភាពរបស់ប្រទេសណេករ៉េ និងជាពានរង្វាន់កិត្តយសរបស់សហរដ្ឋអាមេរិក the Pulitzer of the United States of America សម្រាប់ការងាររបស់គាត់ក្នុង "ការដឹកនាំយុវជននិងមនុស្សធម៌។"*[298] លោកហ៊ុន ម៉ានី បានចាកចេញពីទីក្រុងម៉ានីឡាប្រទេសហ្វីលីពីននិង ត្រឡប់មកកាន់មាតុប្រទេសវិញដើម្បីទទួលការស្វាគមន៍ពីសំណាក់សមាជិកយុវជន UYFC ដែលលើកទឹកចិត្តគាំទ្ររាប់ម៉ឺននាក់។[299] មួយខែមុននោះ សមាជិករបស់ UYFC មានពាក្យចចាមអារាមថាបានចូលរួមក្នុងការតវ៉ាប្រឆាំងនឹងប្រធានគណបក្សប្រឆាំងគឺលោកគឹមសុខានៅខាងក្រៅរដ្ឋសភាជាតិជាកន្លែងដែលតំណាងរាស្ត្រមកពីគណ:បក្សប្រឆាំងពីររូបត្រូវបានវាយដំលើយ៉ាងឃោរឃៅដោយសមាជិករបស់អង្គភាពអង្គរក្សលោកហ៊ុនសែន។[300]

កូនប្រសាស្រីរបស់លោកហ៊ុនសែន ឈ្មោះ ពេជ្រ ច័ន្ទមុន្នី ក៏បានកាន់តំណែងអង្គការសប្បុរសធម៌ផ្ទាល់ខ្លួនរបស់នាងដែលមានឈ្មោះថាសមាគមន៍ក្រុមគ្រូពេទ្យស្ម័គ្រចិត្តសម្តេចតេជោ (TYDA) ដែលនាងគឺជាស្ថាបនិក ជាមួយនិងស្វាមីរបស់នាងគឺលោក ហ៊ុន ម៉ាណែត និង អនុប្រធានស្រីនៃ គណ:ប្រធានសមាគមន៍។[301] ទោះបីវាជាអង្គការជំនួយមនុស្សធម៌មួយក៏ដោយ ក្រុមនេះក៏ត្រូវបានគេនិយាយថាជាក្រុមគាំទ្រគណ:បក្សប្រជាជនកម្ពុជានិងមានគោរម្យងារដែលមានពាក្យពីរម៉ាត់ខាងមុខនោះគឺ "សម្តេចតេជោ" ជាមួយនិងគោរម្យងារជាផ្លូវការរបស់លោកហ៊ុនសែន។[302] ក្នុងខែសីហាឆ្នាំ 2015 សារព័ត៌មានក្នុងស្រុកបានរាយការណ៍ថាសមាគមន៍ក្រុមគ្រូពេទ្យស្ម័គ្រចិត្តសម្តេចតេជោ (TYDA) បានកំពុងតែពិភាក្សាជាមួយនឹងលោក St. John Brigade នៅសឹង្ហបូរីដែលពីមុនលោកក៏ធ្លាប់បានធ្វើការជាមួយនឹងកាកបាទក្រហម កម្ពុជាផងដែរ។[303]

ក្នុងខែមករាឆ្នាំ2016 អង្គការគ្លូបប៊ិលវីតណែសបានសរសេរទៅកាន់កាកបាទក្រហមកម្ពុជា សហព័ន្ធសហជីពយុវជនកម្ពុជានិង សមាគមន៍ក្រុមគ្រូពេទ្យស្ម័គ្រចិត្តសម្តេចតេជោ (TYDA)ក៏ប៉ុន្តែមិនបានទទួលចម្លើយឆ្លើយតបទេ។

## ប្រព័ន្ធផ្សព្វផ្សាយ - អនឡាញ(ប្រើប្រាស់អ៊ីនធឺណែត)និងអហ្វឡាញ(មិនប្រើប្រាស់អ៊ីនធឺណែត)

ក្រុមដង្ហែរតាមជុំវិញលោកហ៊ុនសែននិងគ្រួសាររបស់គាត់ក៏ជួយរក្សាការក្តោបក្តាប់អំណាចក្នុងដៃយ៉ាងណែនលើសង្គមកម្ពុជា។[304] រូបថតរបស់លោកនាយករដ្ឋមន្ត្រីត្រូវបានបិទតាំងនៅពាសពេញផ្ទៃប្រទេស ទាំងនៅតាមផ្លូវក្នុងតំបន់ជាយក្រុងនិងនៅកាច់ជ្រុងផ្លូវនិងនៅតាមភូមិជនបទនានា គឺមានច្រើនជាងរូបភាពរបស់ព្រះមហាក្សត្រកម្ពុជាទៅទៀត។ បទចម្រៀងការ៉ាអូខេច្រៀងសរសើរពីលោកហ៊ុនសែននិងលោកស្រីប៊ុនរ៉ានី ចាក់ផ្សាយមិនដាច់ពាសពេញតាមស្ថានីយទូរទស្សន៍កម្ពុជាហើយមិនត្រឹមតែសរសើរជនទាំងពីររូបនេះជាទូទៅប៉ុណ្ណោះទេក៏ប៉ុន្តែថែមទាំងលើកតម្កើងការសម្រេចចិត្តនានារបស់រដ្ឋាភិបាលនាពេលថ្មីៗនេះផងដែរ។[305] ស្ថាប័នរដ្ឋជាច្រើននិងទីសាធារណ:ដូចជាបណ្ណាល័យ ដងផ្លូវនានានិងសាលារៀនត្រូវបានដាក់ឈ្មោះតាមលោកហ៊ុនសែន។[306]

ភាពជាកម្មសិទ្ធប្រព័ន្ធផ្សព្វផ្សាយបន្តការផ្សព្វផ្សាយផ្តោតខ្លាំងក្នុងប្រទេសកម្ពុជាហើយ ប្រព័ន្ធផ្សព្វផ្សាយមានឥទ្ធិពលខ្លាំងជាងគេរបស់ប្រទេសត្រូវបានគ្រប់គ្រងដោយអ្នកជំនួញនិងអ្នកនយោបាយដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងគ្រួសារត្រកូលហ៊ុន។[307] ជាលទ្ធផល សេរីភាពក្នុងការបញ្ចេញមតិមិនត្រូវបានការពារទាំងស្រុ




ប៊ុន រ៉ានី គឺជាប្រធានរបស់កាកបាទក្រហមកម្ពុជា និងត្រូវបានចោទប្រកាន់ម្តងហើយម្តងទៀតពីបទប្រើប្រាស់អំណោយ សប្បុរសធម៌ដើម្បីផ្តល់ផលប្រយោជន៍បន្ថែមដល់ CPP និងគ្រួសាររបស់គាត់

ងទេហើយអាជ្ញាធរប្រើប្រាស់បណ្តឹងផ្លូវច្បាប់ ការកាត់ទោសបទល្មើសឧក្រិដ្ឋ និងការវាយប្រហារដោយអំពើរហឹង្សាជាមធ្យោបាយនៃការបំភិតបំភ័យប្រឆាំងទៅនឹងអ្នកសារព័ត៌មាន។[308]

គ្រួសារត្រកូលហ៊ុននិងបក្សពួករបស់ខ្លួនបានព្យាយាមទទួលបានការក្តោបក្តាប់ធំលើក្រុមហ៊ុនផ្សព្វផ្សាយឯកជននានារបស់ប្រទេស កម្ពុជា ដែលអនុញ្ញាតិឲ្យពួកគេគ្រប់គ្រងភាគច្រើននៃព័ត៌មានដែលប្រជាជនកម្ពុជាអាចទទួលបាន។ ការសិក្សានាពេលថ្មីៗនេះដែលត្រូវបានផ្តល់មូលនិធិដោយ រដ្ឋាភិបាលប្រទេសអាល្លឺម៉ង់និងបានផ្សព្វផ្សាយក្នុងឆ្នាំ2015ដោយមជ្ឈមណ្ឌលកម្ពុជាសម្រាប់ក្រុមអ្នកសារព័ត៌មាននិងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យឥតព្រំដែនបានធ្វើការស្ទាបស្ទង់មតិលើប្រព័ន្ធផ្សព្វផ្សាយចំបងសំខាន់ៗរបស់ប្រទេសកម្ពុជាចំនួន41 ដែលត្រូវបានគ្រប់គ្រងដោយមនុស្សចំនួន 27 នាក់។ ក្នុងចំណោមមនុស្សទាំង27នាក់នេះការស្រាវជ្រាវបានរកឃើញថាមានប្រាំបួននាក់ជាអ្នកជំនួញឬជាឧកញ៉ាគណបក្សនយោបាយដែលមានទំនាក់ទំនងរឹងមាំជាមួយនឹងគណបក្សប្រជាជនកម្ពុជា។ បញ្ជីនោះក៏រាប់បញ្ចូលទាំងឈ្មោះ **ហ៊ុន ម៉ាណា** និងអ្នកដំណើរការវិស័យឯកជនសំខាន់ៗនិងដៃគូជំនួញរបស់គ្រួសារត្រកូលហ៊ុនដែលមានលោក **គិត ម៉េង**និងលោក **លីយ៉ុងផាត់** ។[309]

ដូចដែលបានពណ៌នានៅលើទំព័រ13ដែលថា ហ៊ុនម៉ាណា គឺជាអ្នកមានទ្រព្យសម្បត្តិនិងអំណាចម្នាក់ក្នុងចំណោមពីរនាក់ដែលគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយក្នុងប្រទេសកម្ពុជាដែលមានការកាន់កាប់ ទាំងវិទ្យុ ទូរទស្សន៍និងសារព័ត៌មាន។[310] គាត់ជានាយកស្ថានីយផ្សព្វផ្សាយបាយ័ន Bayon Media Hight System ដែលជាក្រុមហ៊ុនប្រព័ន្ធផ្សព្វផ្សាយចំបងមួយក្នុងចំណោមក្រុមហ៊ុនជាច្រើនរបស់ប្រទេសកម្ពុជាដែលធ្វើការផ្សព្វផ្សាយទាំងវិទ្យុនិងទូរទស្សន៍។[311] ស្ថានីយទូរទស្សន៍មួយក្នុងចំណោមស្ថានីយចំនួនបីត្រូវបានគ្រប់គ្រងដោយក្រុមហ៊ុននេះ ទូរទស្សន៍បាយ័នព័ត៌មានដែលជាប៉ុស្តទូរទស្សន៍ព័ត៌មានដ៏មានប្រជាប្រិយភាពជាងគេបំផុតទីពីរក្នុងប្រទេសនិងផ្សាយកម្មវិធីពត៌មាន ពេលល្ងាចដែលមានប្រជាប្រិយភាពជាងគេក្នុងប្រទេសកម្ពុជា។[312] លោកស្រី ម៉ាណាក៏កាន់កាប់ស្ថានីយវិទ្យុបាយ័នផងដែរដែលជាស្ថានីយមួយក្នុងចំណោមស្ថានីយវិទ្យុជាច្រើនក្នុងប្រទេសកម្ពុជានិងក៏ជាស្ថានីយដែលឈានមុខគេមួយគាំទ្រដល់គណបក្សប្រជាជន កម្ពុជា។[313] លើសពីនេះគាត់ក៏កាន់កាប់កាសែតកម្ពុជាថ្មីដែលមានចំនួនអ្នកអានជាតិចំនួនប្រាំមួយភាគរយហើយក៏ត្រូវបានគេស្គាល់យ៉ាងទូលំទូលាយថាជាកាសែតដែលគាំទ្រគណ:បក្សប្រជាជនកម្ពុជាផងដែរ។[314]

ក្រុមហ៊ុនប្រព័ន្ធផ្សព្វផ្សាយឯកជនដែលឈានមុខគេដែលគ្រប់គ្រងដោយគ្រួសារត្រកូលហ៊ុននិងបក្សពួករបស់ពួកគេបានមានឥទ្ធិពលយ៉ាងជ្រៅទូទាំងវិស័យសារព័ត៌មានទាំងអស់។ ការសិក្សាមួយក្នុងឆ្នាំ2015ដោយមជ្ឈមណ្ឌលសារព័ត៌មានឯករាជ្យកម្ពុជាបានរកឃើញថាស្ទើតែពាក់ កណ្តាលនៃអ្នកសារព័ត៌មានក្នុងស្រុកមានការភ័យខ្លាចចំពោះផលវិបាកដែលបង្ករឡើងពីការងាររបស់ពួកគេនិង%17ត្រូវបានវាយប្រហារដោយសារតែការរាយការណ៍របស់ពួកគេ។ មានតែ%45 ប៉ុណ្ណោះដែលមានអារម្មណ៍ថាស្ថាប័នដែលពួកគេបានធ្វើការងារឲ្យមិនមានការជ្រៀតជ្រែកពីឥទ្ធិពលនយោបាយ។[315] ក្រុមអ្នកសារព័ត៌មានគ្មានព្រំដែនបានកត់សម្គាល់ថាប្រទេសកម្ពុជានិងប្រទេសឥណ្ឌាគឺជាប្រទេសដែលមានគ្រោះថ្នាក់បំផុតពីរចំពោះអ្នកសារព័ត៌មានដែលផ្សព្វផ្សាយពីបញ្ហាបរិស្ថាន ដោយបានដកស្រង់សម្តីថាមានមនុស្ស4នាក់បានស្លាប់ក្នុងប្រទេសកម្ពុជាក្នុងចន្លោះឆ្នាំ2012និងឆ្នាំ2014។[316]

ដោយមានអ្នកប្រើប្រាស់បណ្តាញសង្គមជាច្រើនក្នុងប្រទេសកម្ពុជាមានការកើនឡើងខ្ពស់ខ្លាំងក្នុង រយ:ពេលប្រាំឆ្នាំចុងក្រោយនេះ គ្រួសារត្រកូលហ៊ុនបានកំពុងតែបង្កើនការសកម្មអនឡាញ។ លោកហ៊ុនសែនបាននឹងកំពុងប៉ុស្ត៍ជាប្រចាំនៅលើទំព័របណ្តាញសង្គមរបស់លោកចាប់តាំងពីខែតុលាឆ្នាំ2015មកម្លេះ ហើយនៅពេលគាត់សរសេរប៉ុស្ត៍មានអ្នកមើលគាត់ជាង4លាននាក់។[317] ក្នុងខែមិនាឆ្នាំ2016 ជម្លោះដែលល្បីរន្ទឺខ្លាំងមួយបានកើតឡើងបន្ទាប់ពីសារព័ត៌មានក្នុងស្រុកនិងលោកសមរង្ស៊ី ដែលជាមេដឹកនាំគណបក្សប្រឆាំងដែលត្រូវបាននិរទេសខ្លួន បានចោទប្រកាន់លោកហ៊ុនសែនថាបានទិញចំនួនឡៃ'Like' ពីក្រុមហ៊ុនចាំចុចបរទេស click-farms ដើម្បីបង្កើនប្រជាប្រិយភាពក្លែងក្លាយរបស់លោក។[318] ដើម្បីពង្រឹងវត្តមានអនឡាញរបស់គាត់ឲ្យកាន់តែខ្លាំង ក្នុងខែមករាឆ្នាំ2016 លោកហ៊ុនសែនបានបើកយុទ្ធនាការកម្មវិធីឈ្មោះ "សម្តេចនាយករដ្ឋមន្ត្រី"ដែលប៉ុស្ត៍ ជាប្រចាំពីសកម្មភាពរបស់គាត់។[319]




វត្តមានអនឡាញរបស់លោកហ៊ុនសែនកំពុងតែមានការកើនឡើងរហូតដល់ពិភពលោកពិត។ សមាជិកនៃគ្រួសារត្រកូលហ៊ុនបានកាន់តែខឹងប្រឡោតក្នុងការឆ្លើយតបទៅនឹងការរិះគន់ដែលបានបន្ទាបបន្ថោកពួកគេតាមអនឡាញ ដោយគំរាមគំហែងដាក់ពាក្យបណ្តឹងបរិហារកេរ្តិ៍និងចាប់ខ្លួនអ្នកប្រើប្រាស់នានា។[320] ក្នុងខែមករាឆ្នាំ2016 ក្រោយពីមានការចាប់ខ្លួ

នបុរសម្នាក់ដែលបានប៉ុស្ដិ៍ពីការទស្សទាយទុកការស្លាប់របស់លោកហ៊ុនសែន ដែលលោកនាយករដ្ឋមន្ត្រីពេលនោះបានព្រមានអ្នកប្រើប្រាស់បណ្ដាញសង្គមFacebookនោះដែលជេប្រមាថគាត់ថាពួកគេអាចនឹងត្រូវបានតាមដានរកឃើញទីកន្លែងបានដោយងាយ។[321]

ផ្ទុយទៅនឹងការបង្ក្រាប លោកហ៊ុនសែនក៏បានប្រើប្រាស់បណ្ដាញសង្គមដើម្បីផ្ដល់ជំនួយដោយមិនចំពោះដល់ប្រជពលរដ្ឋសាមញ្ញ ធម្មតា។ គាត់មានមន្ត្រីរាជការមកពីក្រសួងរដ្ឋាភិបាលចំនួនប្រាំពីរដែលចាំស្វែងរកមើលទទួលនូវអ្វីដែលគេប៉ុស្ដិ៍នៅលើទំព័របណ្ដាញសង្គមរបស់គាត់ដើម្បីរកដំណោះស្រាយចំពោះការកើតទុកមិនសុខចិត្តជាសាធារណៈនានា។[322] ក្នុងខែមិនាឆ្នាំ2016 គាត់បានជ្រៀតជ្រែកក្នុងសំណុំរឿងរបស់សមាជិកសហគមន៍ពីរនាក់ដែលត្រូវបានចាប់ខ្លួនពាក់ព័ន្ធទៅនឹងជម្លោះដីធ្លីក្នុងខេត្តកំពង់ស្ពឺ។ គាត់បានប៉ុស្ដិ៍នៅលើបណ្ដាញសង្គមរបស់គាត់ថាអភិបាលខេត្តនេះគួរធ្វើការជាបន្ទាន់ដើម្បីឲ្យមានការដោះលែងអ្នកដែលជាប់ឃុំនិងក្រោយមកត្រូវបានរាយការណ៍ថាគាត់បានបញ្ជូនកូនប្រុសរបស់គាត់ដែលជាតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាគឺលោក ហ៊ុន ម៉ានីនិងប្រធានអង្គភាពចារកម្មសម្ងាត់កងទ័ពជើងគោគលោកហ៊ុនម៉ានិត ឲ្យទៅជួបស្ត្រីដែលកំពុងជាប់ឃុំឃាំងក្នុងគុកខណៈដែលពួកគេត្រូវបាន ដោះលែងចេញពីគុកឲ្យនៅក្រៅឃុំវិញ។[323]

មធ្យោបាយដែលលោកហ៊ុនសែនកំពុងប្រើប្រាស់បណ្ដាញសង្គម Facebook ដើម្បីទាំងយាយីអ្នករិះគន់និងគ្រប់គ្រងលើប្រព័ន្ធយុត្តិធម៌ដោយការកំណត់ដាក់ទោសឬមិនដាក់ទោសតាមតែអំពើរចិត្ត មធ្យោបាយសាមញ្ញធម្មតាមួយដែលគាត់បានរក្សាការគ្រប់គ្រងក្ដោបក្ដាប់លើប្រទេសកម្ពុជាសម្រាប់រយៈពេលបីទសវត្សចុងក្រោយនេះ។ យន្តការណ៍នេះត្រូវបានផ្លាស់ប្ដូរក៏ប៉ុន្តែយុទ្ធសាស្ត្រនិងផលវិបាកនានានៅរក្សារ ដដែល។

# សេចក្ដីសន្និដ្ឋាន

របាយការណ៍នេះលាតត្រដាងពីវិសាលភាពនិងភាពគ្មានខ្លាចញញើតកោតក្រែងនៃរឿងរ៉ាវការពិតដែលលោកហ៊ុនសែនកំពុងលក់ដល់ពិភពលោកខាងក្រៅ។ យោងតាមរដ្ឋាភិបាលកម្ពុជា គន្លឹះនៃការសម្រេចភាពចាំបាច់នៃការលូតលាស់សេដ្ឋកិច្ចសម្រាប់ប្រទេសដើម្បីសម្រេចគោលដៅអភិវឌ្ឍរបស់ខ្លួនគឺការបង្កើតនូវ'វិស័យឯកជនមួយដែមមានភាពរឹងមាំល្អ'។[324] ក្នុងការខិតខំប្រឹងប្រែងទាក់ទាញការ វិនិយោគជំនួញពីបណ្ដាប្រទេសអាស៊ាននិងដែនអំណាចច្បាប់របស់លោកខាងលិចដូចជាសហរដ្ឋអាមេរិកនិងសហគមន៍អឺរ៉ុប រដ្ឋាភិបាលថ្មីៗនេះបានបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការលើកស្ទួយមុខមាត់ប្រទេសកម្ពុជាថាជាប្រទេសដែលមានទីសដៅនៃការវិនិយោគល្អប្រសើរ ដោយលើកសរសើរពីការមិនមាននិយតកម្មរបស់ប្រទេសនិងកម្លាំងពលកម្មដែលតម្លៃទាប។[325] ទោះបីជាយ៉ាងនេះក៏ដោយ លោកហ៊ុនសែននិងរដ្ឋាភិបាលរបស់លោកបានបរាជ័យទាំងស្រុងក្នុងការដោះស្រាយអំពើរពុករលួយដែលមានពាសពេញទាំងក្នុងវិស័យឯកជននិងសាធារណៈនិងដែលធ្វើឲ្យអន្តរាយដល់កិច្ចខិតខំប្រឹងប្រែងក្នុងការបង្កើតបរិស្ថានវិនិយោគមួយប្រកបដោយការទទួលខុសត្រូវ។ តាមពិតទៅ លោកហ៊ុនសែននិងបក្សពួករបស់លោកស្ថិតនៅចំកណ្ដាលបេះដូងនៃអំពើរពុករលួយ ដែលខ្លួនផ្ទាល់ទទួលប្រយោជន៍ពីអំពើពុករលួយ ដែលផ្ដល់គ្រោះថ្នាក់ដល់ប្រជាជនកម្ពុជា។

ផ្អែកតាមទិន្នន័យសឹងតែតែមួយគត់ពីការចុះបញ្ជីក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មរបស់ប្រទេសកម្ពុជា ភស្តុតាងដែលបានបង្ហាញក្នុងការកាន់កាប់ដោយហឹង្សាបង្ហាញថាសមាជិករបស់គ្រួសារលោកនាយករដ្ឋមន្ត្រីហ៊ុនសែនមានបណ្ដាញទំនាក់ទំនងទៅដល់ក្រុមហ៊ុនក្នុងស្រុកចំនួន114 ក្រុមហ៊ុនដែលបានចុះបញ្ជីចំណែកភាគហ៊ុនរួមមានតម្លៃជាង200លានដុល្លាសហរដ្ឋអាមេរិក។ តួលេខទាំងនេះរាប់បញ្ចូលត្រឹមតែការកាន់កាប់ជំនួញដែលគ្រួសារនេះបានជ្រើសរើសប្រកាសប្រាប់។ ដូច្នេះ ប្រាក់ហ៊ុនជំនួញសរុបទាំងអស់របស់ពួកគេគឺច្បាស់ជាសឹងតែច្រើនជាងនេះឆ្ងាយណាស់។

ភាគហ៊ុនរបស់គ្រួសារនេះលាតសន្ធឹងដល់វិស័យជំនួញភាគច្រើនដែលផ្ដល់ផលកម្រៃយ៉ាងច្រើនសន្ធឹកសន្ធាប់ របស់ប្រទេសកម្ពុជា ក៏ដូចជាវិស័យទាំងឡាយណាដែលបង្ហាញដោយកម្រិតនៃអំពើពុករលួយកម្រិតខ្ពស់ ការរំលោភសិទ្ធិមនុស្សនិងការបំផ្លិចបំផ្លាញបរិស្ថាន។ ក្រុមហ៊ុននានាដែលក្រុមហ៊ុនមានភាគហ៊ុនក្នុងនោះបានប្រព្រឹត្តការរំលោភបំពានដែលនាំមកនូវផលវិបាកដ៏គ្រោះថ្នាក់សម្រាប់ប្រជាជនកម្ពុជាដែលរងផលប៉ះពាល់ដោយផ្ទាល់ពីដំណើរប្រតិបត្តិការរបស់ពួកគេ។កាន់តែ ទូលំទូលាយជាងនេះទៅទៀតនោះគឺថា អំពើរពុករលួយនិងការចាប់យករបស់ពួកអ្នកធំអ្នកមាននូវធនធាននានារបស់រដ្ឋដោយគ្រួសារត្រកូលហ៊ុននិងបក្សពួករបស់គេកំពុងតែធ្វើឲ្យប្រជាជនសាមញ្ញកម្ពុជាជាប់ផុងក្នុងភាពក្រីក្រដោយសារតែប្រាក់ត្រូវបានហូរចូលទៅក្នុងគណនីយ្យធនាគារផ្ទាល់ខ្លួនរបស់ពួកគេជាជាងត្រូវបានចំណាយលើសេវាសាធារណៈចាំបាច់នានាដូចជាសុខភាពនិងការអប់រំជាដើម។326 ដោយសារប្រព័ន្ធតុលាការមានការលំអៀងទៅរកនយោបាយដែលនៅតែស្ថិតនៅយ៉ាងជាប់ក្នុងដៃរបស់លោកហ៊ុនសែន សមាជិកគ្រួសាររបស់គាត់និងក្រុមហ៊ុននានាដែលមានទំនាក់ទំនងជាមួយពួកគេ អាចដំណើរការដោយគ្មានការភ័យព្រួយពីការកាត់ទោសអ្វីឡើយ។ ពួកគេបានព្យាយាមបង្កើតទំនាក់ទំនងជាមួយនឹងក្រុមហ៊ុនម៉ាកល្បីៗធំៗអន្តរជាតិជាច្រើនហើយទទួលបានប្រាក់ លាភសការៈក្នុងក្រុមហ៊ុនជាច្រើនដែលប្រជាជនកម្ពុជានិងអ្នកទេសចរមកកាន់ប្រទេសនេះព្យាយាម គេជជៀស។

ការក្ដោបក្ដាប់វិស័យឯកជនដ៏ទូលំទូលាយវាសំខាន់ណាស់សម្រាប់អាចឲ្យលោកហ៊ុនសែននិងគ្រួសាររបស់គាត់រក្សាបាននូវប្រព័ន្ធអំណាចចាត់តាំង។ ក្រុមហ៊ុនទាំងនេះជាច្រើនអាចរក្សានូវកិច្ចសន្យាសាធារណៈដែលផ្ដល់ផលកម្រៃយ៉ាងច្រើនសន្ធឹកសន្ធាប់និងអាជ្ញាប័ណ្ណសម្បទានសម្រាប់ការទាញយកធនធានធម្មជាតិនិងដីធ្លី។ កត្តានេះធ្វើឲ្យទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់គ្រួសារនេះមានការកើនឡើងដែលចាំបាច់ក្នុងការបន្តផ្ដល់រង្វាន់ដល់អ្នកមានទ្រព្យសម្បត្តិធំៗរបស់ប្រទេសដែលរំពឹងថានឹងត្រូវបានទទួលនូវរង្វាន់មកវិញសម្រាប់ការគាំទ្រដែលមិនរេរារបស់ពួកគេ។[327] បើគ្មានប្រាក់ចំណូលទាំងអស់នេះទេ បណ្ដាញគ្រួសារត្រកូលហ៊ុននឹងច្បាស់ជាបាន ដួលរលំតាំងពីបីទសវត្សចុងកក្រោយនេះមកម្លេះ។

ប្រទេសកម្ពុជាថ្មីៗនេះមានការដើរថយក្រោយខ្លាំងចំពោះសេរីភាពលទ្ធិប្រជាធិបតេយ្យនិងការបើកចំហរ។ បើក្រឡេកមើលទៅលើ ព្រឹត្តការណ៍នានាក្នុងឆ្នាំ2015 និងឆ្នាំ 2016 បង្ហាញពីការវាយប្រហារនៃអំណាចនិតិប្បញ្ញតិដែលគាបសង្កត់ថ្មីនិងការបង្ក្រាបដ៏អាក្រក់លើគ្រប់អ្នករិះគន់រដ្ឋាភិបាលរួមមានទាំងគណៈបក្សប្រឆាំងដែលស្របច្បាប់ផងដែរ។[328] លោក ហ៊ុនសែននិងសមាជិកគ្រួសាររបស់គាត់បានកាន់តែគឃ្លើនឡើងៗក្នុងការការពារកិត្តយសរបស់ពួកគេហើយស្ថានភាពមើលទៅទំនងនឹងកាន់តែអាក្រក់ទៅៗខ្លាំងដោយសារតែពួកគេស្វះស្វែងព្យាយាមពង្រឹងអំណាចនៅមុនពេលការបោះឆ្នោតថ្នាក់ជាតិដែលនឹងមកដល់ក្នុងឆ្នាំ 2017និង2018។

លោកហ៊ុនសែននិងបក្សពួករបស់លោកប្រាកដណាស់ថាមិនទំនងជានឹងមិនមានផែនការបោះបង់អំណាចឬផ្លាស់ប្ដូរវិធីសាស្ត្ររបស់ពួកគេក្នុងពេលណាមួយឆាប់ៗនេះទេ លុះត្រាណាតែមានសម្ពាធពីខាងក្រៅចាប់ផ្ដើមប្រាប់។ ក្នុងការបោះឆ្នោតឆ្នាំ2013 នាពេលថ្មីនេះ ទោះបីជាមានការចោទប្រកាន់ពីការលួចបន្លំជាលក្ខណៈប្រព័ន្ធនិងការបោះឆ្នោតដែលត្រូវ បានរៀបចំដោយរដ្ឋាភិ បាលរបស់គាត់ ក៏ដោយ ក៏លោកហ៊ុនសែនបានទទួលរងនូវការស្ទើរតែបរាជ័យ ដែលជំរុញលោកឲ្យសច្ចាថាមានតែការ*"ស្លាប់ឬការអស់សមត្ថភាពដល់ចំណុចធ្វើការលែងកើតប៉ុណ្ណោះ"*ដែលអាចធ្វើឲ្យគាត់ចុះចេញពីដំណែងបាន។[329] ខណៈពេលសរសេរនេះ មេបក្សប្រឆាំងគឺលោក សមរង្ស៊ីកំពុងតែត្រូវនិរទេសខ្លួននៅឡើយ ហើយវាមិច្បាស់ទេថាតើគាត់អាចត្រឡប់មកវិញសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ2018បានឬអត់នៅឡើយទេ។[330]

ព្រឹត្តការណ៍ថ្មីៗនេះ ផ្គួបជាមួយនឹងការរកឃើញដូចបានបង្ហាញក្នុងអត្ថបទការចាប់យកអំណាចដោយ ហឹង្សាគួរតែប្រើប្រាស់ជាសញ្ញាដាស់តឿនដ៏ធំសម្រាប់អ្នកវិនិយោគទុនធំៗ។ ដោយសារតែការគ្រប់គ្រងច្បាប់បានថយចុះ អ្នកវិនិយោគត្រូវបានទុកឲ្យប្រឈមនឹងការសម្រេចចិត្តតាមតែអំពើរចិត្តដែលធ្វើឡើងដោយជនមានអំណាចទ្រព្យសម្បត្តិ។ លើសពីនេះ បរិស្ថានធ្វើជំនួញដ៏ស្មុគស្មាញជាមួយនឹងអំពើរពុករលួយដែលមានកម្រិតខ្ពស់នាំឲ្យមានគ្រោះថ្នាក់ធ្វើឲ្យប៉ះពាល់ដល់ច្បាប់ ហិរញ្ញវត្ថុនិងកេរ្ដិ៍ឈ្មោះដល់ក្រុមហ៊ុននានា។ពួកគេប្រឈមមុខខ្លាំងក្នុងការជាប់ពាក់ព័ន្ធក្នុងការនាំឲ្យមនាការរំលោភសិទ្ធិមនុស្ស ការបំផ្លិចបំផ្លាញបរិស្ថាននិងអំពើពុករលួយ។ ដើម្បីជៀសវាងបញ្ហានេះ អ្នកវិនិយោគទុននានាចាំបាច់ត្រូវធ្វើការត្រួតពិនិត្យឲ្យបានហ្មត់ចត់ដើម្បីធានាធ្វើឲ្យប្រាកដថាពួកគេនឹងមិនកំពុងតែចូលដៃជាមួយនឹងពួកជនមានអំណាចលុយកាក់ដែលពុករលួយរបស់ប្រទេសទេ។ បើមិនដូច្នោះទេ 'វិស័យឯកជនដែលមានសុខភាពល្អ'ដែល រដ្ឋាភិបាលអះអាងថាខ្លួនកំពុងតែធ្វើការងារដើម្បីឈានទៅសម្រេចបាននោះនឹងមិនអាចកើតជារូបរាងជាក់ស្ដែងបានទេហើយប្រជាជនសាមញ្ញកម្ពុជានឹងបន្តទទួលរងគ្រោះ។

# អនុសាសន៍

**ក្រុមហ៊ុននិងអ្នកវិនិយោគទុនគួរតែ:**
អនុសាសន៍ទាំងនេះពាក់ព័ន្ធចំពោះក្រុមហ៊ុននិងអ្នកវិនិយោគទុនទាំងអស់ដែលមានទំនាក់ទំនងជាមួយនឹងគ្រួសារត្រកូលហ៊ុននិងបក្សពួករបស់ពួកគេ។ នេះមិនសំដៅថាតើទំនាក់ទំនងនោះគឺតាមរយៈភាពជាដៃគូរផ្លូវការ ការទិញសិទ្ធិឈ្មោះទំនិញផ្ដាច់មុខ តាមរយៈ សង្វាក់ផលិតកម្មនានា កិច្ចព្រមព្រៀងចែកចាយជាពិសេសឬក៏ត្រឹមជាទំនាក់ទំនងជាអតិថិជនធម្មតាក៏ដោយ។

1. ធ្វើការពិនិត្យ អោយបានតឹងរឹងច្បាស់លាស់ដើម្បីធ្វើឲ្យប្រាកដថាតើនរណាខ្លះដែលបានពាក់ព័ន្ធក្នុងមុខជំនួញនោះ។ កន្លែងដែលឃើញមានការពាក់ព័ន្ធរបស់អ្នកមានអំណាចខាងនយោបាយឬមុខជំនួញនានាដែលមានប្រវត្តិការចោទប្រកាន់ពីអំពើពុករលួយឬសមាជិកគ្រួសាររបស់ពួកគេ សូមកុំបន្តជាមួយនឹងការវិនិយោគឲ្យសោះ។ កន្លែងដែលបញ្ហានេះមានទំនាក់ទំនងទៅនឹងការវិនិយោគដែលធ្លាប់មានមកហើយ ដូច្នេះសូមចាកចេញពីទំនាក់ទំនងមុខជំនួញនោះឲ្យបានកាន់តែឆាប់កាន់តែល្អឬក្នុងរយៈពេលអតិបរមា 12 ខែ។

   ប្រសិនបើភស្តុតាងនៃការជាប់ពាក់ព័ន្ធក្នុងអំពើរពុករលួយត្រូវបានបើកបង្ហាញតាមរយៈដំណើរការពិនិត្យប្រាក់ដែលត្រូវបង់ដល់ពេលកំណត់យ៉ាងច្បាស់លាស់នោះក្រុមហ៊ុននិងអ្នកវិនិយោគគួរតែរាយការណ៍ដោយខ្លួនឯងអំពីការរកឃើញទាំងឡាយនោះដល់គ្រប់អាជ្ញាធរដែលពាក់ព័ន្ធដែលមានដែនសមត្ថកិច្ចផ្នែកច្បាប់។

2. អនុវត្តនិយមន័យកម្លាំងភារកិច្ចមុខងារវិធានការហិរញ្ញវត្ថុនៃបុគ្គលដែលងាយរងឥទ្ធិពលនយោបាយ(PEPs) ដែលក៏អនុវត្តចំពោះគ្រប់សមាជិកគ្រួសារនិងដៃគូនានានៃអ្នកដែលត្រូវបានកត់សម្គាល់ឃើញ។ បង្កើតដំណើរការម៉ឺងម៉ាត់ច្បាស់លាស់ដើម្បីកំណត់ពីបុគ្គលដែលងាយរងឥទ្ធិពលនយោបាយ(PEPs) ។ កន្លែងដែលដៃគូរជំនួញដ៏មានឥទ្ធិពលត្រូវបានរកឃើញថាជាមនុស្សដែលងាយរងឥទ្ធិពលនយោបាយ(PEPs)បន្ទាប់មកប្រព័ន្ធដំណើរការ ពិនិត្យប្រាក់ដែលត្រូវបង់ដល់ពេលកំណត់ដែលត្រូវបានពង្រឹងត្រូវតែទុកដាក់ឲ្យបានត្រឹមត្រូវ ដើម្បីធានាធ្វើឲ្យប្រាកដថាបុគ្គលដែលសង្ស័យមិនបានពាក់ព័ន្ធក្នុងការលាងលុយកខ្វក់ឬការប្រព្រឹត្តអំពើពុករលួយ មួយផ្សេងទៀតទេ។

3. ធានាធ្វើឲ្យប្រាកដតាមរយៈដំណើរការពិនិត្យប្រាក់ដែលត្រូវបង់ដល់ពេលកំណត់ដែលសកម្មភាពជំនួញនិងការវិនិយោគក្នុងប្រទេសកម្ពុជាមិនបានរំលោភទៅលើច្បាប់និងកិច្ចសន្យាប្រឆាំងនឹងអំពើរពុករលួយក្នុងស្រុកនិងអន្តរជាតិទេ។ ធ្វើការពិចារណាជាពិសេសដើម្បីធានាពីការអនុវត្តតាមច្បាប់ស្ដីពីការប្រព្រឹត្តអំពើរពុករលួយបរទេសរបស់សហរដ្ឋអាមេរិកឆ្នាំ1977 ដែលគ្របដណ្ដប់លើគ្រប់ការធ្វើជំនួញណាដែលត្រូវបានធ្វើក្នុងសហរដ្ឋអាមេរិកជាប្រាក់ដុល្លានិងគ្រប់ ការធ្វើជំនួញដែលមិនមែននៅក្នុងស្រុក ទាំងអស់ដែលធ្វើ ឡើងក្នុងប្រទេសកម្ពុជា។

រដ្ឋាភិបាលអន្តរជាតិបានផ្ដល់ដល់ប្រទេសកម្ពុជានូវជំនួយហិរញ្ញវត្ថុនិងប្រភេទនៃការជួយផ្សេងៗជាច្រើនទៀត:

4. ប្រើប្រាស់វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាដែលហៅកាត់ថា (CDCF) ជាមូលដ្ឋានពឹងផ្អែកក្នុងការចរចារជាមួយនឹងរដ្ឋាភិបាលកម្ពុជាសម្រាប់ការអនុវត្តនូវអនុសាសន៍ដែលត្រូវបានធ្វើឡើងក្នុងរបាយការណ៍នេះ។ ធានាធ្វើឲ្យប្រាកដតាមរយៈការចរចារទាំងនេះថារាល់គ្រប់ម្ចាស់ជំនួយជាទឹកប្រាក់ដល់ប្រទេសកម្ពុជាត្រូវបានចាត់ចែងដោយតម្លាភាព មិនបានធ្លាក់ចូលទីក្នុងហោប៉ៅរបស់អ្នកមានអំណាចបុណ្យសក្តិទេ ហើយជំនួយនោះត្រូវបានចំណាយក្នុងផ្លូវដែលផ្ដល់ផលប្រយោជន៍ដល់ប្រជាជនកម្ពុជា។

5. ប្រើប្រាស់វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាដែលហៅកាត់ថា (CDCF) ជាមូលដ្ឋានពឹងផ្អែកក្នុងការចរចារជាមួយនឹងរដ្ឋាភិបាលកម្ពុជាសម្រាប់ការអនុវត្តនូវអនុសាសន៍ដែលត្រូវបានធ្វើឡើងក្នុងរបាយការណ៍នេះ។ ធានាធ្វើឲ្យប្រាកដតាមរយៈការចរចារទាំងនេះថារាល់គ្រប់ម្ចាស់ជំនួយជាទឹកប្រាក់ដល់ប្រទេសកម្ពុជាត្រូវបានចាត់ចែងដោយតម្លាភាព មិនបានធ្លាក់ចូលទីក្នុងហោប៉ៅរបស់អ្នកមានអំណាចបុណ្យសក្តិទេ ហើយជំនួយនោះត្រូវបានចំណាយក្នុងផ្លូវដែលផ្ដល់ផលប្រយោជន៍ដល់ប្រជាជនកម្ពុជា។

6. ធានាធ្វើឲ្យប្រាកដពីការបំពេញកាតព្វកិច្ចសិទ្ធិមនុស្សក៏ដូចជាតម្រូវការតម្លាភាពត្រូវបានដាក់បញ្ចូលទៅក្នុងសន្ធិសញ្ញា កិច្ចសន្យាវិនិយោគនាពេលអនាគតដែលក្នុងនោះមានប្រទេសកម្ពុជាជាហត្ថលេខីផងដែរ។ ជាពិសេស ធានាធ្វើឲ្យប្រាកដថាកាតព្វកិច្ចទាំងនេះត្រូវបានបញ្ចូលក្នុងសន្ធិសញ្ញាកិច្ចព្រមព្រៀងវិនិយោគទ្វេរភាគីដែលថ្មីៗនេះត្រូវបាននឹងកំពុងចរចាររវាងប្រទេសកម្ពុជានិងសហរដ្ឋអាមេរិក។

7. ប្រឆាំងជំទាស់ជាសាធារណៈនូវច្បាប់ដែលដើរថយក្រោយដែលត្រូវបានអនុម័តនាពេលថ្មីៗនេះ ដូចជា LANGO ច្បាប់សហជីពនិងទូរគមនាគមន៍កុំឲ្យមានការអនុវត្តក្នុងវិធីដែលធ្វើឡើងតាមតែចិត្តនឹកឃើញដែលផ្ដោតខ្លាំងទៅលើអ្នករិះគន់ រដ្ឋាភិបាលនិងការដាក់បញ្ចូលនូវច្បាប់ដែលដើរថយក្រោយបន្ថែមដូចជាច្បាប់ការសម្ងាត់ជាតិជាដើម។ គាំទ្រដំណើរការ ក្នុងការតាក់តែងច្បាប់សេរីភាពព័ត៌មានដើម្បីធានាពីតម្លាភាពជុំវិញការសម្រេចចិត្តរបស់រដ្ឋាភិបាល។

រដ្ឋាភិបាលប្រទេសកម្ពុជាគួរត្រូវ:

8. ធ្វើការស៊ើបអង្កេតឲ្យបានម៉ត់ចត់ ឯករាជ្យនិងតម្លាភាពក្នុងការចោទប្រកាន់នានាដែលត្រូវបានធ្វើឡើងក្នុងរបាយការណ៍នេះហើយនឹងកាត់ទោសក្រុមហ៊ុននិងបុគ្គលទាំងឡាយណាដែលរំលោភច្បាប់ប្រទេសកម្ពុជា។ ជាពិសេស ធ្វើការស៊ើបអង្កេតឲ្យបានគ្រប់ជ្រុងជ្រោយនិងតម្លាភាពចំពោះលោកនាយករដ្ឋមន្ត្រីហ៊ុនសែននិងសមាជិកគ្រួសាររបស់គាត់ដែល ឈ្មោះក្នុងរបាយការណ៍នេះ សម្រាប់បទល្មើសឧក្រិដ្ឋនៃការបង្កើន អនុញ្ញាតិនិងទទួលផលប្រយោជន៍ដែលមិនយុត្តិធម៌លើការបែងចែកសម្បត្តិធនធានរដ្ឋ។

9. ធានាធ្វើឲ្យប្រាកដថាក្រសួងពាណិជ្ជកម្មប្រគល់ត្រឡប់វិញនូវបញ្ជីឈ្មោះក្រុមហ៊ុនទាំងស្រុងដែលក្នុងនោះព័ត៌មានទាំងអស់ដែលបានដាក់ជូនដោយក្រុមហ៊ុននានាត្រូវបានដាក់បញ្ចូល។ ដកចេញនូវការចាំបាច់ក្នុងការចុះឈ្មោះអាសយដ្ឋានសារ អេឡិចត្រូនិកនិងការLoginចូលនៅពេលដែលឆែកស្វែងរកបញ្ជីឈ្មោះក្រុមហ៊ុនរបស់ក្រសួងពាណិជ្ជកម្មនិងធានាធ្វើឲ្យប្រា កដថាបញ្ជីឈ្មោះនោះអាចរកនិងឆែកឃើញបានជាសាធារណៈទាំងស្រុង។ កែតម្រូវគ្រប់ទិន្នន័យទាំងអស់ដែលត្រូវបានដាក់បញ្ចូលក្នុងបញ្ជីឈ្មោះនោះ ជាពិសេសឈ្មោះបុគ្គល ក្រុមហ៊ុន និងផ្លូវនានា ដើម្បីបង្កើនការអាចប្រើប្រាស់បញ្ជីឈ្មោះនោះបាន។

10. ធ្វើកំណែទម្រង់ច្បាប់ប្រឆាំងអំពើរពុករលួយដើម្បីឲ្យវាសមស្របទៅនឹងគោលបំណង។ ជាពិសេសត្រូវ:
    - ធ្វើវិសោធនកម្មមាត្រា11 ដើម្បីឲ្យប្រធាននិងប្រធានរងនៃអង្គភាពប្រឆាំងអំពើរពុករលួយត្រូវបានជ្រើសរើសតាមរយៈដំណើរការមួយដែលមានតម្លាភាពនិងឯករាជ្យនិងមិនមានការតែងតាំងដោយលោកនាយករដ្ឋមន្ត្រីតទៀតឡើយ។
    - ធ្វើវិសោធនកម្មមាត្រា11 ដើម្បីឲ្យប្រធាននិងប្រធានរងនៃអង្គភាពប្រឆាំងអំពើរពុករលួយត្រូវបានជ្រើសរើសតាមរយៈដំណើរការមួយដែលមានតម្លាភាពនិងឯករាជ្យនិងមិនមានការតែងតាំងដោយលោកនាយករដ្ឋមន្ត្រីតទៀតឡើយ។
    - ដើម្បីជៀសវាងជម្លោះផលប្រយោជន៍ ត្រូវធ្វើវិសោធនកម្មមាត្រា16 ដើម្បីឲ្យអង្គភាពអំពើរពុករលួយលែងមានសិទ្ធិទទួលការ បរិច្ចាកឬជំនួយពីអង្គការថ្នាក់ជាតិនានា។
    - ផ្អែកតាមបទដ្ឋានការចាត់វិធានការផ្នែកហិរញ្ញវត្ថុ Financial Action Task Force ត្រូវពង្រីកមាត្រាទី17ដើម្បីឲ្យសមាជិកគ្រួសារនិងបក្សពួកដែលជិតស្និទ្ធនៃមន្ត្រីសាធារណៈក៏ត្រូវបានតម្រូវឲ្យប្រកាស់ទ្រព្យសម្បត្តិរបស់ពួកគេដែរ។
    - ផ្អែកតាមបទដ្ឋានការចាត់វិធានការផ្នែកហិរញ្ញវត្ថុ Financial Action Task Force ត្រូវពង្រីកមាត្រាទី17ដើម្បីឲ្យសមាជិកគ្រួសារនិងបក្សពួកដែលជិតស្និទ្ធនៃមន្ត្រីសាធារណៈក៏ត្រូវបានតម្រូវឲ្យប្រកាស់ទ្រព្យសម្បត្តិរបស់ពួកគេដែរ។

11. ធានាធ្វើឲ្យប្រាកដថាការអាចទទួលបានព័ត៌មានច្បាប់ដែលថ្មីៗនេះត្រូវបានព្រាងដើម្បីតម្លាភាពជុំវិញការសម្រេចចិត្តនានារបស់រដ្ឋាភិបាលហើយមិនត្រូវបានរំលាយចោលដោយច្បាប់ការសម្ងាត់ជាតិ។

12. ដកចេតំណែងលោកនាយករដ្ឋមន្ត្រីហ៊ុនសែនជាប្រធានចេញពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ហើយដាក់ជំនួសតំណែងគាត់វិញដោយប្រធាន

ម្នាក់ដែលឯករាជ្យដែលគ្មានទំនាក់ទំនងពាក់ព័ន្ធនឹងគណៈបក្សប្រជាជនកម្ពុជាឬគ្រួសារត្រកូលហ៊ុន។

13. បញ្ចប់ភាពសម្ងាត់និងធ្វើឲ្យប្រសើរឡើងនូវគណនីយភាពជុំវិញអភិបាលកិច្ចល្អធនធានធម្មជាតិដែលរួមមាន:
   - បញ្ចប់ភាពសម្ងាត់និងធ្វើឲ្យប្រសើរឡើងនូវគណនីយភាពជុំវិញអភិបាលកិច្ចល្អធនធានធម្មជាតិដែលរួមមាន:
   - ដាក់មកវិញនូវប្រព័ន្ធទិន្នន័យអនឡាញស្តីពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រសួងកសិកម្មរុក្ខាប្រម៉ាញ់និងនេសាទ។ ពង្រីកប្រព័ន្ធទិន្នន័យដើមដើម្បីគ្រប់គ្រងលើដីសម្បទានសេដ្ឋកិច្ច។
   - បង្កើតដំណើរការគ្រប់គ្រងនិងត្រួតពិនិត្យសម្រាប់ការបែងចែកធនធានធម្មជាតិនិងការគ្រប់គ្រងក្នុងនោះរួមមានឱកាសសម្រាប់ត្រួតពិនិត្យមើលទាំងពីអង្គនិតិបញ្ញត្តិនិងសង្គមស៊ីវិលរួមទាំងសហគមន៍ដែលរងផលប៉ះពាល់ផងដែរ។
14. បញ្ចប់រាល់ការធ្វើទុក្ខបុកម្នេញចំពោះរាល់គ្រប់អ្នករិះគន់រដ្ឋាភិបាលដែលរួមមានដូចជា:
   - សមាជិកនិងអ្នកគាំទ្រដែលមកពីគណៈបក្សប្រឆាំង។
   - អ្នករិះគន់អនឡាញ។
   - អ្នកការពារសិទ្ធិមនុស្ស
   - អ្នកការពារដីធ្លីនិងព្រៃឈើ

ជាពិសេស បញ្ឈប់ការប្រើប្រាស់មិនត្រឹមត្រូវនូវអង្គភាពប្រឆាំងអំពើពុករលួយជាឧបករណ៍នយោបាយមួយដើម្បីវាយប្រហារនិងបំភិតបំភ័យសង្គមស៊ីវិល។ ដោះលែងអ្នកដែលត្រូវបានចាប់ឃុំឃាំងនាពេលថ្មីៗនេះនិងលប់ចោលរាល់ ការចោទប្រកាន់នានាប្រឆាំងនឹងពួកគេ។

**សមាជិកគ្រួសារត្រកូលហ៊ុន រួមថែមទាំងលោកនាយករដ្ឋមន្ត្រីហ៊ុនសែនគួរតែ:**

15. ធ្វើការប្រកាសជាសាធារណៈនូវទ្រព្យសម្បត្តិទាំងអស់របស់ពួកគេរួមថែមទាំងក្រុមហ៊ុនខ្សែបណ្តាញទំនាក់ទំនងក្នុងស្រុកនិងអន្តរជាតិនានា មិនថាទំនាក់ទំនងនោះជាផ្លូវការឬមិនផ្លូវការក្តី។
16. ធ្វើការប្រកាសជាសាធារណៈនូវទ្រព្យសម្បត្តិទាំងអស់របស់ពួកគេរួមថែមទាំងក្រុមហ៊ុនខ្សែបណ្តាញទំនាក់ទំនងក្នុងស្រុកនិងអន្តរជាតិនានា មិនថាទំនាក់ទំនងនោះជាផ្លូវការឬមិនផ្លូវការក្តី។



ហ៊ុន សែន, ប៊ុន រ៉ានី និង ហ៊ុន ម៉ានិត ធ្វើទស្សនកិច្ចប្រាសាទព្រះវិហារនៅក្នុងឆ្នាំ 2010



# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ1 - ការរកឃើញរបស់ពួកយើងទាំងអស់

តារាង រាយនាមក្រុមហ៊ុនឯកជនក្នុងស្រុកចំនួន114 ក្រុមហ៊ុនដែលកាលបរិច្ឆេទថ្ងៃខែរបស់អង្គការគ្លូបប៊លវីតណែសបង្ហាញពីការ ពាក់ព័ន្ធថ្មីៗរបស់គ្រួសារត្រកូលហ៊ុនក្នុងក្រុមហ៊ុននោះ។ ស្ទើតែទាំងអស់នៃព័ត៌មាននេះត្រូវបានយកមកពីការចុះបញ្ជីក្រុមហ៊ុននានារបស់ក្រសួងពាណិជ្ជកម្ម ក៏ប៉ុន្តែក្នុងករណីមួយចំនួនខ្លះត្រូវបានបន្ថែមដោយប្រភពនានារបស់ព័ត៌មាននិងរបាយការណ៍សារព័ត៌មានរបស់ រដ្ឋាភិបាលកម្ពុជា។

| សមាជិកគ្រួសារហ៊ុន | ក្រុមហ៊ុន*<br>*ក្រុមហ៊ុនទាំងឡាយដែលបានគូសពណ៌ក្រហមលេចឡើងនៅក្នុងតារាងលើសពីម្តង ពីព្រោះក្រុមហ៊ុនទាំងនោះមានទំនាក់ទំនងជាមួយសមាជិកគ្រួសារហ៊ុនលើសពីម្នាក់ | ទំនាក់ទំនងជាមួយក្រុមហ៊ុន/ប្រភេទនៃទំនាក់ទំនង*<br>*នៅពេលដែលគ្មានការបញ្ជាក់អំពីទំហំនៃភាគហ៊ុន គឺមានន័យថាមិនទទួលបានព័ត៌មាននោះទេ | កំណត់ត្រាអំពីសាជីវកម្មនៅក្នុងប្រទេសកម្ពុជា ឬប្រភពព័ត៌មានដែលអាចរកបានផ្សេងទៀត | មូលធនរបស់ក្រុមហ៊ុននៅពេលចុះបញ្ជីជាដុល្លារអាមេរិក*<br>*តួលេខទាំងនេះភាគច្រើនអាចត្រូវបានរកឃើញតាមរយៈការដោនឡូតកម្មវិធីកុំព្យូទ័រនៃសន្លឹកតារាងទិន្នន័យដើម (raw data spreadsheets) នៃការចុះបញ្ជីក្រុមហ៊ុនពីសាជីវកម្មនៃប្រទេសកម្ពុជា | វិស័យ*<br>*នេះគឺផ្អែកតាមព័ត៌មានល្អបំផុតដែលអាចរកបាន រួមមានការប្រមូលផ្តុំទិន្នន័យរបស់ MoC ព័ត៌មានខាងក្រៅ ដូចជា គេហទំព័ររបស់សាជីវកម្ម និងឈ្មោះរបស់ក្រុមហ៊ុន នៅក្នុងករណីមួយចំនួន។ សម្រាប់ឯកសារយោងពេញលេញ សូមទំនាក់ទំនង Global Witness |
|---|---|---|---|---|---|
| Dy Chouch | Pich Sambath Import Export Co. | Chair | R2425 | 5,000.00 | Trading |
| Dy Chouch | C Pimex Co. | Chair; Director: Shareholder | A1319 | 5,000.00 | Trading |
| Dy Vichea | Dy Corp | Chair | R15979 | 5,000.00 | Unknown |
| Dy Vichea | Emperor Group | Chair | R12380 | 5,000.00 | Conglomerate - Financial services, construction/real estate, watch and jewellery, hospitality/entertainment, media, furniture and furnishing, as well as food and beverage |
| Dy Vichea | VC Group | Chair | R16097 | 1,000.00 | Mining |
| Dy Vichea | Poseidon Co Ltd (listed as *'Poseldon' by the MoC)* | Director; Shareholder | A4879 | Unknown | Gambling |
| Dy/Hok Chendavy | D & M (Bavet) SEZ Co | Developer | Official Cambodian government data collated and displayed on the Open Development Mekong website, https://cambodia.opendevelopmentmekong.net/profiles/special-economic-zones/?map_id=6 (last accessed 1st June 2016) | 52,000,000.00 | Special Economic Zone |
| Hun Chantha | Fortress Group | Chair | R18381 | 8,000,000.00 | Unknown |
| Hun Chantha | Fortress Travel Agency | Chair | R18380 | 8,000,000.00 | Tourism |
| Hun Chantha | Fortress Construction Co | Chair | R5424 | 2,000,000.00 | Construction/real estate |
| Hun Chantha | Fortress Investment Company International | Chair | R16272 | 8,000,000.00 | Finance |
| Hun Chantha | Advance Development Group (ADG) Co | Chair | R16024 | 5,000.00 | Trading |
| Hun Chantha | SPK 1 | Chair | R25317 | 1,000.00 | Unknown |
| Hun Chantha | SPK Group | Chair | R3559 | 5,000.00 | Unknown |
| Hun Chantha | SID Cambodian Co | Chair | R232 | 1,000,000.00 | Unknown |
| Hun Chantha | Cambodian Top Investment (CTI) | Chair | R15642 | 200,000.00 | Finance |
| Hun Chantha | Gold 999 99 | Chair | R19191 | 175,000.00 | Unknown |
| Hun Chantha | Tourism (Cambodia) Co. | Chair | R15530 | 6,000.00 | Tourism |
| Hun Chantha | (Cambodian) International Franchise Co. | Director; Shareholder (through Fortress Investment Company International) | A5727 | 5,000.00 | Trading |
| Hun Chanthou | Heritage Investment Corporation Co. | Chair | R18390 | 500,000.00 | Finance |
| Hun Chea | Hun Chea Transport Co. | Chair | R4509 | 5,000.00 | Transport |
| Hun Chea | CHSN Transportation Co. | Chair | R3133 | 5,000.00 | Transport |
| Hun Chea | CHLK Trading Co. | Chair | R2146 | 5,000.00 | Trading |
| Hun Chea | (Cambodian) HC Trading Co. | Chair | R1002 | 5,000.00 | Trading |
| Hun Chea | PSZ Trading | Director; Shareholder (10%) | A5147 | 5,000.00 | Trading |
| Hun Kimleng | HML Xat Consulting | Chair | R25296 | 100,000.00 | Professional services (tax advisors) |
| Hun Kimleng | Eastern (Cambodia) International Investment | Chair; Shareholder (49%) | A799 | 5,000,000.00 | Trading |
| Hun Kimleng | F & B Life Style Investment | Chair | R18498 | 5,000.00 | Unknown |
| Hun Kimleng | Gloria Jean's Coffees (Cambodia) | Chair | R18902 | 5,000.00 | Hospitality/entertainment |
| Hun Kimleng | HD Rock Café & Shop | Chair; Director; Shareholder (75%) | R8322; A9983; A9875 | 5,000.00 | Hospitality/entertainment |
| Hun Kimleng | HKLCH Import Export | Chair | R23359 | 10,000,000.00 | Trading |
| Hun Kimleng | HML Consulting | Chair | R25187 | 100,000.00 | Professional services - Legal |

| សមាជិកគ្រួសារហ៊ុន | ក្រុមហ៊ុន*<br>*ក្រុមហ៊ុនទាំងឡាយដែលបានគូសពណ៌ក្រហមលេចឡើងនៅក្នុងតារាងលើសពីម្តង ពីព្រោះក្រុមហ៊ុនទាំងនោះមានទំនាក់ទំនងជាមួយសមាជិកគ្រួសារហ៊ុនលើសពីម្នាក់ | ទំនាក់ទំនងជាមួយក្រុមហ៊ុន/ប្រភេទនៃទំនាក់ទំនង*<br>*នៅពេលដែលគ្មានការបញ្ជាក់អំពីទំហំនៃភាគហ៊ុន គឺមានន័យថាមិនទទួលបានព័ត៌មាននោះទេ | កំណត់ត្រាអំពីសាជីវកម្មនៅក្នុងប្រទេសកម្ពុជា ឬប្រភពព័ត៌មានដែលអាចរកបានផ្សេងទៀត | មូលធនរបស់ក្រុមហ៊ុននៅពេលចុះបញ្ជីជាដុល្លារអាមេរិក*<br>*តួលេខទាំងនេះភាគច្រើនអាចត្រូវបានរកឃើញតាមរយៈការដោនឡូតកម្មវិធីកុំព្យូទ័រនៃសន្លឹកតារាងទិន្នន័យដើម (raw data spreadsheets) នៃការចុះបញ្ជីក្រុមហ៊ុនពីសាជីវកម្មនៃប្រទេសកម្ពុជា | វិស័យ*<br>*នេះគឺផ្អែកតាមព័ត៌មានល្អបំផុតដែលអាចរកបាន រួមមានការប្រមូលផ្តុំទិន្នន័យរបស់ MoC ព័ត៌មានខាងក្រៅ ដូចជា គេហទំព័ររបស់សាជីវកម្ម និងឈ្មោះរបស់ក្រុមហ៊ុន នៅក្នុងករណីមួយចំនួន។ សម្រាប់ឯកសារយោងពេញលេញ សូមទំនាក់ទំនង Global Witness |
|---|---|---|---|---|---|
| Hun Kimleng | Worldwide Investment Group | Chair; Director; Shareholder | A5952 | 25,000.00 | Conglomerate - Food & beverages, advisory services, tourism, construction/real estate, mining, trading, hospitality/entertainment |
| Hun Kimleng | Worldwide Investment Incorporation | Chair; Shareholder (100%) | A5415 | 25,000.00 | Conglomerate - Food & beverages, advisory services, tourism, construction/real estate, mining, trading, hospitality/entertainment |
| Hun Kimleng | Kam Chin International Cooperation Group | Shareholder (51%) | A6710 | Unknown | Forestry |
| Hun Maly | TK Avenue | Chair | R25949 | 1,500.00 | Retail |
| Hun Maly | Cambodia Electricity Private | Director; Shareholder (5%) | A6979; A7920; Electric Authority of Cambodia, Decision on first revision of the license document no.132LD dated May 31 , 2006 for (Cambodia) Electricity Private Co., Ltd. for providing electric power generation service at Phnom Penh city for revising ownership of licensee, 27th November 2013. Document obtained by Global Witness investigators in October 2015. | Unknown | Energy |
| Hun Maly | (Cambodian) Food Industries Co | Director; Shareholder | A6257 | Unknown | Unknown |
| Hun Maly | Decampharma | Shareholder (10%) | A7567; A10029 | 50,000.00 | Pharmaceuticals |
| Hun Maly | Moon Media *(listed as Moon Advertising by the MoC)* | Shareholder; Director | A651 | 5,000.00 | Media |
| Hun Maly | Stone Grill | Shareholder | A7307 | 5,000.00 | Hospitality/entertainment |
| Hun Mana | NVC Corporation | Chair; Director; Shareholder (via NH Holding) | A5839 | Unknown | Manufacturing |
| Hun Mana | Ocasis Cambo Investment Group Co | Chair | R7623 | 10,000.00 | Unknown |
| Hun Mana | Ocasis Cambo Investment Co | Chair | R7622 | 10,000.00 | Unknown |
| Hun Mana | Star Aviation (Cambodia) | Chair | R18119 | 5,000.00 | Transport |
| Hun Mana | Star Airline (Cambodia) | Chair | R18113 | 5,000.00 | Transport |
| Hun Mana | Helistar (Cambodia) | Chair | R18118 | 5,000.00 | Transport |
| Hun Mana | Moon Media *(listed as Moon Advertising by the MoC)* | Chair; Director; Shareholder (51% via NH Holding) | A311; A651 | 5,000.00 *(figure only counted once in total despite repetition of company in table)* | Media |
| Hun Mana | Bayon Media Hight System Co | Chair; Director; Shareholder (100%) | A7110 | Unknown | Media |
| Hun Mana | Bayon CM Organizer Co | Chair; Shareholder (25% via Bayon Media Hight System Co) | R22109; A4765 | 5,000.00 | Media |
| Hun Mana | Jaya Holding Ltd | Chair | R15680 | 222,000.00 | Unknown |
| Hun Mana | Dragon Royal Telecom | Chair; Director | A4764 | 2,000,000.00 | Telecomms |
| Hun Mana | Kampuchea Thmey Daily Co | Chair; Director; Shareholder (100%) | R6193; A473 | 5,000.00 | Media |
| Hun Mana | NVN Corporation Co | Chair | R1850 | 500,000.00 | Construction/real estate |
| Hun Mana | MLM Resort Group Co | Chair | R3836 | 5,000.00 | Tourism |
| Hun Mana | K Thong Huot Telecom | Director; Shareholder (20%) | A6195 | Unknown | Retail |
| Hun Mana | NH Holding | Representative | A311; A5839; A2534 | Unknown | Finance |
| Hun Mana | Viettel (Cambodia) PTE | Shareholder (6% via NH Holding) | A2588 | 44,877,168.00 | Telecomms |
| Hun Mana | Royal Group Investment Company | Director; Shareholder | A4610 | 5,000.00 | Finance |
| Hun Mana | The Museum Company | Shareholder | A4617 | 2,500,000.00 | Tourism |
| Hun Mana | Vina (HK) | Shareholder | A5068 | 16,000,000.00 | Gambling |
| Hun Mana | Cambodia Electricity Private | Director; Shareholder (10%) | A6979; A7920; Electric Authority of Cambodia, Decision on first revision of the license document no.132LD dated May 31 , 2006 for (Cambodia) Electricity Private Co., Ltd. for providing electric power generation service at Phnom Penh city for revising ownership of licensee, 27th November 2013. Document obtained by Global Witness investigators in October 2015. | Unknown | Energy |



| សមាជិកគ្រួសារហ៊ុន | ក្រុមហ៊ុន*<br>*ក្រុមហ៊ុនទាំងឡាយដែលបានគូសពណ៌ក្រហមលេចឡើងនៅក្នុងតារាងលើសពីម្តង ពីព្រោះក្រុមហ៊ុនទាំងនោះមានទំនាក់ទំនងជាមួយសមាជិកគ្រួសារហ៊ុនលើសពីម្នាក់ | ទំនាក់ទំនងជាមួយក្រុមហ៊ុន/ប្រភេទនៃទំនាក់ទំនង*<br>*នៅពេលដែលគ្មានការបញ្ជាក់អំពីទំហំនៃភាគហ៊ុន គឺមានន័យថាមិនទទួលបានព័ត៌មាននោះទេ | កំណត់ត្រាអំពីសាជីវកម្មនៅក្នុងប្រទេសកម្ពុជា ឬប្រភពព័ត៌មានដែលអាចរកបានផ្សេងទៀត | មូលធនរបស់ក្រុមហ៊ុននៅពេលចុះបញ្ជីជាដុល្លារអាមេរិក*<br>*តួលេខទាំងនេះភាគច្រើនអាចត្រូវបានរកឃើញតាមរយៈការដោនឡូតកម្មវិធីកុំព្យូទ័រនៃសន្លឹកតារាងទិន្នន័យដើម (raw data spreadsheets) នៃការចុះបញ្ជីក្រុមហ៊ុនពីសាជីវកម្មនៃប្រទេសកម្ពុជា | វិស័យ*<br>*នេះគឺផ្អែកតាមព័ត៌មានល្អបំផុតដែលអាចរកបាន រួមមានការប្រមូលផ្តុំទិន្នន័យរបស់ MoC ព័ត៌មានខាងក្រៅ ដូចជា គេហទំព័ររបស់សាជីវកម្ម និងឈ្មោះរបស់ក្រុមហ៊ុន នៅក្នុងករណីមួយចំនួន។ សម្រាប់ឯកសារយោងពេញលេញ សូមទំនាក់ទំនង Global Witness |
|---|---|---|---|---|---|
| Hun Mana | Orkide Villa 3 | Chair | R32257 | 500,000.00 | Construction/real estate |
| Hun Manith | Cambodia Electricity Private | Director, Shareholder (5%) | A6979; A7920; Electric Authority of Cambodia, Decision on first revision of the license document no.132LD dated May 31 , 2006 for (Cambodia) Electricity Private Co., Ltd. for providing electric power generation service at Phnom Penh city for revising ownership of licensee, 27th November 2013. Document obtained by Global Witness investigators in October 2015. | Unknown | Energy |
| Hun Seng Ny | D.G.F. (Cambodia) Co. | Chair | R3035 | 1,000,000.00 | Unknown |
| Hun Seng Ny | Garuda Import Export (Garuda Group) | Chair | R22816 | 5,000.00 | Trading |
| Hun Seng Ny | Hatti Marketing Co | Chair | R21768 | 5,000.00 | Media |
| Hun Seng Ny | Hovercraft HiTec (Cambodia) Co | Chair | R21662 | 5,000.00 | Unknown |
| Hun Seng Ny | Metal Mining (Cambodia) Co | Chair | R16769; A5955 | 7,500.00 | Mining |
| Hun Seng Ny | Metal Mining (Cambodia) PLC | Chair; Shareholder | A8006 | Unknown | Mining |
| Hun Seng Ny | Rong De Group | Chair; Director; Shareholder | A1816 | 5,000.00 | Unknown |
| Hun Seng Ny | UNT Wholesale Co | Chair; Director; Shareholder (50%) | A5841; A5545 | Unknown | Trading |
| Hun Seng Ny | Attwood Investment Group* | Shareholder (50%)* | A4769 | 1,000,000.00 | Trading |
| Hun Seng Ny | SL Garments | Director General | Cambodia Daily, Hun Sen's sister linked to private security firm at SL factory, 14th November 2013, https://www.cambodiadaily.com/archives/hun-sens-sister-linked-to-private-security-firm-at-sl-factory-46946/ (last accessed 4th June 2016) | Unknown | Garments |
